  ត្រង់ $x=-1 \implies y=-2$ (ចំណុចអតិបរមាធៀប)

  ត្រង់ $x=1 \implies y=0$ (ចំណុចអប្បបរមាធៀប)

  ត្រង់ $x=2 \implies y=\dfrac{1}{4}$ ។




## ១.៣ សិក្សាអនុគមន៍ $y=\dfrac{ax^2+bx+c}{px^2+qx+r}$

**សម្គាល់**

**វិធាន** ដើម្បីរកដែនកំណត់អនុគមន៍ $y=\dfrac{ax^2+bx+c}{px^2+qx+r}$ គេត្រូវឱ្យភាគបែងស្មើសូន្យដោះស្រាយរកតម្លៃ $x$ គឺឱ្យ $px^2+qx+r=0$ ប្រើរូបមន្ត $\Delta$ ដើម្បីរក $x$ ។

- បើ $\Delta>0$ សមីការមានឫសពីរផ្សេងគ្នាជាចំនួនពិត $x_1$ , $x_2$ គេបានដែនកំណត់ $D=\mathbb{R}-\{x_1,x_2\}$ ។
- បើ $\Delta=0$ សមីការមានឫសឌុប $x_1=x_2=\alpha$ គេបានដែនកំណត់ $D=\mathbb{R}-\{\alpha\}$ ។
- បើ $\Delta<0$ សមីការគ្មានឫសជាចំនួនពិតគេបាន គេបានដែនកំណត់ $D=\mathbb{R}$ ។
- ចំពោះភាគបែងរាង $ax^2+b$ ដែល $a>0$ , $b>0$ នាំឱ្យ $ax^2+b>0$ , $\forall x\in\mathbb{R}$ គេបានដែនកំណត់ $D=\mathbb{R}$ ។
- ចំពោះភាគបែងរាង $ax^2+b$ ដែល $a<0$ , $b<0$ នាំឱ្យ $ax^2+b<0$ , $\forall x\in\mathbb{R}$ គេបានដែនកំណត់ $D=\mathbb{R}$ ។

**រំលឹក**

សមីការដឺក្រេទី២ $ax^2+bx+c=0$ ប្រើរូបមន្ត $\Delta=b^2-4ac$

- បើ $\Delta>0$ សមីការមានឫសពីរជាចំនួនពិត គេបាន $x_1,x_2=\dfrac{-b\pm\sqrt{\Delta}}{2a}$
- បើ $\Delta=0$ សមីការមានឫសឌុប $x_1=x_2=-\dfrac{b}{2a}$
- បើ $\Delta<0$ សមីការគ្មានជាចំនួនពិតយកសញ្ញាតាមមេគុណ $a$ ។

ករណីសមីការ $ax^2+bx+c=0$ មានមេគុណ $b$ ជាចំនួនគូគេអាចប្រើរូបមន្ត $\Delta'=b'^2-ac$ ដែល $b'=\dfrac{b}{2}$

- បើ $\Delta'>0$ សមីការមានឫសពីរជាចំនួនពិត គេបាន $x_1,x_2=\dfrac{-b'\pm\sqrt{\Delta'}}{a}$
- បើ $\Delta'=0$ សមីការមានឫសឌុប $x_1=x_2=-\dfrac{b'}{a}$
- បើ $\Delta'<0$ សមីការគ្មានជាចំនួនពិតយកសញ្ញាតាមមេគុណ $a$ ។

**ករណីពិសេស** : ឧបមាថាសមីការដឺក្រេទី២ $ax^2+bx+c=0$ ៖

- បើ $a+b+c=0$ គេបានសមីការមានឫស $x_1=1$ , $x_2=\dfrac{c}{a}$
- បើ $a-b+c=0$ រឺ $a+c=b$ គេបានសមីការមានឫស $x_1=-1$ , $x_2=-\dfrac{c}{a}$ ។

## លំហាត់

**1** រកដែនកំណត់នៃអនុគមន៍ខាងក្រោម

ⓐ $f(x)=\dfrac{x^2-3x+6}{x^2+x-6}$

ⓑ $f(x)=\dfrac{2x^2-x}{x^2-3x+2}$

ⓒ $f(x)=\dfrac{1-3x+x^2}{x^2+2}$

ⓓ $f(x)=\dfrac{-x^2+3x-5}{2x^2-x+3}$

ⓔ $f(x)=\dfrac{x^2+1}{x^2-6x+9}$

ⓕ $f(x)=\dfrac{1-3x^2}{x^2-4}$

**2** សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ខាងក្រោម

ⓐ $f(x)=\dfrac{2x^2-9x+4}{x^2+x-12}$

ⓑ $f(x)=\dfrac{3x^2-18x+25}{x^2-6x+8}$

ⓒ $f(x)=\dfrac{x^2+2x}{x^2+4}$

ⓓ $f(x)=\dfrac{x^2-1}{(x+2)^2}$

ⓔ $f(x)=\dfrac{-x^2-2x+3}{x^2+3x+2}$

**3** គេឱ្យអនុគមន៍ $y=f(x)=\dfrac{mx^2+1}{x}$ មានក្រាប $(C)$ ។

ⓐ សិក្សាអថេរភាព និងសង់ក្រាប ចំពោះ $m=1$

ⓑ កំណត់តម្លៃ $m$ ដើម្បីឱ្យអនុគមន៍ កើនក្នុងចន្លោះ $\left[\dfrac{1}{2},+\infty\right)$

ⓒ តើចំណុចនឹងដែលស្ថិតលើក្រាប $(C)$ ចំពោះគ្រប់ $m$ ឬទេ?

ⓓ ដោយប្រើក្រាប $(C)$ កំណត់តម្លៃ $a$ ដើម្បីឱ្យ $x^2-ax+1>0$ ចំពោះគ្រប់ $x>0$ ។

# ដំណោះស្រាយ

**1** រកដែនកំណត់នៃអនុគមន៍ខាងក្រោម

ⓐ $f(x)=\dfrac{x^2-3x+6}{x^2+x-6}$

- អនុគមន៍ $f(x)$ មានន័យកាលណា ភាគបែង $x^2+x-6\neq 0$
- សមីការ $x^2+x-6=0 \iff (x+3)(x-2)=0 \implies x=-3$ ឬ $x=2$
- ដូចនេះ ដែនកំណត់នៃអនុគមន៍គឺ $D=\mathbb{R}\setminus\{-3,2\}$

ⓑ $f(x)=\dfrac{2x^2-x}{x^2-3x+2}$

- អនុគមន៍ $f(x)$ មានន័យកាលណា ភាគបែង $x^2-3x+2\neq 0$
- សមីការ $x^2-3x+2=0 \iff (x-1)(x-2)=0 \implies x=1$ ឬ $x=2$
- ដូចនេះ ដែនកំណត់នៃអនុគមន៍គឺ $D=\mathbb{R}\setminus\{1,2\}$

ⓒ $f(x)=\dfrac{1-3x+x^2}{x^2+2}$

- អនុគមន៍ $f(x)$ មានន័យកាលណា ភាគបែង $x^2+2\neq 0$
- ដោយ $x^2+2>0$ ចំពោះគ្រប់ $x\in\mathbb{R}$
- ដូចនេះ ដែនកំណត់នៃអនុគមន៍គឺ $D=\mathbb{R}$

ⓓ $f(x)=\dfrac{-x^2+3x-5}{2x^2-x+3}$

- អនុគមន៍ $f(x)$ មានន័យកាលណា ភាគបែង $2x^2-x+3\neq 0$
- សមីការ $2x^2-x+3=0$ មាន $\Delta=(-1)^2-4(2)(3)=-23<0$ នាំឱ្យ $2x^2-x+3>0$ ចំពោះគ្រប់ $x\in\mathbb{R}$
- ដូចនេះ ដែនកំណត់នៃអនុគមន៍គឺ $D=\mathbb{R}$

ⓔ $f(x)=\dfrac{x^2+1}{x^2-6x+9}$

- អនុគមន៍ $f(x)$ មានន័យកាលណា ភាគបែង $x^2-6x+9\neq 0$
- សមីការ $x^2-6x+9=0 \iff (x-3)^2=0 \implies x=3$
- ដូចនេះ ដែនកំណត់នៃអនុគមន៍គឺ $D=\mathbb{R}\setminus\{3\}$

ⓕ $f(x)=\dfrac{1-3x^2}{x^2-4}$

- អនុគមន៍ $f(x)$ មានន័យកាលណា ភាគបែង $x^2-4\neq 0$
- សមីការ $x^2-4=0 \iff (x-2)(x+2)=0 \implies x=-2$ ឬ $x=2$
- ដូចនេះ ដែនកំណត់នៃអនុគមន៍គឺ $D=\mathbb{R}\setminus\{-2,2\}$

**2** សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ខាងក្រោម

ⓐ $f(x)=\dfrac{2x^2-9x+4}{x^2+x-12}$

- ដែនកំណត់ : សមីការ $x^2+x-12=0 \iff (x+4)(x-3)=0 \implies x=-4$ ឬ $x=3$ ៕

  ដូចនេះ អនុគមន៍ $f(x)$ មានដែនកំណត់ $D=\mathbb{R}\setminus\{-4,3\}$ ៕
- ទិសដៅអថេរភាព
  - ដេរីវេ

$$f'(x)=\frac{(4x-9)(x^2+x-12)-(2x+1)(2x^2-9x+4)}{(x^2+x-12)^2}=\frac{11x^2-56x+104}{(x^2+x-12)^2}$$

  ដោយ $(x^2+x-12)^2>0$ ចំពោះគ្រប់ $x\in D$ ហើយភាគយក $11x^2-56x+104$ មាន $\Delta'=(-28)^2-11(104)=-360<0$ នាំឱ្យ $11x^2-56x+104>0$ ចំពោះគ្រប់ $x\in\mathbb{R}$ ៕

  គេបាន $f'(x)>0$ ចំពោះគ្រប់ $x\in D$ ៕

  ដូចនេះ អនុគមន៍ $f(x)$ កើនដាច់ខាតលើចន្លោះ $(-\infty,-4)$, $(-4,3)$ និង $(3,+\infty)$ ៕
  - គណនាលីមីត
    - $\lim\limits_{x\to-4^-}f(x)=\lim\limits_{x\to-4^-}\dfrac{2x^2-9x+4}{(x+4)(x-3)}=+\infty$
    - $\lim\limits_{x\to-4^+}f(x)=\lim\limits_{x\to-4^+}\dfrac{2x^2-9x+4}{(x+4)(x-3)}=-\infty$
    - $\lim\limits_{x\to3^-}f(x)=\lim\limits_{x\to3^-}\dfrac{2x^2-9x+4}{(x+4)(x-3)}=+\infty$
    - $\lim\limits_{x\to3^+}f(x)=\lim\limits_{x\to3^+}\dfrac{2x^2-9x+4}{(x+4)(x-3)}=-\infty$
    - $\lim\limits_{x\to\pm\infty}f(x)=\lim\limits_{x\to\pm\infty}\dfrac{2x^2}{x^2}=2$
  - អាស៊ីមតូត គេមាន $\lim\limits_{x\to\pm\infty}f(x)=2$ គេបានបន្ទាត់ $y=2$ ជាអាស៊ីមតូតដេកនៃក្រាប ៕

    $\lim\limits_{x\to-4}f(x)=\pm\infty$ និង $\lim\limits_{x\to3}f(x)=\pm\infty$ គេបានសមីការ $x=-4$ និង $x=3$ ជាអាស៊ីមតូតឈរទាំងពីរនៃក្រាប ៕
  - តារាងអថេរភាព

| $x$ | $-\infty$ | | $-4$ | | $3$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | $+$ | | $+$ | | $+$ | | |
| $f(x)$ | $2$ | $\nearrow$ | $+\infty$ / $-\infty$ | $\nearrow$ | $+\infty$ / $-\infty$ | $\nearrow$ | $2$ / $-\infty$ |

- សំណង់ក្រាប
  - ចំណុចប្រសព្វរវាងក្រាប $C$ និងអ័ក្ស $x'Ox$ គឺ

$y=0 \iff 2x^2-9x+4=0 \implies x=\dfrac{1}{2}$ ឬ $x=4$ ។

ដូចនេះ ក្រាបកាត់អ័ក្ស $x'Ox$ ត្រង់ចំណុច $\left(\dfrac{1}{2},0\right)$ និង $(4,0)$ ។

- ចំណុចប្រសព្វរវាងក្រាប $C$ និងអ័ក្ស $y'Oy$ គឺ


$x=0 \implies f(0)=-\dfrac{4}{12}=-\dfrac{1}{3}$ ។

ដូចនេះ ក្រាបកាត់អ័ក្ស $y'Oy$ ត្រង់ចំណុច $\left(0,-\dfrac{1}{3}\right)$ ។

- ចំណុចជំនួយបន្ថែម ៖

ត្រង់ $x=2 \implies y=1$

ត្រង់ $x=5 \implies y=\dfrac{1}{2}$ ។




ⓑ $f(x)=\dfrac{3x^2-18x+25}{x^2-6x+8}$

- ដែនកំណត់ : សមីការ $x^2-6x+8=0 \iff (x-2)(x-4)=0 \implies x=2$ ឬ $x=4$ ។

ដូចនេះ អនុគមន៍ $f(x)$ មានដែនកំណត់ $D=\mathbb{R}\setminus\{2,4\}$ ។

- ទិសដៅអថេរភាព

- ដេរីវេ

$$f'(x)=\frac{(6x-18)(x^2-6x+8)-(2x-6)(3x^2-18x+25)}{(x^2-6x+8)^2}=\frac{2(3-x)}{(x^2-6x+8)^2}$$

ដោយ $(x^2-6x+8)^2>0$ ចំពោះគ្រប់ $x\in D$ គេបានសញ្ញានៃ $f'(x)$ យកតាមសញ្ញានៃភាគយក $2(3-x)$ ៖

- $f'(x)=0 \iff 3-x=0 \implies x=3$
- $f'(x)>0$ ចំពោះ $x\in(-\infty,2)\cup(2,3)$
- $f'(x)<0$ ចំពោះ $x\in(3,4)\cup(4,+\infty)$

ដូចនេះ អនុគមន៍កើនលើចន្លោះ $(-\infty,2)$ និង $(2,3)$ ហើយចុះលើចន្លោះ $(3,4)$ និង

$(4,+\infty)$ ៕

- បរមាធៀប
  - អនុគមន៍មានអតិបរមាធៀបត្រង់ $x=3$ គឺ $f(3)=2$
- គណនាលីមីត
  - $\lim\limits_{x\to 2^-} f(x)=\lim\limits_{x\to 2^-}\dfrac{3x^2-18x+25}{(x-2)(x-4)}=+\infty$
  - $\lim\limits_{x\to 2^+} f(x)=\lim\limits_{x\to 2^+}\dfrac{3x^2-18x+25}{(x-2)(x-4)}=-\infty$
  - $\lim\limits_{x\to 4^-} f(x)=\lim\limits_{x\to 4^-}\dfrac{3x^2-18x+25}{(x-2)(x-4)}=-\infty$
  - $\lim\limits_{x\to 4^+} f(x)=\lim\limits_{x\to 4^+}\dfrac{3x^2-18x+25}{(x-2)(x-4)}=+\infty$
  - $\lim\limits_{x\to \pm\infty} f(x)=\lim\limits_{x\to \pm\infty}\dfrac{3x^2}{x^2}=3$
- អាស៊ីមតូត គេមាន $\lim\limits_{x\to\pm\infty} f(x)=3$ គេបានបន្ទាត់ $y=3$ ជាអាស៊ីមតូតដេកនៃក្រាប ៕ $\lim\limits_{x\to 2} f(x)=\pm\infty$ និង $\lim\limits_{x\to 4} f(x)=\pm\infty$ គេបានសមីការ $x=2$ និង $x=4$ ជាអាស៊ីមតូតឈរទាំងពីរនៃក្រាប ៕
- តារាងអថេរភាព

| $x$ | $-\infty$ | | $2$ | | $3$ | | $4$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | | $+$ | $0$ | $-$ | | $-$ | |
| $f(x)$ | $3$ | ↗ | $+\infty$ | $-\infty$ | ↗ | $2$ | ↘ | $-\infty$ | ↘ $3$ |

- សំណង់ក្រាប
  - ចំណុចប្រសព្វរវាងក្រាប $C$ និងអ័ក្ស $x'Ox$ គឺ

    $y=0 \iff 3x^2-18x+25=0 \implies x=\dfrac{9-\sqrt{6}}{3}\approx 2.18$ ឬ $x=\dfrac{9+\sqrt{6}}{3}\approx 3.82$ ៕
  - ចំណុចប្រសព្វរវាងក្រាប $C$ និងអ័ក្ស $y'Oy$ គឺ


    $x=0 \implies f(0)=\dfrac{25}{8}$ ៕

    ដូចនេះ ក្រាបកាត់អ័ក្ស $y'Oy$ ត្រង់ចំណុច $\left(0,\dfrac{25}{8}\right)$ ៕
  - ចំណុចជំនួយបន្ថែម ៖

    ត្រង់ $x=1 \implies y=\dfrac{10}{3}$

    ត្រង់ $x=3 \implies y=2$ (ចំណុចអតិបរមាធៀប)

    ត្រង់ $x=5 \implies y=\dfrac{10}{3}$ ៕




ⓒ $f(x)=\dfrac{x^2+2x}{x^2+4}$

- ដែនកំណត់ : ដោយ $x^2+4>0$ ចំពោះគ្រប់ $x\in\mathbb{R}$ ។
  ដូចនេះ អនុគមន៍ $f(x)$ មានដែនកំណត់ $D=\mathbb{R}$ ។
- ទិសដៅអថេរភាព
  - ដេរីវេ

$$f'(x)=\frac{(2x+2)(x^2+4)-2x(x^2+2x)}{(x^2+4)^2}=\frac{-2x^2+8x+8}{(x^2+4)^2}=\frac{-2(x^2-4x-4)}{(x^2+4)^2}$$

ដោយ $(x^2+4)^2>0$ ចំពោះគ្រប់ $x\in\mathbb{R}$ គេបានសញ្ញានៃ $f'(x)$ យកតាមសញ្ញានៃភាគយក $-2(x^2-4x-4)$ ៖

- $f'(x)=0\iff x^2-4x-4=0\implies x=2-2\sqrt{2}$ ឬ $x=2+2\sqrt{2}$
- $f'(x)>0$ ចំពោះ $x\in(2-2\sqrt{2},2+2\sqrt{2})$
- $f'(x)<0$ ចំពោះ $x\in(-\infty,2-2\sqrt{2})\cup(2+2\sqrt{2},+\infty)$

ដូចនេះ អនុគមន៍កើនលើចន្លោះ $(2-2\sqrt{2},2+2\sqrt{2})$ ហើយចុះលើចន្លោះ $(-\infty,2-2\sqrt{2})$ និង $(2+2\sqrt{2},+\infty)$ ។


- បរមាធៀប
  - អនុគមន៍មានអប្បបរមាធៀបត្រង់ $x=2-2\sqrt{2}\approx-0.83$ គឺ $f(2-2\sqrt{2})=\dfrac{1-\sqrt{2}}{2}\approx-0.21$
  - អនុគមន៍ មាន អតិបរមា ធៀប ត្រង់ $x=2+2\sqrt{2}\approx4.83$ គឺ $f(2+2\sqrt{2})=\dfrac{1+\sqrt{2}}{2}\approx1.21$
- គណនាលីមីត
  - $\lim\limits_{x\to-\infty}f(x)=\lim\limits_{x\to-\infty}\dfrac{x^2\left(1+\dfrac{2}{x}\right)}{x^2\left(1+\dfrac{4}{x^2}\right)}=1$

$\circ \lim\limits_{x\to+\infty} f(x) = \lim\limits_{x\to+\infty} \dfrac{x^2\left(1+\dfrac{2}{x}\right)}{x^2\left(1+\dfrac{4}{x^2}\right)} = 1$

- អាស៊ីមតូត គេមាន $\lim\limits_{x\to\pm\infty} f(x) = 1$ គេបានបន្ទាត់ $y = 1$ ជាអាស៊ីមតូតដេកនៃក្រាប ។
- តារាងអថេរភាព

| $x$ | $-\infty$ | | $2-2\sqrt{2}$ | | $2+2\sqrt{2}$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $-$ | $0$ | $+$ | $0$ | $-$ | |
| $f(x)$ | $1$ | ↘ | $\dfrac{1-\sqrt{2}}{2}$ | ↗ | $\dfrac{1+\sqrt{2}}{2}$ | ↘ | $1$ |

- សំណង់ក្រាប
  - ចំណុចប្រសព្វរវាងក្រាប $C$ និងអ័ក្ស $x'Ox$ គឺ
    $y = 0 \iff x^2+2x = 0 \implies x = 0$ ឬ $x = -2$ ។
    ដូចនេះ ក្រាបកាត់អ័ក្ស $x'Ox$ ត្រង់ចំណុច $(0,0)$ និង $(-2,0)$ ។
  - ចំណុចប្រសព្វរវាងក្រាប $C$ និងអ័ក្ស $y'Oy$ គឺ
    $x = 0 \implies f(0) = 0$ ។
  - ចំណុចជំនួយបន្ថែម ៖
    ត្រង់ $x = -4 \implies y = \dfrac{2}{5} = 0.4$
    ត្រង់ $x = 2 \implies y = 1$
    ត្រង់ $x = 4 \implies y = \dfrac{6}{5} = 1.2$ ។




(d) $f(x) = \dfrac{x^2-1}{(x+2)^2}$

- ដែនកំណត់ : សមីការ $(x+2)^2 = 0 \implies x = -2$ ។

ដូចនេះ អនុគមន៍ $f(x)$ មានដែនកំណត់ $D = \mathbb{R} \setminus \{-2\}$ ៕

- ទិសដៅអថេរភាព

  - ដេរីវេ

$$f'(x) = \frac{2x(x+2)^2 - 2(x+2)(x^2-1)}{(x+2)^4} = \frac{2(x+2)(x^2+2x-x^2+1)}{(x+2)^4} = \frac{2(2x+1)}{(x+2)^3}$$

សញ្ញានៃ $f'(x)$ អាស្រ័យលើសញ្ញានៃភាគយក $2x+1$ និងភាគបែង $(x+2)^3$ ៖

- $f'(x) = 0 \iff 2x+1 = 0 \implies x = -\frac{1}{2}$
- $f'(x) > 0$ ចំពោះ $x \in (-\infty, -2) \cup \left(-\frac{1}{2}, +\infty\right)$
- $f'(x) < 0$ ចំពោះ $x \in \left(-2, -\frac{1}{2}\right)$

នោះ អនុគមន៍កើនលើចន្លោះ $(-\infty, -2)$ និង $\left(-\frac{1}{2}, +\infty\right)$ ហើយចុះលើចន្លោះ $\left(-2, -\frac{1}{2}\right)$

- បរមាធៀប

  - អនុគមន៍មានអប្បបរមាធៀបត្រង់ $x = -\frac{1}{2}$ គឺ $f\left(-\frac{1}{2}\right) = -\frac{1}{3}$

- គណនាលីមីត

  - $\lim\limits_{x \to -2^-} f(x) = \lim\limits_{x \to -2^-} \frac{x^2-1}{(x+2)^2} = +\infty$
  - $\lim\limits_{x \to -2^+} f(x) = \lim\limits_{x \to -2^+} \frac{x^2-1}{(x+2)^2} = +\infty$
  - $\lim\limits_{x \to \pm\infty} f(x) = \lim\limits_{x \to \pm\infty} \frac{x^2\left(1 - \frac{1}{x^2}\right)}{x^2\left(1 + \frac{2}{x}\right)^2} = 1$

- អាស៊ីមតូត គេមាន $\lim\limits_{x \to \pm\infty} f(x) = 1$ គេបានបន្ទាត់ $y = 1$ ជាអាស៊ីមតូតដេកនៃក្រាប ៕
  $\lim\limits_{x \to -2} f(x) = +\infty$ គេបានសមីការ $x = -2$ ជាអាស៊ីមតូតឈរនៃក្រាប ៕

- តារាងអថេរភាព

| $x$ | $-\infty$ | | $-2$ | | $-\frac{1}{2}$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $1$ | ↗ | $+\infty$ ‖ $+\infty$ | ↘ | $-\frac{1}{3}$ | ↗ | $1$ |

- សំណង់ក្រាប

  - ចំណុចប្រសព្វរវាងក្រាប $C$ និងអ័ក្ស $x'Ox$ គឺ
    $y = 0 \iff x^2 - 1 = 0 \implies x = -1$ ឬ $x = 1$ ៕

ដូចនេះ ក្រាបកាត់អ័ក្ស $x'Ox$ ត្រង់ចំណុច $(-1,0)$ និង $(1,0)$ ។

- ចំណុចប្រសព្វរវាងក្រាប $C$ និងអ័ក្ស $y'Oy$ គឺ

$x=0 \implies f(0)=-\dfrac{1}{4}$ ។


ដូចនេះ ក្រាបកាត់អ័ក្ស $y'Oy$ ត្រង់ចំណុច $\left(0,-\dfrac{1}{4}\right)$ ។

- ចំណុចជំនួយបន្ថែម ៖

ត្រង់ $x=-4 \implies y=\dfrac{15}{4}$

ត្រង់ $x=-3 \implies y=8$

ត្រង់ $x=-\dfrac{1}{2} \implies y=-\dfrac{1}{3}$ (ចំណុចអប្បបរមាធៀប) ។




ⓔ $f(x)=\dfrac{-x^2-2x+3}{x^2+3x+2}$

- ដែនកំណត់ : សមីការ $x^2+3x+2=0 \iff (x+1)(x+2)=0 \implies x=-2$ ឬ $x=-1$ ។

ដូចនេះ អនុគមន៍ $f(x)$ មានដែនកំណត់ $D=\mathbb{R}\setminus\{-2,-1\}$ ។

- ទិសដៅអថេរភាព

- ដេរីវេ

$$f'(x)=\frac{(-2x-2)(x^2+3x+2)-(2x+3)(-x^2-2x+3)}{(x^2+3x+2)^2}=\frac{-(x^2+10x+13)}{(x^2+3x+2)^2}$$

ដោយ $(x^2+3x+2)^2>0$ ចំពោះគ្រប់ $x\in D$ គេបានសញ្ញានៃ $f'(x)$ យកតាមសញ្ញានៃភាគយក $-(x^2+10x+13)$ ៖

- $f'(x)=0 \iff x^2+10x+13=0 \implies x=-5-2\sqrt{3}\approx -8.46$ ឬ $x=-5+2\sqrt{3}\approx -1.54$
- $f'(x)>0$ ចំពោះ $x\in(-5-2\sqrt{3},-2)\cup(-2,-5+2\sqrt{3})$
- $f'(x)<0$ ចំពោះ $x\in(-\infty,-5-2\sqrt{3})\cup(-5+2\sqrt{3},-1)\cup(-1,+\infty)$

ដូចនេះ អនុគមន៍កើនលើចន្លោះ $(-5-2\sqrt{3},-2)$ និង $(-2,-5+2\sqrt{3})$ ហើយចុះលើចន្លោះ $(-\infty,-5-2\sqrt{3}),(-5+2\sqrt{3},-1)$ និង $(-1,+\infty)$ ។

- បរមាធៀប
  - អនុគមន៍មានអប្បបរមាធៀបត្រង់ $x=-5-2\sqrt{3}$ គឺ $f(-5-2\sqrt{3})=4\sqrt{3}-8\approx -1.07$
  - អនុគមន៍មានអតិបរមាធៀបត្រង់ $x=-5+2\sqrt{3}$ គឺ $f(-5+2\sqrt{3})=-4\sqrt{3}-8\approx -14.93$
- គណនាលីមីត
  - $\lim\limits_{x\to -2^-} f(x)=\lim\limits_{x\to -2^-}\dfrac{-x^2-2x+3}{(x+1)(x+2)}=+\infty$
  - $\lim\limits_{x\to -2^+} f(x)=\lim\limits_{x\to -2^+}\dfrac{-x^2-2x+3}{(x+1)(x+2)}=-\infty$
  - $\lim\limits_{x\to -1^-} f(x)=\lim\limits_{x\to -1^-}\dfrac{-x^2-2x+3}{(x+1)(x+2)}=-\infty$
  - $\lim\limits_{x\to -1^+} f(x)=\lim\limits_{x\to -1^+}\dfrac{-x^2-2x+3}{(x+1)(x+2)}=+\infty$
  - $\lim\limits_{x\to \pm\infty} f(x)=\lim\limits_{x\to \pm\infty}\dfrac{-x^2}{x^2}=-1$
- អាស៊ីមតូត គេមាន $\lim\limits_{x\to\pm\infty} f(x)=-1$ គេបានបន្ទាត់ $y=-1$ ជាអាស៊ីមតូតដេកនៃក្រាប ។

  $\lim\limits_{x\to -2} f(x)=\pm\infty$ និង $\lim\limits_{x\to -1} f(x)=\pm\infty$ គេបានសមីការ $x=-2$ និង $x=-1$ ជាអាស៊ីមតូតឈរទាំងពីរនៃក្រាប ។
- តារាងអថេរភាព

| $x$ | $-\infty$ | | $-5-2\sqrt{3}$ | | $-2$ | | $-5+2\sqrt{3}$ | | $-1$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $-$ | $0$ | $+$ | | $+$ | $0$ | $-$ | | $-$ | |
| $f(x)$ | $-1$ | $\searrow$ | $4\sqrt{3}-8$ | $\nearrow$ | $+\infty$ | $-\infty$ | $\nearrow$ | $-4\sqrt{3}-8$ | $\searrow$ | $+\infty$ | $\searrow$ $-1$ |

- សំណង់ក្រាប
  - ចំណុចប្រសព្វរវាងក្រាប $C$ និងអ័ក្ស $x'Ox$ គឺ


    $y=0 \iff -x^2-2x+3=0 \implies x=-3$ ឬ $x=1$ ។

    ដូចនេះ ក្រាបកាត់អ័ក្ស $x'Ox$ ត្រង់ចំណុច $(-3,0)$ និង $(1,0)$ ។
  - ចំណុចប្រសព្វរវាងក្រាប $C$ និងអ័ក្ស $y'Oy$ គឺ

    $x=0 \implies f(0)=\dfrac{3}{2}$ ។

    ដូចនេះ ក្រាបកាត់អ័ក្ស $y'Oy$ ត្រង់ចំណុច $\left(0,\dfrac{3}{2}\right)$ ។

- ចំណុចជំនួយបន្ថែម ៖
  ត្រង់ $x=-4 \Longrightarrow y=-\dfrac{5}{6}$
  ត្រង់ $x=-1.5 \Longrightarrow y=-15$
  ត្រង់ $x=2 \Longrightarrow y=-\dfrac{5}{12}$ ។




**3** គេឱ្យអនុគមន៍ $y=f(x)=\dfrac{mx^2+1}{x}$ មានក្រាប $(C)$ ។

ⓐ សិក្សាអថេរភាព និងសង់ក្រាប ចំពោះ $m=1$

- ចំពោះ $m=1$ គេបានអនុគមន៍ $f(x)=\dfrac{x^2+1}{x}=x+\dfrac{1}{x}$
- ដែនកំណត់ ៖ $D=\mathbb{R}\setminus\{0\}=(-\infty,0)\cup(0,+\infty)$
- ទិសដៅអថេរភាព ៖
  - ដេរីវេ ៖

$$f'(x)=1-\frac{1}{x^2}=\frac{x^2-1}{x^2}$$

$f'(x)=0 \iff x^2-1=0 \Longrightarrow x=-1$ ឬ $x=1$ ។
ដោយ $x^2>0$ ចំពោះគ្រប់ $x\in D$ សញ្ញានៃ $f'(x)$ យកតាម $x^2-1$ ៖
- $f'(x)>0$ ចំពោះ $x\in(-\infty,-1)\cup(1,+\infty)$
- $f'(x)<0$ ចំពោះ $x\in(-1,0)\cup(0,1)$


ដូចនេះ អនុគមន៍កើនលើចន្លោះ $(-\infty,-1)$ និង $(1,+\infty)$ ហើយចុះលើចន្លោះ $(-1,0)$ និង $(0,1)$ ។

  - បរមាធៀប ៖
    - អនុគមន៍មានអតិបរមាធៀបត្រង់ $x=-1$ គឺ $f(-1)=-2$
    - អនុគមន៍មានអប្បបរមាធៀបត្រង់ $x=1$ គឺ $f(1)=2$

- គណនាលីមីត ៖
  - $\lim\limits_{x\to-\infty} f(x) = -\infty$ និង $\lim\limits_{x\to+\infty} f(x) = +\infty$
  - $\lim\limits_{x\to0^-} f(x) = -\infty$ និង $\lim\limits_{x\to0^+} f(x) = +\infty$
- អាស៊ីមតូត ៖
  - ដោយ $\lim\limits_{x\to0} f(x) = \pm\infty$ នាំឱ្យអ័ក្ស $y'Oy\,(x=0)$ ជាអាស៊ីមតូតឈរ ។
  - ដោយ $f(x) = x + \dfrac{1}{x}$ ហើយ $\lim\limits_{x\to\pm\infty} \dfrac{1}{x} = 0$ នាំឱ្យបន្ទាត់ $(d) : y = x$ ជាអាស៊ីមតូតទ្រេតនៃក្រាប ។
- តារាងអថេរភាព ៖

| $x$ | $-\infty$ | | $-1$ | | $0$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | ↗ | $-2$ | ↘ | ‖ | $+\infty$ | ↘ | ↗ | $+\infty$ |
| | | | | | ‖ | | $2$ | | |

- សំណង់ក្រាប ៖
  - សមីការ $x^2+1=0$ គ្មានឫសក្នុង $\mathbb{R} \implies$ ក្រាបមិនកាត់អ័ក្ស $x'Ox$ ទេ ។
  - ចំណុចពិសេស ៖ $(-1,-2)$ ជាចំណុចអតិបរមាធៀប និង $(1,2)$ ជាចំណុចអប្បបរមាធៀប ។




(b) កំណត់តម្លៃ $m$ ដើម្បីឱ្យអនុគមន៍កើនក្នុងចន្លោះ $\left[\dfrac{1}{2},+\infty\right)$

- គេមាន $f(x) = \dfrac{mx^2+1}{x}$
- ដេរីវេ ៖ $f'(x) = \dfrac{(2mx)(x)-(mx^2+1)(1)}{x^2} = \dfrac{mx^2-1}{x^2}$
- ដើម្បីឱ្យអនុគមន៍កើនលើចន្លោះ $\left[\dfrac{1}{2},+\infty\right)$ លុះត្រាតែ $f'(x) \geq 0$ ចំពោះគ្រប់ $x \in \left[\dfrac{1}{2},+\infty\right)$

- ដោយ $x^2 > 0$ ចំពោះគ្រប់ $x \geq \dfrac{1}{2}$ គេបាន ៖

$$mx^2 - 1 \geq 0 \iff mx^2 \geq 1 \quad \forall x \in \left[\frac{1}{2}, +\infty\right)$$

- ចំពោះ $x \geq \dfrac{1}{2} \implies x^2 \geq \dfrac{1}{4}$
- ដើម្បីឱ្យ $mx^2 \geq 1$ ពិតចំពោះគ្រប់ $x^2 \geq \dfrac{1}{4}$ លុះត្រាតែ $m > 0$ និងតម្លៃអប្បបរមានៃ $mx^2$ លើចន្លោះនេះធំជាងឬស្មើ $1$ ៖

$$m \cdot \frac{1}{4} \geq 1 \iff m \geq 4$$

- ដូចនេះ តម្លៃ $m$ ដែលត្រូវរកគឺ $m \geq 4$ (ឬ $m \in [4, +\infty)$) ៕

◈ តើចំណុចនឹងដែលស្ថិតលើក្រាប $(C)$ ចំពោះគ្រប់ $m$ ឬទេ?

- ឧបមាថា $P(x_0, y_0)$ ជាចំណុចនឹងដែលស្ថិតលើក្រាប $(C)$ ចំពោះគ្រប់ $m$
- គេបានសមីការ ៖

$$y_0 = \frac{mx_0^2 + 1}{x_0} \iff x_0 y_0 = mx_0^2 + 1 \iff mx_0^2 + (1 - x_0 y_0) = 0$$

- សមីការនេះផ្ទៀងផ្ទាត់ចំពោះគ្រប់ $m \in \mathbb{R}$ លុះត្រាតែមេគុណនៃ $m$ និងតួថេរស្មើ $0$ ព្រមគ្នា ៖

$$\begin{cases} x_0^2 = 0 \\ 1 - x_0 y_0 = 0 \end{cases} \implies \begin{cases} x_0 = 0 \\ 1 - 0 \cdot y_0 = 0 \implies 1 = 0 \quad (\text{មិនពិត}) \end{cases}$$

- ម្យ៉ាងទៀត $x_0 = 0$ មិនស្ថិតក្នុងដែនកំណត់នៃអនុគមន៍ឡើយ ៕
- ដូចនេះ គ្មានចំណុចនឹងដែលស្ថិតលើក្រាប $(C)$ ចំពោះគ្រប់ $m$ ឡើយ ៕

◈ ដោយប្រើក្រាប $(C)$ កំណត់តម្លៃ $a$ ដើម្បីឱ្យ $x^2 - ax + 1 > 0$ ចំពោះគ្រប់ $x > 0$

- វិសមីការ $x^2 - ax + 1 > 0$ ចំពោះគ្រប់ $x > 0$
- ដោយ $x > 0$ ចែកអង្គទាំងពីរនៃវិសមីការនឹង $x$ គេបាន ៖

$$\frac{x^2 + 1}{x} - a > 0 \iff \frac{x^2 + 1}{x} > a \iff f(x) > a$$

- តាមក្រាប $(C)$ នៃអនុគមន៍ $f(x) = \dfrac{x^2 + 1}{x}$ (ចំពោះ $m = 1$) នៅលើចន្លោះ $(0, +\infty)$ អនុគមន៍មានតម្លៃអប្បបរមាត្រង់ $x = 1$ គឺ $f(1) = 2$
- មានន័យថា $f(x) \geq 2$ ចំពោះគ្រប់ $x > 0$

- ដូចនេះ ដើម្បីឱ្យ $f(x) > a$ ចំពោះគ្រប់ $x > 0$ លុះត្រាតែ $a$ តូចជាងតម្លៃអប្បបរមានៃ $f(x)$ លើចន្លោះ $(0, +\infty)$ ៖

  នោះ $a < 2$
- ដូចនេះ តម្លៃ $a$ ដែលត្រូវរកគឺ $a < 2$ (ឬ $a \in (-\infty, 2)$) ។

## ក្រម្ងចលំហាត់បន្ថែម

**1** រកអាស៊ីមតូតនៃក្រាបតាងអនុគមន៍ខាងក្រោម

ⓐ $y = x + 1 + \dfrac{2}{x-1}$ ⓑ $y = \dfrac{x^2+4x+1}{x+2}$ ⓒ $y = \dfrac{x^2+3x+1}{x^2-1}$

**2** គេឱ្យអនុគមន៍ $f$ កំណត់ចំពោះ $x \neq 2$ ដោយ $y = \dfrac{2x^2+x-1}{x-2}$ និងមានក្រាប $(C)$

ⓐ រកចំនួនពិត $a, b, c$ ដែលគ្រប់ $x \neq 2$ គេបាន $f(x) = ax + b + \dfrac{c}{x-2}$

ⓑ រកសមីការអាស៊ីមតូតឈរ និងទ្រេតនៃក្រាប $(C)$

ⓒ សិក្សាទីតាំងធៀបរវាងអាស៊ីមតូតទ្រេត និងក្រាប $(C)$ ។

**3** គេឱ្យអនុគមន៍ $f$ កំនត់លើ $(-\infty, 2) \cup (2, +\infty)$ ដោយ $f(x) = \dfrac{x^2-4x+8}{x-2}$ មានក្រាប $(C)$ ។

ⓐ រកចំនួនពិត $a, b, c$ ដែលគ្រប់ $x \neq 2$ គេបាន $f(x) = ax + b + \dfrac{c}{x-2}$

ⓑ រកសមីការអាស៊ីមតូតឈរ និងទ្រេតនៃក្រាប $(C)$

ⓒ សិក្សាអថេរភាពនៃ$f$ និងសង់ក្រាប $(C)$ ។

**4** គេមានអនុគមន៍ $f(x) = \dfrac{x^2-x-3}{x+1}$ និងមានក្រាប $(C)$ ។

ⓐ រកដែនកំណត់ $f$

ⓑ បង្ហាញថា $f(x) = x - 2 - \dfrac{1}{x+1}$

ⓒ បង្ហាញថា សមីការ $y = x - 2$ ជាអាស៊ីមតូតទ្រេតនៃក្រាប ។

ⓓ សិក្សាអថេរភាព និងសង់ក្រាប $(C)$ ។

**5** គេឱ្យ $f$ ជាអនុគមន៍កំណត់ដោយ $f(x) = \dfrac{x^2-6x}{x^2-6x+5}$ មានក្រាប $(C)$ ស្ថិតក្នុងតម្រុយ $(O, \vec{i}, \vec{j})$ ។

ⓐ គណនាលិមីតចុងដែនកំណត់ រួចទាញរកសមីការអាស៊ីមតូត ។

ⓑ គណនា $f'(x)$ រួចសិក្សាសញ្ញារបស់វា ។ ទាញថា $f$ មានអប្បរមាធៀបមួយ រួចគណនាតម្លៃអប្បបរមាធៀបនោះ ។ សង់តារាងអថេរភាពនៃ $f$ ។

ⓒ សង់ក្រាប $(C)$ និងអាស៊ីមតូត ។

**6** អនុគមន៍ $f$ កំណត់ចំពោះ$x \neq 2$ ដោយ $f(x) = \dfrac{qx^2+bx+c}{(x-2)^2}$ ហើយមានក្រាប $(c)$ ។

ⓐ រក $a, b, c$ ដោយដឹងថា ក្រាប$(c)$ កាត់អាប់ស៊ីសត្រង់ $x = 1$ និង $x = -3$ ហើយមានអាស៊ីមតូតដេក $y = 1$ ។

(b) រកសមីការអាស៊ីមតូតឈរនៃក្រាប និងសង់តារាងអថេរភាពនៃ $f$ ដែលកំណត់បានក្នុងសំណួរទី១។

(c) សង់ក្រាប $(C)$ ។

**7** (a) សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ $y = \dfrac{x^2 - 4x + 8}{x - 2}$

(b) សិក្សាតាងតម្លៃ $m$ អត្ថិភាព និងសញ្ញានៃឫសសមីការ $x^2 - (m+4)x + 2m + 8 = 0$ ដោយប្រើក្រាបតាង$y$

**8** កំណត់តម្លៃ $a$ ដើម្បីឱ្យអនុគមន៍ $y = \dfrac{x^2 - 2ax + 3a^2}{x - 2a}$ កើនលើចន្លោះ $(1, +\infty)$ ។

**9** គេឱ្យអនុគមន៍ $y = \dfrac{mx^2 + 3mx + 2m + 1}{x + 2}$

(a) ស្រាយបញ្ជាក់ថា អាស៊ីមតូតទ្រេតកាត់តាមចំណុចនឹងមួយ ចំពោះគ្រប់ប៉ារ៉ាម៉ែត្រ $m$ ដែលត្រូវកំណត់កូអរដោនេ។

(b) រកតម្លៃ $m$ ដើម្បីឱ្យបន្ទាត់ $y = m$ ប៉ះក្រាប $(C)$

(c) សិក្សាអថេរភាព និងសង់ក្រាប ចំពោះ $m = -1$ ។

**10** គេឱ្យអនុគមន៍ $y = \dfrac{x^2 + 2(m+1)x + 2}{x + 1}$ ។

(a) ចំពោះ $m = 0$ សិក្សាអថេរភាព និងសង់ក្រាប$(C)$ រួចកំណត់តម្លៃ $a$ ដើម្បីឱ្យក្រាប $(c)$ ប៉ះនឹងបន្ទាត់ $y = -x + a$

(b) រកតម្លៃ $m$ ដើម្បីឱ្យអនុគមន៍ កើនលើចន្លោះ $[0, +\infty)$

## ចម្លើយកម្រងលំហាត់បន្ថែម

**1** រកអាស៊ីមតូតនៃក្រាបតាងអនុគមន៍ខាងក្រោម

(a) $y = x + 1 + \dfrac{2}{x - 1}$

- ដែនកំណត់ ៖ $D = \mathbb{R} \setminus \{1\}$
- អាស៊ីមតូតឈរ ៖ ដោយ $\lim\limits_{x \to 1^-} y = -\infty$ និង $\lim\limits_{x \to 1^+} y = +\infty$ នាំឱ្យបន្ទាត់ $x = 1$ ជាអាស៊ីមតូតឈរនៃក្រាប ។
- អាស៊ីមតូតទ្រេត ៖ ដោយ $y = (x+1) + \dfrac{2}{x-1}$ ហើយ $\lim\limits_{x \to \pm\infty} \dfrac{2}{x-1} = 0$ នាំឱ្យបន្ទាត់ $y = x + 1$ ជាអាស៊ីមតូតទ្រេតនៃក្រាប ។

(b) $y = \dfrac{x^2 + 4x + 1}{x + 2}$

- ដែនកំណត់ ៖ $D = \mathbb{R} \setminus \{-2\}$
- បំបែកអនុគមន៍ជាទម្រង់ ៖

$$y = \frac{(x+2)^2 - 3}{x + 2} = x + 2 - \frac{3}{x + 2}$$

- អាស៊ីមតូតឈរ ៖ ដោយ $\lim\limits_{x \to -2^-} y = +\infty$ និង $\lim\limits_{x \to -2^+} y = -\infty$

នាំឱ្យបន្ទាត់ $x=-2$ ជាអាស៊ីមតូតឈរនៃក្រាប ។

- អាស៊ីមតូតទ្រេត ៖ ដោយ $\lim\limits_{x\to\pm\infty}[y-(x+2)]=\lim\limits_{x\to\pm\infty}\left(-\dfrac{3}{x+2}\right)=0$

  នាំឱ្យបន្ទាត់ $y=x+2$ ជាអាស៊ីមតូតទ្រេតនៃក្រាប ។

◈ c $y=\dfrac{x^2+3x+1}{x^2-1}$

- ដែនកំណត់ ៖ $D=\mathbb{R}\setminus\{-1,1\}$
- អាស៊ីមតូតឈរ ៖ ដោយ $\lim\limits_{x\to-1}y=\pm\infty$ និង $\lim\limits_{x\to1}y=\pm\infty$

  នាំឱ្យបន្ទាត់ $x=-1$ និង $x=1$ ជាអាស៊ីមតូតឈរទាំងពីរនៃក្រាប ។
- អាស៊ីមតូតដេក ៖ ដោយ $\lim\limits_{x\to\pm\infty}y=\lim\limits_{x\to\pm\infty}\dfrac{x^2\left(1+\dfrac{3}{x}+\dfrac{1}{x^2}\right)}{x^2\left(1-\dfrac{1}{x^2}\right)}=1$

  នាំឱ្យបន្ទាត់ $y=1$ ជាអាស៊ីមតូតដេកនៃក្រាប ។

**2** គេឱ្យអនុគមន៍ $f$ កំណត់ចំពោះ $x\neq2$ ដោយ $y=\dfrac{2x^2+x-1}{x-2}$ និងមានក្រាប $(C)$

◈ a រកចំនួនពិត $a,b,c$ ៖

- គេមាន $f(x)=\dfrac{2x^2+x-1}{x-2}$
- ដោយធ្វើប្រមាណវិធីចែកពហុធា $2x^2+x-1$ នឹង $x-2$ ៖

  $2x^2+x-1=(2x+5)(x-2)+9$

  គេបាន ៖ $f(x)=\dfrac{(2x+5)(x-2)+9}{x-2}=2x+5+\dfrac{9}{x-2}$
- ផ្ទៀងផ្ទាត់ជាមួយទម្រង់ $f(x)=ax+b+\dfrac{c}{x-2}$

  គេទាញបាន ៖

  $a=2,\quad b=5,\quad c=9$

◈ b រកសមីការអាស៊ីមតូតឈរ និងទ្រេតនៃក្រាប $(C)$ ៖

- អាស៊ីមតូតឈរ ៖ ដោយ $\lim\limits_{x\to2^-}f(x)=-\infty$ និង $\lim\limits_{x\to2^+}f(x)=+\infty$

  នាំឱ្យបន្ទាត់ $x=2$ ជាអាស៊ីមតូតឈរនៃក្រាប $(C)$ ។
- អាស៊ីមតូតទ្រេត ៖ ដោយ $f(x)=2x+5+\dfrac{9}{x-2}$ ហើយ $\lim\limits_{x\to\pm\infty}\dfrac{9}{x-2}=0$

  នាំឱ្យបន្ទាត់ $(d):y=2x+5$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ។

◈ c សិក្សាទីតាំងធៀបរវាងអាស៊ីមតូតទ្រេត និងក្រាប $(C)$ ៖

- ពិនិត្យផលដក $f(x)-y=\dfrac{9}{x-2}$ លើ $D=\mathbb{R}\setminus\{2\}$ ៖
  - ចំពោះ $x\in(2,+\infty)\implies x-2>0\implies f(x)-y>0\iff f(x)>y$

    ដូចនេះ ក្រាប $(C)$ ស្ថិតនៅខាងលើអាស៊ីមតូតទ្រេត $(d)$ លើចន្លោះ $(2,+\infty)$ ។
  - ចំពោះ $x\in(-\infty,2)\implies x-2<0\implies f(x)-y<0\iff f(x)<y$

    ដូចនេះ ក្រាប $(C)$ ស្ថិតនៅខាងក្រោមអាស៊ីមតូតទ្រេត $(d)$ លើចន្លោះ $(-\infty,2)$ ។

**3** គេឱ្យអនុគមន៍ $f$ កំនត់លើ $(-\infty,2)\cup(2,+\infty)$ ដោយ $f(x)=\dfrac{x^2-4x+8}{x-2}$ មានក្រាប $(C)$ ។

**a** រកចំនួនពិត $a,b,c$ ៖

- គេមាន $f(x)=\dfrac{x^2-4x+8}{x-2}$
- ដោយធ្វើប្រមាណវិធីចែកពហុធា $x^2-4x+8$ និង $x-2$ ៖

$$x^2-4x+8=(x-2)(x-2)+4$$

- គេបាន ៖ $f(x)=\dfrac{(x-2)^2+4}{x-2}=x-2+\dfrac{4}{x-2}$
- ផ្ទៀងផ្ទាត់ជាមួយទម្រង់ $f(x)=ax+b+\dfrac{c}{x-2}$ គេទាញបាន ៖

$$a=1,\quad b=-2,\quad c=4$$

**b** រកសមីការអាស៊ីមតូតឈរ និងទ្រេតនៃក្រាប $(C)$ ៖

- អាស៊ីមតូតឈរ ៖ ដោយ $\lim\limits_{x\to2^-}f(x)=-\infty$ និង $\lim\limits_{x\to2^+}f(x)=+\infty$
  នាំឱ្យបន្ទាត់ $x=2$ ជាអាស៊ីមតូតឈរនៃក្រាប $(C)$ ។
- អាស៊ីមតូតទ្រេត ៖ ដោយ $f(x)=x-2+\dfrac{4}{x-2}$ ហើយ $\lim\limits_{x\to\pm\infty}\dfrac{4}{x-2}=0$
  នាំឱ្យបន្ទាត់ $(d):y=x-2$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ។

**c** សិក្សាអថេរភាពនៃ $f$ និងសង់ក្រាប $(C)$ ៖

- ដែនកំណត់ ៖ $D=(-\infty,2)\cup(2,+\infty)$
- ទិសដៅអថេរភាព ៖
  - ដេរីវេ ៖

$$f'(x)=1-\frac{4}{(x-2)^2}=\frac{(x-2)^2-4}{(x-2)^2}=\frac{x^2-4x}{(x-2)^2}=\frac{x(x-4)}{(x-2)^2}$$

$f'(x)=0\iff x(x-4)=0\implies x=0$ ឬ $x=4$ ។
ដោយ $(x-2)^2>0$ ចំពោះគ្រប់ $x\in D$ សញ្ញានៃ $f'(x)$ យកតាម $x(x-4)$ ៖

- $f'(x)>0$ ចំពោះ $x\in(-\infty,0)\cup(4,+\infty)$
- $f'(x)<0$ ចំពោះ $x\in(0,2)\cup(2,4)$

ដូចនេះ អនុគមន៍កើនលើចន្លោះ $(-\infty,0)$ និង $(4,+\infty)$ ហើយចុះលើចន្លោះ $(0,2)$ និង $(2,4)$ ។


  - បរមាធៀប ៖
    - អនុគមន៍មានអតិបរមាធៀបត្រង់ $x=0$ គឺ $f(0)=-4$
    - អនុគមន៍មានអប្បបរមាធៀបត្រង់ $x=4$ គឺ $f(4)=4$
  - គណនាលីមីត ៖

- $\lim\limits_{x\to-\infty} f(x) = -\infty$ និង $\lim\limits_{x\to+\infty} f(x) = +\infty$
- $\lim\limits_{x\to2^-} f(x) = -\infty$ និង $\lim\limits_{x\to2^+} f(x) = +\infty$

- តារាងអថេរភាព ៖

| $x$ | $-\infty$ | | $0$ | | $2$ | | $4$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | ↗ | $-4$ | ↘ | $+\infty$ ‖ $-\infty$ | ↘ | $4$ | ↗ | $+\infty$ |

- សំណង់ក្រាប ៖
  - ចំណុចប្រសព្វរវាងក្រាប $(C)$ និងអ័ក្ស $x'Ox$ ៖
    $y = 0 \iff x^2 - 4x + 8 = 0$ មាន $\Delta' = 4 - 8 = -4 < 0 \implies$ ក្រាបមិនកាត់អ័ក្ស $x'Ox$ ទេ ៕
  - ចំណុចប្រសព្វរវាងក្រាប $(C)$ និងអ័ក្ស $y'Oy$ ៖
    $x = 0 \implies y = -4$ ៕
  - ចំណុចពិសេស ៖ $(0,-4)$ ជាចំណុចអតិបរមាធៀប និង $(4,4)$ ជាចំណុចអប្បបរមាធៀប ៕




**4** គេមានអនុគមន៍ $f(x) = \dfrac{x^2 - x - 3}{x + 1}$ និងមានក្រាប $(C)$ ។

**a** រកដែនកំណត់ $f$ ៖

អនុគមន៍ $f(x)$ មានន័យកាលណា ភាគបែង $x + 1 \neq 0 \iff x \neq -1$ ដូចនេះ ដែនកំណត់នៃអនុគមន៍គឺ $D = \mathbb{R} \setminus \{-1\} = (-\infty,-1) \cup (-1,+\infty)$ ៕

**b** បង្ហាញថា $f(x) = x - 2 - \dfrac{1}{x+1}$ ៖

- គេមាន ៖

$$x - 2 - \frac{1}{x+1} = \frac{(x-2)(x+1) - 1}{x+1} = \frac{x^2 - x - 2 - 1}{x+1} = \frac{x^2 - x - 3}{x+1} = f(x)$$

○ ដូចនេះ $f(x) = x - 2 - \dfrac{1}{x+1}$ ពិតប្រាកដមែន ៕

ⓒ បង្ហាញថា សមីការ $y = x - 2$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ៖

○ គណនាលីមីតផលដក ៖

$$\lim_{x\to\pm\infty}[f(x) - (x-2)] = \lim_{x\to\pm\infty}\left(-\frac{1}{x+1}\right) = 0$$

ដូចនេះ បន្ទាត់ $y = x - 2$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ខាង $+\infty$ និង $-\infty$ ៕

ⓓ សិក្សាអថេរភាព និងសង់ក្រាប $(C)$ ៖

○ ទិសដៅអថេរភាព ៖

- ដេរីវេ ៖

$$f'(x) = (x-2)' - \left(\frac{1}{x+1}\right)' = 1 + \frac{1}{(x+1)^2} = \frac{(x+1)^2+1}{(x+1)^2} = \frac{x^2+2x+2}{(x+1)^2}$$

ដោយ $(x+1)^2 + 1 > 0$ និង $(x+1)^2 > 0$ ចំពោះគ្រប់ $x \in D$ នាំឱ្យ $f'(x) > 0$ ចំពោះគ្រប់ $x \in D$ ៕

ដូចនេះ អនុគមន៍ $f$ ជាអនុគមន៍កើនដាច់ខាតលើចន្លោះ $(-\infty, -1)$ និង $(-1, +\infty)$ ហើយគ្មានបរមាធៀបឡើយ ៕

- គណនាលីមីត និងអាស៊ីមតូតឈរ ៖

○ $\lim\limits_{x\to-\infty} f(x) = -\infty$ និង $\lim\limits_{x\to+\infty} f(x) = +\infty$

○ $\lim\limits_{x\to-1^-} f(x) = \lim\limits_{x\to-1^-}\left(x - 2 - \dfrac{1}{x+1}\right) = +\infty$

○ $\lim\limits_{x\to-1^+} f(x) = \lim\limits_{x\to-1^+}\left(x - 2 - \dfrac{1}{x+1}\right) = -\infty$

ដោយ $\lim\limits_{x\to-1} f(x) = \pm\infty$ នាំឱ្យបន្ទាត់ $x = -1$ ជាអាស៊ីមតូតឈរនៃក្រាប $(C)$ ៕

- តារាងអថេរភាព ៖

| $x$ | $-\infty$ | | $-1$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $+$ | ‖ | $+$ | |
| $f(x)$ | $-\infty$ | ↗ | $+\infty$ ‖ $-\infty$ | ↗ | $+\infty$ |

○ សំណង់ក្រាប ៖


- ចំណុចប្រសព្វរវាងក្រាប $(C)$ និងអ័ក្ស $y'Oy$ ៖

$x = 0 \implies f(0) = -3$ នាំឱ្យក្រាបកាត់អ័ក្ស $y'Oy$ ត្រង់ $(0, -3)$ ៕

- ចំណុចប្រសព្វរវាងក្រាប $(C)$ និងអ័ក្ស $x'Ox$ ៖

  $y = 0 \iff x^2 - x - 3 = 0 \implies x = \dfrac{1-\sqrt{13}}{2} \approx -1.30$ ឬ $x = \dfrac{1+\sqrt{13}}{2} \approx 2.30$ ។

- ចំណុចជំនួយបន្ថែម ៖ $(-2,-3), (-3,-4.5), (1,-1.5), (2,-0.33)$ ។




**5** គេឱ្យ $f$ ជាអនុគមន៍កំណត់ដោយ $f(x) = \dfrac{x^2-6x}{x^2-6x+5}$ មានក្រាប $(C)$ ស្ថិតក្នុងតម្រុយ $(O,\vec{i},\vec{j})$ ។

- **a** គណនាលីមីតចុងដែនកំណត់ រួចទាញរកសមីការអាស៊ីមតូត។
- **b** គណនា $f'(x)$ រួចសិក្សាសញ្ញារបស់វា។ ទាញថា $f$ មានអប្បរមាធៀបមួយ រួចគណនាតម្លៃអប្បបរមាធៀបនោះ។ សង់តារាងអថេរភាពនៃ $f$ ។
- **c** សង់ក្រាប $(C)$ និងអាស៊ីមតូត។

**6** អនុគមន៍ $f$ កំណត់ចំពោះ $x \neq 2$ ដោយ $f(x) = \dfrac{qx^2+bx+c}{(x-2)^2}$ ហើយមានក្រាប $(c)$ ។

- **a** គណនាលីមីតចុងដែនកំណត់ និងទាញរកសមីការអាស៊ីមតូត ៖
  - ដែនកំណត់ ៖ ភាគបែង $x^2-6x+5=0 \iff (x-1)(x-5)=0 \implies x=1$ ឬ $x=5$ ។

    នាំឱ្យ $D = \mathbb{R}\setminus\{1,5\} = (-\infty,1)\cup(1,5)\cup(5,+\infty)$ ។
  - លីមីតត្រង់ $\pm\infty$ ៖

$$\lim_{x\to-\infty} f(x) = \lim_{x\to-\infty} \frac{x^2}{x^2} = 1 \quad \text{និង} \quad \lim_{x\to+\infty} f(x) = \lim_{x\to+\infty} \frac{x^2}{x^2} = 1$$

  នាំឱ្យបន្ទាត់ $y=1$ ជាអាស៊ីមតូតដេកនៃក្រាប $(C)$ ខាង $-\infty$ និង $+\infty$ ។

- លីមីតត្រង់ $x=1$ ៖

$$\lim_{x\to 1^-} f(x)=\lim_{x\to 1^-}\frac{x^2-6x}{(x-1)(x-5)}=\frac{-5}{(-0)(-4)}=-\infty$$

$$\lim_{x\to 1^+} f(x)=\lim_{x\to 1^+}\frac{x^2-6x}{(x-1)(x-5)}=\frac{-5}{(+0)(-4)}=+\infty$$

នាំឱ្យបន្ទាត់ $x=1$ ជាអាស៊ីមតូតឈរនៃក្រាប $(C)$ ។

- លីមីតត្រង់ $x=5$ ៖

$$\lim_{x\to 5^-} f(x)=\lim_{x\to 5^-}\frac{x^2-6x}{(x-1)(x-5)}=\frac{-5}{(4)(-0)}=+\infty$$

$$\lim_{x\to 5^+} f(x)=\lim_{x\to 5^+}\frac{x^2-6x}{(x-1)(x-5)}=\frac{-5}{(4)(+0)}=-\infty$$

នាំឱ្យបន្ទាត់ $x=5$ ជាអាស៊ីមតូតឈរនៃក្រាប $(C)$ ។

(b) គណនា $f'(x)$ សិក្សាសញ្ញា ទាញរកអប្បបរមាធៀប និងសង់តារាងអថេរភាព ៖

- គណនា $f'(x)$ ៖

$$f'(x)=\frac{(2x-6)(x^2-6x+5)-(2x-6)(x^2-6x)}{(x^2-6x+5)^2}=\frac{5(2x-6)}{(x^2-6x+5)^2}=\frac{10(x-3)}{(x^2-6x+5)^2}$$

- សិក្សាសញ្ញានៃ $f'(x)$ ៖ ដោយ $(x^2-6x+5)^2>0$ ចំពោះគ្រប់ $x\in D$ សញ្ញានៃ $f'(x)$ យកតាមសញ្ញានៃ $(x-3)$ ៖

  - $f'(x)=0 \iff x-3=0 \implies x=3$
  - $f'(x)<0$ ចំពោះ $x\in(-\infty,1)\cup(1,3)$
  - $f'(x)>0$ ចំពោះ $x\in(3,5)\cup(5,+\infty)$

- អប្បបរមាធៀប ៖ ត្រង់ $x=3$ ដេរីវេ $f'(x)$ ប្តូរសញ្ញាពីដក $(-)$ ទៅបូក $(+)$ នាំឱ្យអនុគមន៍ $f$ មានអប្បបរមាធៀបមួយត្រង់ $x=3$ គឺ ៖

$$f(3)=\frac{3^2-6(3)}{3^2-6(3)+5}=\frac{9-18}{9-18+5}=\frac{-9}{-4}=\frac{9}{4}=2.25$$


- តារាងអថេរភាព ៖

| $x$ | $-\infty$ | | $1$ | | $3$ | | $5$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $-$ | $\|\|$ | $-$ | $0$ | $+$ | $\|\|$ | $+$ | |
| $f(x)$ | $1$ | $\searrow$ | $\|\|$ | $+\infty$ | $\frac{9}{4}$ | $\nearrow$ | $\|\|$ | $1$ | |
| | | $-\infty$ | $\|\|$ | | | $+\infty$ | $\|\|$ | $-\infty$ | |

ⓒ សង់ក្រាប $(C)$ និងអាស៊ីមតូត ៖

- ចំណុចប្រសព្វរវាងក្រាប $(C)$ និងអ័ក្ស $x'Ox$ ៖

  $y=0 \iff x^2-6x=0 \implies x=0$ ឬ $x=6$ នាំឱ្យក្រាបកាត់អ័ក្ស $x'Ox$ ត្រង់ $(0,0)$ និង $(6,0)$ ៕
- ចំណុចអប្បបរមាធៀប ៖ $\left(3,\frac{9}{4}\right)$ ៕




**7** ⓐ សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ $y=f(x)=\dfrac{x^2-4x+8}{x-2}$

- ដែនកំណត់ ៖ $D=\mathbb{R}\setminus\{2\}=(-\infty,2)\cup(2,+\infty)$
- ទិសដៅអថេរភាព ៖
  - ដេរីវេ ៖

$$f'(x)=1-\frac{4}{(x-2)^2}=\frac{(x-2)^2-4}{(x-2)^2}=\frac{x^2-4x}{(x-2)^2}=\frac{x(x-4)}{(x-2)^2}$$

$f'(x)=0 \iff x(x-4)=0 \implies x=0$ ឬ $x=4$ ៕

ដោយ $(x-2)^2>0$ ចំពោះគ្រប់ $x\in D$ សញ្ញានៃ $f'(x)$ យកតាម $x(x-4)$ ៖

- $f'(x)>0$ ចំពោះ $x\in(-\infty,0)\cup(4,+\infty)$
- $f'(x)<0$ ចំពោះ $x\in(0,2)\cup(2,4)$


ដូចនេះ អនុគមន៍កើនលើចន្លោះ $(-\infty,0)$ និង $(4,+\infty)$ ហើយចុះលើចន្លោះ $(0,2)$ និង

$(2,4)$ ។

- បរមាធៀប ៖
  - អនុគមន៍មានអតិបរមាធៀបត្រង់ $x=0$ គឺ $f(0)=-4$
  - អនុគមន៍មានអប្បបរមាធៀបត្រង់ $x=4$ គឺ $f(4)=4$
- គណនាលីមីត និងអាស៊ីមតូត ៖
  - $\lim\limits_{x\to-\infty} f(x)=-\infty$ និង $\lim\limits_{x\to+\infty} f(x)=+\infty$
  - $\lim\limits_{x\to2^-} f(x)=-\infty$ និង $\lim\limits_{x\to2^+} f(x)=+\infty \implies$ បន្ទាត់ $x=2$ ជាអាស៊ីមតូតឈរ ។
  - $f(x)=x-2+\dfrac{4}{x-2}$ ដោយ $\lim\limits_{x\to\pm\infty}\dfrac{4}{x-2}=0 \implies$ បន្ទាត់ $(d):y=x-2$ ជាអាស៊ីមតូតទ្រេត ។
- តារាងអថេរភាព ៖

| $x$ | $-\infty$ | | $0$ | | $2$ | | $4$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | ↗ | $-4$ | ↘ | ‖ $+\infty$ | ↘ | $4$ | ↗ | $+\infty$ |

- សំណង់ក្រាប $(C)$ ៖
  - ចំណុចប្រសព្វរវាងក្រាប $(C)$ និងអ័ក្ស $y'Oy$ គឺ $(0,-4)$ (ជាចំណុចអតិបរមាធៀប) ។
  - ក្រាបមិនកាត់អ័ក្ស $x'Ox$ ទេ ព្រោះសមីការ $x^2-4x+8=0$ គ្មានឫសក្នុង $\mathbb{R}$ ។
  - ចំណុចអប្បបរមាធៀប គឺ $(4,4)$ ។




ⓑ សិក្សាតាមតម្លៃ $m$ អត្ថិភាព និងសញ្ញានៃឫសសមីការ $x^2-(m+4)x+2m+8=0$ ដោយប្រើក្រាប $(C)$

- គេមានសមីការ ៖

$x^2-(m+4)x+2m+8=0 \iff x^2-4x+8-m(x-2)=0$

$\iff x^2-4x+8=m(x-2)$

- បើ $x=2 \implies 2^2-4(2)+8=m(0) \iff 4=0$ (មិនពិត) នាំឱ្យ $x=2$ មិនមែនជាឫសនៃសមីការទេ ចំពោះគ្រប់ $m$ ។
- ចំពោះ $x\neq 2$ សមីការសមមូលនឹង ៖

$$\frac{x^2-4x+8}{x-2}=m \iff f(x)=m$$

- ចំនួន និងសញ្ញានៃឫសសមីការ គឺជាអាប់ស៊ីស $(x)$ នៃចំណុចប្រសព្វរវាងក្រាប $(C)$ និងបន្ទាត់ដេក $(d_m): y=m$ ។
- តាមក្រាប $(C)$ គេទាញបានការពិភាក្សាតាមតម្លៃ $m$ ដូចខាងក្រោម ៖

1. ចំពោះ $m<-4$ ៖ បន្ទាត់ $y=m$ កាត់ក្រាប $(C)$ ត្រង់ពីរចំណុចដែលមានអាប់ស៊ីស $x_1<0$ និង $0<x_2<2$ ។
   $\implies$ សមីការមានឫសពិតពីរផ្សេងគ្នា មានសញ្ញាផ្ទុយគ្នា $(x_1<0<x_2)$ ។
2. ចំពោះ $m=-4$ ៖ បន្ទាត់ $y=-4$ ប៉ះក្រាប $(C)$ ត្រង់ចំណុចអតិបរមា $(0,-4)$ ។
   $\implies$ សមីការមានឫសឌុប $x_1=x_2=0$ ។
3. ចំពោះ $-4<m<4$ ៖ បន្ទាត់ $y=m$ មិនកាត់ក្រាប $(C)$ ឡើយ ។
   $\implies$ សមីការគ្មានឫសពិត ។
4. ចំពោះ $m=4$ ៖ បន្ទាត់ $y=4$ ប៉ះក្រាប $(C)$ ត្រង់ចំណុចអប្បបរមា $(4,4)$ ។
   $\implies$ សមីការមានឫសឌុបវិជ្ជមាន $x_1=x_2=4>0$ ។
5. ចំពោះ $m>4$ ៖ បន្ទាត់ $y=m$ កាត់ក្រាប $(C)$ ត្រង់ពីរចំណុចដែលមានអាប់ស៊ីស $2<x_1<4$ និង $x_2>4$ ។
   $\implies$ សមីការមានឫសពិតវិជ្ជមានពីរផ្សេងគ្នា $(0<2<x_1<x_2)$ ។

**8** កំណត់តម្លៃ $a$ ដើម្បីឱ្យអនុគមន៍ $y=\dfrac{x^2-2ax+3a^2}{x-2a}$ កើនលើចន្លោះ $(1,+\infty)$

1. លក្ខខណ្ឌនៃដែនកំណត់ ៖
   - អនុគមន៍ $f(x)$ មានន័យកាលណា ភាគបែង $x-2a\neq 0 \iff x\neq 2a$
   - ដើម្បីឱ្យអនុគមន៍ $f(x)$ កើន និងជាប់លើចន្លោះ $(1,+\infty)$ លុះត្រាតែចំណុចមិនកំណត់ $x=2a$ មិនស្ថិតនៅក្នុងចន្លោះ $(1,+\infty)$ ឡើយ ៖

$$2a\leq 1 \implies a\leq \frac{1}{2} \quad \text{(លក្ខខណ្ឌទី១)}$$

2. គណនាដេរីវេ ៖
   - បំបែកអនុគមន៍ជាទម្រង់ ៖ $f(x)=x+\dfrac{3a^2}{x-2a}$

- ដេរីវេនៃអនុគមន៍គឺ ៖

$$f'(x) = 1 - \frac{3a^2}{(x-2a)^2} = \frac{(x-2a)^2 - 3a^2}{(x-2a)^2}$$

3. លក្ខខណ្ឌដើម្បីឱ្យអនុគមន៍កើនលើចន្លោះ $(1,+\infty)$ ៖
   - អនុគមន៍ $f(x)$ កើនលើ $(1,+\infty)$ លុះត្រាតែ $f'(x) \geq 0$ ចំពោះគ្រប់ $x \in (1,+\infty)$
   - ដោយ $(x-2a)^2 > 0$ ចំពោះគ្រប់ $x > 1 \geq 2a$ គេបាន ៖

$$(x-2a)^2 - 3a^2 \geq 0 \iff (x-2a)^2 \geq 3a^2 \iff |x-2a| \geq \sqrt{3}|a| \quad \forall x > 1$$

   - ដោយ $x > 1 \geq 2a \implies x - 2a > 0$ នាំឱ្យ $|x-2a| = x - 2a$ ៖

$$x - 2a \geq \sqrt{3}|a| \iff x \geq 2a + \sqrt{3}|a| \quad \forall x \in (1,+\infty)$$

   - ដើម្បីឱ្យវិសមភាពនេះពិតចំពោះគ្រប់ $x > 1$ លុះត្រាតែ ៖

$$2a + \sqrt{3}|a| \leq 1 \quad \text{(លក្ខខណ្ឌទី២)}$$

4. ដោះស្រាយវិសមភាព $2a + \sqrt{3}|a| \leq 1$ ៖
   - ករណីទី១ $(0 \leq a \leq \frac{1}{2})$ ៖ គេបាន $|a| = a$

$$2a + \sqrt{3}a \leq 1 \iff a(2+\sqrt{3}) \leq 1 \iff a \leq \frac{1}{2+\sqrt{3}} = 2 - \sqrt{3}$$

     ដោយ $2 - \sqrt{3} \approx 0.268 \leq \frac{1}{2}$ គេបានចន្លោះចម្លើយ ៖ $0 \leq a \leq 2 - \sqrt{3}$ ៕
   - ករណីទី២ $(a < 0)$ ៖ គេបាន $|a| = -a$

$$2a - \sqrt{3}a \leq 1 \iff a(2-\sqrt{3}) \leq 1 \iff a \leq \frac{1}{2-\sqrt{3}} = 2 + \sqrt{3}$$

     ដោយ $2 + \sqrt{3} \approx 3.732 > 0$ វិសមភាព $a \leq 2 + \sqrt{3}$ ពិតជានិច្ចចំពោះគ្រប់ $a < 0$ ៕
5. សន្និដ្ឋាន ៖
   - ផ្គុំលទ្ធផលពីករណីទាំងពីរ គេទាញបាន ៖

$$a \leq 2 - \sqrt{3}$$

   - ដូចនេះ តម្លៃ $a$ ដែលត្រូវរកគឺ $a \leq 2 - \sqrt{3}$ (ឬ $a \in (-\infty, 2-\sqrt{3}]$) ៕

**9** គេឱ្យអនុគមន៍ $y=\dfrac{mx^2+3mx+2m+1}{x+2}$

**a** ស្រាយបញ្ជាក់ថា អាស៊ីមតូតទ្រេតកាត់តាមចំណុចនឹងមួយ និងកំណត់កូអរដោនេ ៖

- គេអាចបំបែកអនុគមន៍ជាទម្រង់ ៖

$$y=\frac{m(x^2+3x+2)+1}{x+2}=\frac{m(x+1)(x+2)+1}{x+2}=m(x+1)+\frac{1}{x+2}$$

- ដោយ $\lim\limits_{x\to\pm\infty}\dfrac{1}{x+2}=0$ នាំឱ្យសមីការអាស៊ីមតូតទ្រេតនៃក្រាប $(C)$ គឺ ៖

$$(d):y=m(x+1)\iff m(x+1)-y=0$$

- ឧបមាថា $A(x_0,y_0)$ ជាចំណុចនឹងដែលស្ថិតលើបន្ទាត់ $(d)$ ចំពោះគ្រប់ $m\in\mathbb{R}$
- គេបានសមីការ $m(x_0+1)-y_0=0$ ផ្ទៀងផ្ទាត់ចំពោះគ្រប់ $m\in\mathbb{R}$ លុះត្រាតែ ៖

$$\begin{cases}x_0+1=0\\-y_0=0\end{cases}\implies\begin{cases}x_0=-1\\y_0=0\end{cases}$$

- ដូចនេះ អាស៊ីមតូតទ្រេតតែងតែកាត់តាមចំណុចនឹងមួយគឺ $A(-1,0)$ ចំពោះគ្រប់ $m$ ទាំងអស់ ៕

**b** រកតម្លៃ $m$ ដើម្បីឱ្យបន្ទាត់ $y=m$ ប៉ះក្រាប $(C)$ ៖

- សមីការអាបស៊ីសចំណុចប្រសព្វរវាងបន្ទាត់ $y=m$ និងក្រាប $(C)$ គឺ ៖

$$\frac{mx^2+3mx+2m+1}{x+2}=m\quad(x\neq-2)$$

$$\iff mx^2+3mx+2m+1=m(x+2)$$

$$\iff mx^2+2mx+1=0\quad(\text{សមីការ}*)$$

- បន្ទាត់ $y=m$ ប៉ះក្រាប $(C)$ លុះត្រាតែសមីការ $(*)$ ជាសមីការដឺក្រេទី២ មានឫសឌុប ($m\neq0$ និង $\Delta'=0$) ៖

$$\Delta'=m^2-m(1)=m^2-m=m(m-1)$$

$$\Delta'=0\iff m(m-1)=0\implies m=0\ \text{ឬ}\ m=1$$

- ពិនិត្យករណី ៖
  - បើ $m=0\implies1=0$ (មិនពិត $\implies$ គ្មានឫស) ៕

· បើ $m=1 \implies x^2+2x+1=0 \iff (x+1)^2=0 \implies x=-1\neq -2$ (មានឫសឌុប) ។

○ ដូចនេះ តម្លៃ $m$ ដែលត្រូវរកគឺ $m=1$ ។

ⓒ សិក្សាអថេរភាព និងសង់ក្រាប ចំពោះ $m=-1$ ៖

○ ចំពោះ $m=-1$ គេបានអនុគមន៍ ៖

$$f(x)=-(x+1)+\frac{1}{x+2}=-x-1+\frac{1}{x+2}=\frac{-x^2-3x-1}{x+2}$$

○ ដែនកំណត់ ៖ $D=\mathbb{R}\setminus\{-2\}=(-\infty,-2)\cup(-2,+\infty)$

○ ទិសដៅអថេរភាព ៖

- ដេរីវេ ៖

$$f'(x)=-1-\frac{1}{(x+2)^2}=\frac{-(x+2)^2-1}{(x+2)^2}=\frac{-x^2-4x-5}{(x+2)^2}$$

ដោយ $-(x+2)^2-1<0$ និង $(x+2)^2>0$ ចំពោះគ្រប់ $x\in D$

នាំឱ្យ $f'(x)<0$ ចំពោះគ្រប់ $x\in D$ ។

ដូចនេះ អនុគមន៍ចុះដាច់ខាតលើចន្លោះ $(-\infty,-2)$ និង $(-2,+\infty)$ ហើយគ្មានបរមាធៀបឡើយ ។

- គណនាលីមីត និងអាស៊ីមតូត ៖

· $\lim\limits_{x\to-\infty}f(x)=+\infty$ និង $\lim\limits_{x\to+\infty}f(x)=-\infty$

· $\lim\limits_{x\to-2^-}f(x)=-\infty$ និង $\lim\limits_{x\to-2^+}f(x)=+\infty \implies$ បន្ទាត់ $x=-2$ ជាអាស៊ីមតូតឈរ ។

· ដោយ $f(x)=-x-1+\dfrac{1}{x+2}$ ហើយ $\lim\limits_{x\to\pm\infty}\dfrac{1}{x+2}=0$

$\implies$ បន្ទាត់ $(d):y=-x-1$ ជាអាស៊ីមតូតទ្រេត ។

- តារាងអថេរភាព ៖

| $x$ | $-\infty$ | | $-2$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $-$ | ‖ | $-$ | |
| $f(x)$ | $+\infty$ | ↘ | ‖ | ↘ | $-\infty$ |
| | | | ‖ $+\infty$ | | |


○ សំណង់ក្រាប $(C)$ ៖

- ចំណុចប្រសព្វរវាងក្រាប $(C)$ និងអ័ក្ស $y'Oy$ គឺ $\left(0,-\dfrac{1}{2}\right)$ ។

- ចំណុចប្រសព្វរវាងក្រាប $(C)$ និងអ័ក្ស $x'Ox$ ៖

$y = 0 \iff -x^2 - 3x - 1 = 0 \implies x = \dfrac{-3-\sqrt{5}}{2} \approx -2.62$ ឬ $x = \dfrac{-3+\sqrt{5}}{2} \approx -0.38$ ។

- ចំណុចជំនួយបន្ថែម ៖ $(-1,0), (-3,2), (-4,2.5)$ ។




**10** គេឱ្យអនុគមន៍ $y = \dfrac{x^2+2(m+1)x+2}{x+1}$ ។

ⓐ ចំពោះ $m = 0$ សិក្សាអថេរភាព សង់ក្រាប $(C)$ និងកំណត់តម្លៃ $a$ ដើម្បីឱ្យក្រាប $(C)$ ប៉ះនឹងបន្ទាត់ $y = -x + a$ ៖

- ចំពោះ $m = 0$ គេបានអនុគមន៍ ៖

$$f(x) = \frac{x^2+2x+2}{x+1} = \frac{(x+1)^2+1}{x+1} = x+1+\frac{1}{x+1}$$

- ដែនកំណត់ ៖ $D = \mathbb{R} \setminus \{-1\} = (-\infty,-1) \cup (-1,+\infty)$
- ទិសដៅអថេរភាព ៖
  - ដេរីវេ ៖

$$f'(x) = 1 - \frac{1}{(x+1)^2} = \frac{(x+1)^2-1}{(x+1)^2} = \frac{x^2+2x}{(x+1)^2} = \frac{x(x+2)}{(x+1)^2}$$

$f'(x) = 0 \iff x(x+2) = 0 \implies x = 0$ ឬ $x = -2$ ។

ដោយ $(x+1)^2 > 0$ ចំពោះគ្រប់ $x \in D$ សញ្ញានៃ $f'(x)$ យកតាម $x(x+2)$ ៖

· $f'(x) > 0$ ចំពោះ $x \in (-\infty,-2) \cup (0,+\infty)$

· $f'(x) < 0$ ចំពោះ $x \in (-2,-1) \cup (-1,0)$

ដូចនេះ អនុគមន៍កើនលើចន្លោះ $(-\infty,-2)$ និង $(0,+\infty)$ ហើយចុះលើចន្លោះ $(-2,-1)$ និង $(-1,0)$ ។

- បរមាធៀប ៖

· អនុគមន៍មានអតិបរមាធៀបត្រង់ $x=-2$ គឺ $f(-2)=-2$

· អនុគមន៍មានអប្បបរមាធៀបត្រង់ $x=0$ គឺ $f(0)=2$

- គណនាលីមីត និងអាស៊ីមតូត ៖

· $\lim\limits_{x\to-\infty} f(x)=-\infty$ និង $\lim\limits_{x\to+\infty} f(x)=+\infty$

· $\lim\limits_{x\to-1^-} f(x)=-\infty$ និង $\lim\limits_{x\to-1^+} f(x)=+\infty \implies$ បន្ទាត់ $x=-1$ ជាអាស៊ីមតូតឈរ ៕

· $f(x)=x+1+\dfrac{1}{x+1}$ ដោយ $\lim\limits_{x\to\pm\infty}\dfrac{1}{x+1}=0 \implies$ បន្ទាត់ $(d):y=x+1$ ជាអាស៊ីមតូតទ្រេត ៕

- តារាងអថេរភាព ៖

| $x$ | $-\infty$ | | $-2$ | | $-1$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | ↗ | $-2$ | ↘ | $+\infty$ | ↘ | $2$ | ↗ | $+\infty$ |

○ សំណង់ក្រាប $(C)$ ៖

- ចំណុចប្រសព្វរវាងក្រាប $(C)$ និងអ័ក្ស $y'Oy$ គឺ $(0,2)$ (ជាចំណុចអប្បបរមាធៀប) ៕
- ក្រាបមិនកាត់អ័ក្ស $x'Ox$ ទេ ព្រោះ $x^2+2x+2=0$ មាន $\Delta'=-1<0$ ៕
- ចំណុចអតិបរមាធៀប គឺ $(-2,-2)$ ៕

○ កំណត់តម្លៃ $a$ ដើម្បីឱ្យក្រាប $(C)$ ប៉ះនឹងបន្ទាត់ $y=-x+a$ ៖

- សមីការអាប់ស៊ីសចំណុចប្រសព្វរវាងក្រាប $(C)$ និងបន្ទាត់ $y=-x+a$ ៖

$$\frac{x^2+2x+2}{x+1}=-x+a \quad (x\neq-1)$$

$$\iff x^2+2x+2=(-x+a)(x+1)$$

$$\iff x^2+2x+2=-x^2+(a-1)x+a$$


$$\iff 2x^2+(3-a)x+(2-a)=0 \quad (\text{សមីការ } *)$$

- បន្ទាត់ $y=-x+a$ ប៉ះក្រាប $(C)$ លុះត្រាតែសមីការ $(*)$ មានឫសឌុប $(\Delta=0)$ ៖

$$\Delta=(3-a)^2-4(2)(2-a)=9-6a+a^2-16+8a=a^2+2a-7$$

$$\Delta=0 \iff a^2+2a-7=0 \implies a=-1\pm2\sqrt{2}$$

- ដូចនេះ តម្លៃ $a$ ដែលត្រូវរកគឺ $a=-1-2\sqrt{2}$ ឬ $a=-1+2\sqrt{2}$ ។




(b) រកតម្លៃ $m$ ដើម្បីឱ្យអនុគមន៍កើនលើចន្លោះ $[0,+\infty)$ ៖

- បំបែកទម្រង់អនុគមន៍ ៖

$$f(x)=\frac{x^2+2(m+1)x+2}{x+1}=x+2m+1+\frac{1-2m}{x+1}$$

- លើចន្លោះ $[0,+\infty)$ អនុគមន៍ $f$ ជាប់ និងមានដេរីវេ ៖

$$f'(x)=1-\frac{1-2m}{(x+1)^2}=\frac{(x+1)^2-(1-2m)}{(x+1)^2}$$

- ដើម្បីឱ្យអនុគមន៍ $f$ កើនលើចន្លោះ $[0,+\infty)$ លុះត្រាតែ $f'(x)\geq 0$ ចំពោះគ្រប់ $x\in[0,+\infty)$
- ដោយ $(x+1)^2>0$ ចំពោះគ្រប់ $x\geq 0$ គេបាន ៖

$$(x+1)^2-(1-2m)\geq 0 \iff (x+1)^2\geq 1-2m \quad \forall x\in[0,+\infty)$$

- ចំពោះ $x\geq 0 \implies x+1\geq 1 \implies (x+1)^2\geq 1$
- នាំឱ្យតម្លៃតូចបំផុតនៃ $(x+1)^2$ លើចន្លោះ $[0,+\infty)$ គឺ $1$ (ត្រង់ $x=0$)
- ដូចនេះ វិសមភាព $(x+1)^2\geq 1-2m$ ពិតចំពោះគ្រប់ $x\geq 0$ លុះត្រាតែ ៖

$$1\geq 1-2m \iff 2m\geq 0 \iff m\geq 0$$

ដូចនេះ តម្លៃ $m$ ដែលត្រូវរកគឺ $m\geq 0$ (ឬ $m\in[0,+\infty)$) ។

# អនុគមន៍អិចស្ប៉ូណង់ស្យែល

## ២.១ ចំនួន $e$

| $n$ | $(1+1/n)^n$ |
|---|---|
| 2 | 2.59... |
| 10 | 2.70... |
| 1,000 | 2.71... |
| 10,000 | 2.718... |
| $\infty$ (infinity) | $e$ |

លីមីតនៃកន្សោម $\left(1+\frac{1}{n}\right)^n$ កាលណា $n$ ខិតជិត $+\infty$ ហៅថា **ចំនួន** $e$ ។

គេបាន $\boxed{e=\lim_{x\to+\infty}\left(1+\frac{1}{n}\right)^n\approx 2.7182}$


## ២.២ អនុគមន៍អិចស្ប៉ូណង់ស្យែល

### ២.២.១ និយមន័យ និងលក្ខណៈគ្រឹះ

**និយមន័យ** អនុគមន៍ដែលមានរាង $y=e^x$ ហៅថាអនុគមន៍អ៊ិចស្ប៉ូណង់ស្យែលគោល $e$ ដែល $e=\lim_{x\to+\infty}\left(1+\frac{1}{n}\right)^n$ ។ ■

- គោល $e$ ហៅថា ចំនួនអឺលែដែលតម្លៃនៃ $e\simeq 2.7182\cdots$
- ដែនកំណត់និងសំណុំរូបភាពនៃអនុគមន៍អិចស្ប៉ូណង់ស្យែលមានគោល $e$

តាមក្រាបរបស់អនុគមន៍ $f(x)=e^x$ យើងឃើញថា $f$ មានសំណុំដែនកំណត់លើចន្លោះ $(-\infty,+\infty)$ និងសំណុំរូបភាពលើ $(0,+\infty)$ នោះគេបាន $e^x>0\forall x\in\mathbb{R}$ ។



ក្រាបតាងអនុគមន៍ $f(x)=e^x$

**សម្គាល់**

ចំពោះគ្រប់ចំនួនពិត $m$ និង $n$ គេបាន

- (a) $e^{m+n}=e^m\cdot e^n$
- (b) $e^{-n}=\frac{1}{e^n}$
- (c) $e^{m-n}=\frac{e^m}{e^n}$
- (d) $(e^m)^n=e^{mn}$

## ២.៣ ដេរីវេនៃអនុគមន៍អិចស្ប៉ូណង់ស្យែល

**ដានូទៅ**

(a) បើ $f(x)=e^x$ នោះ $f'(x)=e^x$

(b) បើ $f(x)=a^x$ នោះ $f'(x)=a^x\ln a$

(c) បើ $f(x)=e^{u(x)}$ នោះ $f'(x)=u'(x)\cdot e^{u(x)}$

**លំហាត់គម្រូ** គណនាដេរីវេនៃអនុគមន៍ៈ

(a) $y=e^{4x}$ (b) $y=e^{x^2-3x+1}$ (c) $y=xe^x$

**ដំណោះស្រាយ**

(a) $y'=(e^{4x})'=(4x)'e^{4x}=4e^{4x}$

(b) $y'=(e^{x^2-3x+1})'=(x^2-3x+1)'e^{x^2-3x+1}=(2x-3)e^{x^2-3x+1}$

(c) $y'=(xe^x)'=(x)'e^x+x(e^x)'=e^x+xe^x=(1+x)e^x$ ។

**លំហាត់គំរូ 2** សិក្សាអថេរភាពនិងសង់ក្រាបនៃអនុគមន៍ $y=4-2e^{-x}$ ។

**ដំណោះស្រាយ** សិក្សាអថេរភាពនិងសង់ក្រាបនៃអនុគមន៍ $y=4-2e^{-x}$

- ដែនកំណត់ $D=\mathbb{R}$
- ទិសដៅអថេរភាព
  - ដេរីវេ $y'=2e^{-x}, y'>0$ ចំពោះគ្រប់តម្លៃ $x\in D$ ។ អនុគមន៍កើនលើ $D$ ។
  - លីមីត $\lim\limits_{x\to-\infty}(4-2e^{-x})=4-2\lim\limits_{x\to-\infty}\left(\dfrac{1}{e^x}\right)=-\infty$


    $\lim\limits_{x\to+\infty}(4-2e^{-x})=4-2\lim\limits_{x\to+\infty}\left(\dfrac{1}{e^x}\right)=4$ ។

    ដូច្នេះ សមីការបន្ទាត់ $y=4$ ជាអាស៊ីមតូតដេកនៃក្រាប ។
- តារាងអថេរភាព

| $x$ | $-\infty$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $f(x)$ | $-\infty$ | ↗ | $2$ | ↗ | $4$ |

- ក្រាបនៃអនុគមន៍ $y=4-2e^{-x}$
  - ចំណុចប្រសព្វរវាងក្រាបនិងអ័ក្ស

    $y'Oy: x=0$ នាំឱ្យ $y=2$ ។




- សង់ចំណុចបន្ថែម

  $x=-1, y=4-2e=-1.4$ ។

**លំហាត់គំរូ 3** អនុគមន៍ $f$ កំណត់លើ $\mathbb{R}$ ដោយ $y=f(x)=x-e^x$ មានក្រាប $C$ ។

ⓐ គណនា $\lim\limits_{x\to-\infty} f(x)$ និង $\lim\limits_{x\to+\infty} f(x)$ ។ រកសមីការអាស៊ីមតូតទ្រេត $L$ នៃក្រាប $C$ ។

ⓑ សិក្សាអថេរភាពនៃ $f$ និងសង់តារាងអថេរភាពនៃ $f$ ។

ⓒ គណនា $f(1)$ និង $f(2)$ ។ សង់ $L$ និង $C$ ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

**ដំណោះស្រាយ**

$C: f(x)=x-e^x$ ដែនកំណត់ $D=\mathbb{R}$

ⓐ គណនាលីមីត

- $\lim\limits_{x\to-\infty} f(x)=\lim\limits_{x\to-\infty}(x-e^x)=-\infty \quad \left(\text{ព្រោះ } \lim\limits_{x\to-\infty} e^x=0\right)$
- $\lim\limits_{x\to+\infty} f(x)=\lim\limits_{x\to+\infty}(x-e^x)$ (រាងមិនកំណត់ $+\infty-\infty$)

  $=\lim\limits_{x\to+\infty} e^x\left(\frac{x}{e^x}-1\right)=-\infty \quad \left(\text{ព្រោះ } \lim\limits_{x\to+\infty} e^x=+\infty \text{ និង } \lim\limits_{x\to+\infty}\frac{x}{e^x}=0\right)$ ។

រកសមីការអាស៊ីមតូតទ្រេត $L$ នៃក្រាប $C$

ដោយ $f(x)=x-e^x$ គេបាន $\lim\limits_{x\to-\infty}[f(x)-x]=\lim\limits_{x\to-\infty}(-e^x)=0$

ដូចេ្នះ $L: y=x$ ជាអាស៊ីមតូតទ្រេត $L$ នៃក្រាប $C$ ។

ⓑ សិក្សាអថេរភាពនៃ $f$

- ដេរីវេ: $f'(x)=(x-e^x)'=1-e^x$
- សញ្ញានៃដេរីវេ

$f'(x)$ មានសញ្ញាដូច $1-e^x$ ។

$1-e^x=0 \Leftrightarrow e^x=1 \Leftrightarrow x=0$

$1-e^x>0 \Leftrightarrow e^x<1 \Leftrightarrow x<0$

$1-e^x<0 \Leftrightarrow e^x>1 \Leftrightarrow x>0$


| $x$ | $-\infty$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | |

អនុគមន៍ $f$ កើនលើចន្លោះ $(-\infty,0)$ ព្រោះ $f'(x)>0$
អនុគមន៍ $f$ ចុះលើចន្លោះ $(0,+\infty)$ ព្រោះ $f'(x)<0$ ។
តម្លៃអតិបរមាធៀប $f(0)=0-e^0=-1$

- តារាងអថេរភាពនៃ $f$

| $x$ | $-\infty$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | |
| $f(x)$ | $-\infty$ | ↗ | $-1$ | ↘ | $-\infty$ |

ⓒ គណនា $f(1), f(2)$ $f(1)=1-e=1-2.7=-1.7$
$f(2)=2-e^2=2-7.3=-5.3$
សង់ $L$ និង $C$ :



**លំហាត់គំរូ 4** សិក្សាអថេរភាពនិងសង់ក្រាបនៃអនុគមន៍ $y = xe^x$ ។

**ដំណោះស្រាយ** សិក្សាអថេរភាពនិងសង់ក្រាបនៃអនុគមន៍ $y = xe^x$

- ដែនកំណត់ $D = \mathbb{R}$
- ទិសដៅអថេរភាព ដេរីវេ $y' = (x)'e^x + x(e^x)' = e^x(1+x)$ ដោយ $e^x > 0$ ចំពោះ $\forall x \in \mathbb{R}$ , $y'$ មានសញ្ញាដូច $x+1$ ។ $y' = 0$ គេបាន $x+1 = 0$ នាំឱ្យ $x = -1$ ។
- សញ្ញាដេរីវេ

| $x$ | $-\infty$ | | $-1$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | |


  - អនុគមន៍ $f$ កើនលើ $(-\infty, -1)$ ហើយចុះលើ $(-1, +\infty)$
  - ត្រង់ $x = -1$ អនុគមន៍ $y = f(x)$ មានតម្លៃអប្បបរមាធៀប
    $f(-1) = -e^{-1} \approx -0.36$
  - លីមីត : ដោយ $\lim\limits_{x\to-\infty} x = -\infty$ ហើយ $\lim\limits_{x\to-\infty} e^x = 0$
    គេបាន $-\lim\limits_{x\to-\infty} \dfrac{-x}{e^{-x}} = 0$ ដូច្នេះបន្ទាត់សមីការ $y = 0$ ជាអាស៊ីមតូតដេក
    នៃក្រាប កាលណា $x \to -\infty$ ។
    ដោយ $\lim\limits_{x\to+\infty} x = +\infty$ ហើយ $\lim\limits_{x\to+\infty} e^x = +\infty$
    គេបាន $\lim\limits_{x\to+\infty} xe^x = +\infty$ ។
- តារាងអថេរភាព

| $x$ | $-\infty$ | | $-1$ | | $+\infty$ |
|---|---|---|---|---|---|
| $y'$ | | $-$ | $0$ | $+$ | |
| $y$ | $0$ | ↘ | $-e^{-1}$ | ↗ | $+\infty$ |

- ក្រាប $y = xe^x$
  - ចំណុចប្រសព្វរវាងក្រាបនិងអ័ក្ស $x'Ox$
    $y = 0$ នាំឱ្យ $x = 0$ ក្រាបកាត់តាមគល់ $O$ ។
  - ចំណុចរបត់ : $y'' = (x+2)e^x$
    ដោយ $e^x > 0, y''$ មានសញ្ញាដូច $x+2$
    $y'' = 0$ គេបាន $x+2 = 0$ នាំឱ្យ $x = -2$

| $x$ | $-\infty$ | | $-2$ | | $+\infty$ |
|---|---|---|---|---|---|
| $y''$ | | $-$ | $0$ | $+$ | |

ដូច្នេះ អនុគមន៍មានចំណុចរបត់មួយគឺ
$I(-2,-2e^{-2})$ ឬ $I(-2,-0.27)$ ។




**ប្រតិបត្តិ** សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ខាងក្រោម

ⓐ $y = x + e^x$ ⓑ $f(x) = \dfrac{3}{1+2e^{-5x}}$ ⓒ $y = \dfrac{x}{e^x}$

**ដំណោះស្រាយ** សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ខាងក្រោម

ⓐ $y = x + e^x$

- ដែនកំណត់ ៖
  - អនុគមន៍ $f(x)$ កំណត់លើ $D = \mathbb{R} = (-\infty, +\infty)$ ។
- ទិសដៅអថេរភាព ៖
  - ដេរីវេ ៖

$$f'(x) = (x)' + (e^x)' = 1 + e^x$$

ដោយ $e^x > 0$ ចំពោះគ្រប់ $x \in \mathbb{R}$ នាំឱ្យ $f'(x) = 1 + e^x > 1 > 0$ ចំពោះគ្រប់ $x \in \mathbb{R}$ ។
ដូចនេះ អនុគមន៍ $f$ ជាអនុគមន៍កើនដាច់ខាតលើ $\mathbb{R}$ ហើយគ្មានបរមាធៀបឡើយ ។

  - គណនាលីមីត និងអាស៊ីមតូត ៖

· $\lim\limits_{x\to-\infty} f(x) = \lim\limits_{x\to-\infty}(x+e^x) = -\infty$ (ព្រោះ $\lim\limits_{x\to-\infty} e^x = 0$)

· $\lim\limits_{x\to+\infty} f(x) = \lim\limits_{x\to+\infty}(x+e^x) = +\infty$ (ព្រោះ $\lim\limits_{x\to+\infty} e^x = +\infty$)

· អាស៊ីមតូតទ្រេត ៖ ដោយ $\lim\limits_{x\to-\infty}[f(x)-x] = \lim\limits_{x\to-\infty} e^x = 0$

នាំឱ្យបន្ទាត់ $(d): y = x$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ខាង $-\infty$ ៕

○ តារាងអថេរភាព ៖

| $x$ | $-\infty$ | | $+\infty$ |
|---|---|---|---|
| $f'(x)$ | | $+$ | |
| $f(x)$ | $-\infty$ | ↗ | $+\infty$ |

• សំណង់ក្រាប $(C)$ ៖

○ ចំណុចប្រសព្វរវាងក្រាប $(C)$ និងអ័ក្ស $y'Oy$ ៖

$x = 0 \implies f(0) = 0 + e^0 = 1 \implies$ ក្រាបកាត់អ័ក្ស $y'Oy$ ត្រង់ចំណុច $(0,1)$ ៕


○ ចំណុចប្រសព្វរវាងក្រាប $(C)$ និងអ័ក្ស $x'Ox$ ៖

$y = 0 \iff x + e^x = 0 \implies x \approx -0.57$ (ក្រាបកាត់អ័ក្ស $x'Ox$ ត្រង់ចន្លោះ $-1 < x < 0$) ៕

○ ចំណុចជំនួយបន្ថែម ៖

· $x = -1 \implies y = -1 + e^{-1} \approx -0.63$

· $x = 1 \implies y = 1 + e \approx 3.72$




**b** $f(x) = \dfrac{3}{1+2e^{-5x}}$

• ដែនកំណត់ ៖

○ ដោយ $e^{-5x} > 0$ ចំពោះគ្រប់ $x \in \mathbb{R} \implies 1 + 2e^{-5x} > 1 > 0$ ចំពោះគ្រប់ $x \in \mathbb{R}$

- នាំឱ្យអនុគមន៍ $f(x)$ មានដែនកំណត់ $D = \mathbb{R} = (-\infty, +\infty)$ ។


- ទិសដៅអថេរភាព ៖
  - ដេរីវេ ៖

$$f'(x) = \frac{-3 \cdot (2e^{-5x})'}{(1+2e^{-5x})^2} = \frac{-3 \cdot (-10e^{-5x})}{(1+2e^{-5x})^2} = \frac{30e^{-5x}}{(1+2e^{-5x})^2}$$

  ដោយ $e^{-5x} > 0$ និង $(1+2e^{-5x})^2 > 0$ ចំពោះគ្រប់ $x \in \mathbb{R}$
  នាំឱ្យ $f'(x) > 0$ ចំពោះគ្រប់ $x \in \mathbb{R}$ ។
  ដូចនេះ អនុគមន៍ $f$ ជាអនុគមន៍កើនដាច់ខាតលើ $\mathbb{R}$ ហើយគ្មានបរមាធៀបឡើយ ។
  - គណនាលីមីត និងអាស៊ីមតូត ៖
    - $\lim\limits_{x\to-\infty} f(x) = \lim\limits_{x\to-\infty} \frac{3}{1+2e^{-5x}} = 0$ (ព្រោះ $\lim\limits_{x\to-\infty} e^{-5x} = +\infty$)
      $\Longrightarrow$ បន្ទាត់ $y = 0$ (អ័ក្ស $x'Ox$) ជាអាស៊ីមតូតដេកនៃក្រាប $(C)$ ខាង $-\infty$ ។
    - $\lim\limits_{x\to+\infty} f(x) = \lim\limits_{x\to+\infty} \frac{3}{1+2e^{-5x}} = \frac{3}{1+0} = 3$ (ព្រោះ $\lim\limits_{x\to+\infty} e^{-5x} = 0$)
      $\Longrightarrow$ បន្ទាត់ $y = 3$ ជាអាស៊ីមតូតដេកនៃក្រាប $(C)$ ខាង $+\infty$ ។
  - តារាងអថេរភាព ៖

| $x$ | $-\infty$ | | $+\infty$ |
|---|---|---|---|
| $f'(x)$ | | $+$ | |
| $f(x)$ | $0$ | ↗ | $3$ |

- សំណង់ក្រាប $(C)$ ៖
  - ចំណុចប្រសព្វរវាងក្រាប $(C)$ និងអ័ក្ស $y'Oy$ ៖
    $x = 0 \implies f(0) = \frac{3}{1+2e^0} = \frac{3}{3} = 1 \implies$ ក្រាបកាត់អ័ក្ស $y'Oy$ ត្រង់ចំណុច $(0,1)$ ។
  - ចំណុចរបត់ ៖
    $f''(x) = \frac{150e^{-5x}(2e^{-5x}-1)}{(1+2e^{-5x})^3}$
    $f''(x) = 0 \iff 2e^{-5x} - 1 = 0 \implies x = \frac{\ln 2}{5} \approx 0.14 \implies y = \frac{3}{2} = 1.5$ ។
  - ចំណុចជំនួយបន្ថែម ៖
    - $x = -0.5 \implies y = \frac{3}{1+2e^{2.5}} \approx 0.12$
    - $x = 0.5 \implies y = \frac{3}{1+2e^{-2.5}} \approx 2.58$




◈ $y = \dfrac{x}{e^x}$

- ដែនកំណត់ ៖
  - ដោយ $e^x > 0$ ចំពោះគ្រប់ $x \in \mathbb{R}$ នាំឱ្យអនុគមន៍ $f(x)$ មានដែនកំណត់ $D = \mathbb{R} = (-\infty, +\infty)$ ៕
- ទិសដៅអថេរភាព ៖
  - ដេរីវេ ៖

$$f'(x) = \frac{(x)' \cdot e^x - x \cdot (e^x)'}{(e^x)^2} = \frac{e^x - xe^x}{e^{2x}} = \frac{1-x}{e^x}$$

$f'(x) = 0 \iff 1 - x = 0 \implies x = 1$ ៕

ដោយ $e^x > 0$ ចំពោះគ្រប់ $x \in \mathbb{R}$ សញ្ញានៃ $f'(x)$ យកតាម $(1-x)$ ៖

· $f'(x) > 0$ ចំពោះ $x \in (-\infty, 1)$

· $f'(x) < 0$ ចំពោះ $x \in (1, +\infty)$

ដូចនេះ អនុគមន៍កើនលើចន្លោះ $(-\infty, 1)$ និងចុះលើចន្លោះ $(1, +\infty)$ ៕

  - អតិបរមាធៀប ៖ ត្រង់ $x = 1$ ដេរីវេ $f'(x)$ ប្តូរសញ្ញាពីបូក $(+)$ ទៅដក $(-)$ នាំឱ្យអនុគមន៍ $f$ មានអតិបរមាធៀបមួយត្រង់ $x = 1$ គឺ ៖

$$f(1) = \frac{1}{e} \approx 0.37$$

  - គណនាលីមីត និងអាស៊ីមតូត ៖

· $\lim\limits_{x \to -\infty} f(x) = \lim\limits_{x \to -\infty} \dfrac{x}{e^x} = -\infty$


· $\lim\limits_{x \to +\infty} f(x) = \lim\limits_{x \to +\infty} \dfrac{x}{e^x} = 0$

$\implies$ បន្ទាត់ $y = 0$ (អ័ក្ស $x'Ox$) ជាអាស៊ីមតូតដេកនៃក្រាប $(C)$ ខាង $+\infty$ ៕

  - តារាងអថេរភាព ៖

| $x$ | $-\infty$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | |
| $f(x)$ | $-\infty$ | ↗ | $\frac{1}{e}$ | ↘ | $0$ |

- សំណង់ក្រាប $(C)$ ៖
  - ចំណុចប្រសព្វរវាងក្រាប $(C)$ និងអ័ក្សកូអរដោនេ ៖
    $x=0 \Longrightarrow f(0)=0 \Longrightarrow$ ក្រាបកាត់តាមគល់តម្រុយ $O(0,0)$ ។
  - ចំណុចរបត់ ៖
    $f''(x)=\dfrac{x-2}{e^x}=0 \Longleftrightarrow x=2 \Longrightarrow y=\dfrac{2}{e^2}\approx 0.27$ ។
  - ចំណុចជំនួយបន្ថែម ៖
    - $x=-1 \Longrightarrow y=-e\approx -2.72$
    - $x=3 \Longrightarrow y=\dfrac{3}{e^3}\approx 0.15$




## លំហាត់

**1** គណនាដេរីវេនៃអនុគមន៍ខាងក្រោម

(a) $y=e^{2x}$
(b) $y=e^{4x}$
(c) $y=e^{x^2-3x+1}$
(d) $y=xe^x$
(e) $y=(x^2-3)(e^x)$
(f) $y=x^2e^{-2x}$
(g) $y=\dfrac{\sqrt{x}}{e^x}$

**2** គណនាដេរីវេនៃអនុគមន៍

ⓐ $y = e^x$
ⓑ $y = 3^x$
ⓒ $y = xe^x$
ⓓ $y = x^3e^x$
ⓔ $y = e^x \sin x$
ⓕ $y = x^4e^{2x}$
ⓖ $y = e^{-x}\cos x$
ⓗ $y = e^{4x}\sin 3x$
ⓘ $y = 4^{4x^4}$
ⓙ $y = 4^{-5x^4}$
ⓚ $y = (4^x + 2)^3$
ⓛ $y = 3^{(x^4+1)^3}$
ⓜ $y = 3^{\cos 3x^4}$

**3** គណនាដេរីវេនៃអនុគមន៍ខាងក្រោម

ⓐ $y = (x^2 + 1)e^{3x}$
ⓑ $y = e^{x^2+3x}$
ⓒ $y = \dfrac{e^{2x} + e^{-2x}}{x^2}$
ⓓ $y = 3^{x^2+3x}$
ⓔ $y = x \cdot 5^{3x}$
ⓕ $y = \dfrac{3^x - 3^{-x}}{2}$
ⓖ $y = xe^{x^2+1}$
ⓗ $y = \sqrt{1 + e^x}$
ⓘ $y = (2x + e^{x^2})^4$
ⓙ $y = (3x)^{5x}$
ⓚ $y = (3x + 2)^{2x-1}$

## ដំណោះស្រាយ

**1** គណនាដេរីវេនៃអនុគមន៍ខាងក្រោម

ⓐ $y = e^{2x} \Longrightarrow y' = (2x)'e^{2x} = \boxed{2e^{2x}}$

ⓑ $y = e^{4x} \Longrightarrow y' = (4x)'e^{4x} = \boxed{4e^{4x}}$

ⓒ $y = e^{x^2-3x+1} \Longrightarrow y' = (x^2 - 3x + 1)'e^{x^2-3x+1} = \boxed{(2x - 3)e^{x^2-3x+1}}$

ⓓ $y = xe^x \Longrightarrow y' = (x)'e^x + x(e^x)' = 1 \cdot e^x + xe^x = \boxed{(x + 1)e^x}$

ⓔ $y = (x^2 - 3)e^x$

$\Longrightarrow y' = (x^2 - 3)'e^x + (x^2 - 3)(e^x)' = 2xe^x + (x^2 - 3)e^x = \boxed{(x^2 + 2x - 3)e^x}$

ⓕ $y = x^2e^{-2x}$

$\Longrightarrow y' = (x^2)'e^{-2x} + x^2(e^{-2x})' = 2xe^{-2x} + x^2(-2e^{-2x})$

$= 2xe^{-2x} - 2x^2e^{-2x} = \boxed{2x(1 - x)e^{-2x}}$

ⓖ $y = \dfrac{\sqrt{x}}{e^x}$

$$\Longrightarrow y' = \frac{(\sqrt{x})'e^x - \sqrt{x}(e^x)'}{(e^x)^2} = \frac{\frac{1}{2\sqrt{x}}e^x - \sqrt{x}e^x}{e^{2x}} = \frac{e^x\left(\frac{1 - 2x}{2\sqrt{x}}\right)}{e^{2x}} = \boxed{\frac{1 - 2x}{2\sqrt{x}e^x}}$$

**2** គណនាដេរីវេនៃអនុគមន៍

ⓐ $y = e^x \Longrightarrow y' = (e^x)' = e^x$

ដូចនេះ $\boxed{y' = e^x}$

(b) $y = 3^x \Longrightarrow y' = (3^x)' = 3^x \ln$

ដូចនេះ $\boxed{y' = 3^x \ln 3}$

(c) $y = xe^x$

$$\begin{aligned}\Longrightarrow y' &= (x)'e^x + x(e^x)' \\ &= 1 \cdot e^x + xe^x \\ &= (x+1)e^x\end{aligned}$$

ដូចនេះ $\boxed{y' = (x+1)e^x}$

(d) $y = x^3e^x$

$$\begin{aligned}\Longrightarrow y' &= (x^3)'e^x + x^3(e^x)' \\ &= 3x^2e^x + x^3e^x \\ &= x^2(x+3)e^x\end{aligned}$$

ដូចនេះ $\boxed{y' = x^2(x+3)e^x}$

(e) $y = e^x \sin x$

$$\begin{aligned}\Longrightarrow y' &= (e^x)' \sin x + e^x(\sin x)' \\ &= e^x \sin x + e^x \cos x \\ &= e^x(\sin x + \cos x)\end{aligned}$$

ដូចនេះ $\boxed{y' = e^x(\sin x + \cos x)}$

(f) $y = x^4e^{2x}$

$$\begin{aligned}\Longrightarrow y' &= (x^4)'e^{2x} + x^4(e^{2x})' \\ &= 4x^3e^{2x} + x^4(2e^{2x}) \\ &= 2x^3(x+2)e^{2x}\end{aligned}$$

ដូចនេះ $\boxed{y' = 2x^3(x+2)e^{2x}}$

ⓖ $y = e^{-x}\cos x$

$$\begin{aligned}\Longrightarrow y' &= (e^{-x})'\cos x + e^{-x}(\cos x)' \\ &= -e^{-x}\cos x + e^{-x}(-\sin x) \\ &= -e^{-x}(\cos x + \sin x)\end{aligned}$$

ដូចនេះ $\boxed{y' = -e^{-x}(\cos x + \sin x)}$

ⓗ $y = e^{4x}\sin 3x$

$$\begin{aligned}\Longrightarrow y' &= (e^{4x})'\sin 3x + e^{4x}(\sin 3x)' \\ &= 4e^{4x}\sin 3x + 3e^{4x}\cos 3x \\ &= e^{4x}(4\sin 3x + 3\cos 3x)\end{aligned}$$

ដូចនេះ $\boxed{y' = e^{4x}(4\sin 3x + 3\cos 3x)}$

ⓘ $y = 4^{4x^4}$

$$\begin{aligned}\text{គេបាន } y' &= (4x^4)' \cdot 4^{4x^4}\ln 4 \\ &= 16x^3 \cdot 4^{4x^4}\ln 4\end{aligned}$$

ដូចនេះ $\boxed{y' = 16x^3 \cdot 4^{4x^4}\ln 4}$

ⓙ $y = 4^{-5x^4}$

$$\begin{aligned}\Longrightarrow y' &= (-5x^4)' \cdot 4^{-5x^4}\ln 4 \\ &= -20x^3 \cdot 4^{-5x^4}\ln 4\end{aligned}$$

ដូចនេះ $\boxed{y' = -20x^3 \cdot 4^{-5x^4}\ln 4}$

(k) $y = (4^x + 2)^3$

$$\begin{aligned}\Longrightarrow y' &= 3(4^x+2)^2 \cdot (4^x+2)' \\ &= 3(4^x+2)^2 \cdot 4^x \ln 4 \\ &= 3\ln 4 \cdot 4^x (4^x+2)^2\end{aligned}$$

ដូចនេះ $\boxed{y' = 3\ln 4 \cdot 4^x (4^x+2)^2}$

(l) $y = 3^{(x^4+1)^3}$

$$\begin{aligned}\text{គេបាន } y' &= \left[(x^4+1)^3\right]' \cdot 3^{(x^4+1)^3} \ln 3 \\ &= 3(x^4+1)^2 \cdot (x^4+1)' \cdot 3^{(x^4+1)^3} \ln 3 \\ &= 3(x^4+1)^2 \cdot (4x^3) \cdot 3^{(x^4+1)^3} \ln 3 \\ &= 12x^3 (x^4+1)^2 \ln 3 \cdot 3^{(x^4+1)^3}\end{aligned}$$

ដូចនេះ $\boxed{y' = 12x^3 (x^4+1)^2 \ln 3 \cdot 3^{(x^4+1)^3}}$

(m) $y = 3^{\cos 3x^4}$

$$\begin{aligned}\Longrightarrow y' &= (\cos 3x^4)' \cdot 3^{\cos 3x^4} \ln 3 \\ &= (-\sin 3x^4) \cdot (3x^4)' \cdot 3^{\cos 3x^4} \ln 3 \\ &= -12x^3 \ln 3 \sin 3x^4 \cdot 3^{\cos 3x^4}\end{aligned}$$

ដូចនេះ $\boxed{y' = -12x^3 \ln 3 \sin 3x^4 \cdot 3^{\cos 3x^4}}$

**3** គណនាដេរីវេនៃអនុគមន៍ខាងក្រោម

(a) $y = (x^2+1)e^{3x}$

$$\begin{aligned}\Longrightarrow y' &= (x^2+1)' e^{3x} + (x^2+1)(e^{3x})' \\ &= 2xe^{3x} + (x^2+1)(3e^{3x}) \\ &= (3x^2+2x+3)e^{3x}\end{aligned}$$

ដូចនេះ $\boxed{y' = (3x^2+2x+3)e^{3x}}$

**b** $y = e^{x^2+3x}$

$$\begin{aligned}\Longrightarrow y' &= (x^2+3x)'e^{x^2+3x}\\ &= (2x+3)e^{x^2+3x}\end{aligned}$$

ដូចនេះ $\boxed{y' = (2x+3)e^{x^2+3x}}$

**c** $y = \dfrac{e^{2x}+e^{-2x}}{x^2}$

$$\begin{aligned}\Longrightarrow y' &= \frac{(e^{2x}+e^{-2x})'x^2 - (e^{2x}+e^{-2x})(x^2)'}{(x^2)^2}\\ &= \frac{(2e^{2x}-2e^{-2x})x^2 - (e^{2x}+e^{-2x})(2x)}{x^4}\\ &= \frac{2x\left[x(e^{2x}-e^{-2x}) - (e^{2x}+e^{-2x})\right]}{x^4}\\ &= \frac{2\left[(x-1)e^{2x} - (x+1)e^{-2x}\right]}{x^3}\end{aligned}$$

ដូចនេះ $\boxed{y' = \dfrac{2\left[(x-1)e^{2x} - (x+1)e^{-2x}\right]}{x^3}}$

**d** $y = 3^{x^2+3x}$

$$\begin{aligned}\Longrightarrow y' &= (x^2+3x)' \cdot 3^{x^2+3x}\ln 3\\ &= (2x+3)3^{x^2+3x}\ln 3\end{aligned}$$

ដូចនេះ $\boxed{y' = (2x+3)3^{x^2+3x}\ln 3}$

**e** $y = x \cdot 5^{3x}$

$$\begin{aligned}\Longrightarrow y' &= (x)'5^{3x} + x(5^{3x})'\\ &= 1 \cdot 5^{3x} + x(3 \cdot 5^{3x}\ln 5)\\ &= (1+3x\ln 5)5^{3x}\end{aligned}$$

ដូចនេះ $\boxed{y' = (1+3x\ln 5)5^{3x}}$

(f) $y = \dfrac{3^x - 3^{-x}}{2}$

$$\begin{aligned}\Longrightarrow y' &= \frac{(3^x)' - (3^{-x})'}{2}\\ &= \frac{3^x\ln 3 - (-3^{-x}\ln 3)}{2}\\ &= \frac{(3^x + 3^{-x})\ln 3}{2}\end{aligned}$$

ដូចនេះ $\boxed{y' = \dfrac{(3^x + 3^{-x})\ln 3}{2}}$

(g) $y = xe^{x^2+1}$

$$\begin{aligned}\Longrightarrow y' &= (x)'e^{x^2+1} + x(e^{x^2+1})'\\ &= 1\cdot e^{x^2+1} + x(2xe^{x^2+1})\\ &= (2x^2+1)e^{x^2+1}\end{aligned}$$

ដូចនេះ $\boxed{y' = (2x^2+1)e^{x^2+1}}$

(h) $y = \sqrt{1+e^x}$

$$\begin{aligned}\Longrightarrow y' &= \frac{(1+e^x)'}{2\sqrt{1+e^x}}\\ &= \frac{e^x}{2\sqrt{1+e^x}}\end{aligned}$$

ដូចនេះ $\boxed{y' = \dfrac{e^x}{2\sqrt{1+e^x}}}$

ⓘ $y = (2x + e^{x^2})^4$

$$\begin{aligned}\Longrightarrow y' &= 4(2x + e^{x^2})^3(2x + e^{x^2})' \\ &= 4(2x + e^{x^2})^3(2 + 2xe^{x^2}) \\ &= 8(1 + xe^{x^2})(2x + e^{x^2})^3\end{aligned}$$

ដូចនេះ $\boxed{y' = 8(1 + xe^{x^2})(2x + e^{x^2})^3}$

ⓙ $y = (3x)^{5x}$

$$\begin{aligned}\ln y &= 5x\ln(3x) \\ \Longrightarrow \frac{y'}{y} &= (5x)'\ln(3x) + 5x(\ln(3x))' \\ &= 5\ln(3x) + 5x \cdot \frac{3}{3x} \\ &= 5(1 + \ln(3x)) \\ \Longrightarrow y' &= 5(3x)^{5x}(1 + \ln(3x))\end{aligned}$$

ដូចនេះ $\boxed{y' = 5(3x)^{5x}(1 + \ln(3x))}$

ⓚ $y = (3x + 2)^{2x-1}$

$$\begin{aligned}\ln y &= (2x - 1)\ln(3x + 2) \\ \Longrightarrow \frac{y'}{y} &= (2x - 1)'\ln(3x + 2) + (2x - 1)(\ln(3x + 2))' \\ &= 2\ln(3x + 2) + (2x - 1) \cdot \frac{3}{3x + 2} \\ &= 2\ln(3x + 2) + \frac{6x - 3}{3x + 2} \\ \Longrightarrow y' &= (3x + 2)^{2x-1}\left[2\ln(3x + 2) + \frac{6x - 3}{3x + 2}\right]\end{aligned}$$

ដូចនេះ $\boxed{y' = (3x + 2)^{2x-1}\left[2\ln(3x + 2) + \frac{6x - 3}{3x + 2}\right]}$

## ២.៤ អថេរភាពអនុគមន៍អិចស្ប៉ូណង់ស្យែល

**របៀបដោះស្រាយ**

**ប្តង់សិក្សាអនុគមន៍អ៊ិចស្ប៉ូណង់ស្យែល**

*a*. ដែកកំណត់

*b*. លីមីតចុងដែនកំណត់

*c*. ទិសដៅអថេរភាព

– ដេរីវេទី១ និង សិក្សាសញ្ញាដេរីវេទី១

– តារាងអថេរភាព

*d*. សង់ក្រាបនៃអនុគមន៍

– ចំណុចប្រសព្វអ័ក្ស $y'oy$ (ឱ្យ $x=0$) និង ចំណុចប្រសព្វអ័ក្ស $x'ox$ (ឱ្យ $y=0$) បើមាន

# លំហាត់

**1** សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ខាងក្រោម

ⓐ $y=4-2e^{-x}$

ⓑ $y=x-e^{x}$

ⓒ $y=xe^{x}$

ⓓ $y=x+e^{x}$

ⓔ $y=\dfrac{1}{1+2e^{-5x}}$

ⓕ $y=\dfrac{x}{e^{x}}$

**2** $f$ ជាអនុគមន៍កំណត់ដោយ $f(x)=e^{1-x}$ ហើយ $C$ ជាក្រាបរបស់ $f$ ។

ⓐ បញ្ជាក់ដែនកំណត់នៃ $f$ រួចបង្ហាញថា $f$ ជាអនុគមន៍ចុះលើ $\mathbb{R}$ ។

ⓑ គណនា $\lim\limits_{x\to+\infty} f(x)$ និង $\lim\limits_{x\to-\infty} f(x)$ រួចបកស្រាយសមីការអាស៊ីមតូតនៃ $C$ ។

ⓒ គូសតារាងអថេរភាព $f$ ។

ⓓ គណនាចំណុចប្រសព្វរវាងអ័ក្ស $C$ និងអ័ក្សអាប់ស៊ីស (គិត $e=2.7$) ។

ⓔ សរសេរសមីការតង់សង់ $L$ ដែលប៉ះ ៖

ⓕ ក្រាប $C$ ត្រង់ $x=1$ សង់ក្រាប $C$ និងបន្ទាត់ $L$ នៅក្នុងប្រព័ន្ធអ័ក្សកូណាល់មួយ ។

**3** គេឲ្យអនុគមន៍ $g$ មួយកំណត់ដោយ $g(x)=e^{x}+ax+b$

ⓐ គណនា $g'(x), g''(x)$ រួចបកស្រាយ $g''(x)>0$ ចំពោះគ្រប់ $a, b$ ។

ⓑ គណនា $a$ និង $b$ ដោយដឹងថា មេគុណប្រាប់ទិសនៃបន្ទាត់ប៉ះនឹងខ្សែកោង $C$ត្រង់គល់$O$ ស្របអ័ក្ស $(x'Ox)$ ។

ⓒ កំណត់តម្លៃ $a$ និង $b$ ដែលរកឃើញ ចូរគណនា $g'(x)$ រួចសង់តារាងអថេរភាព នៃ $g$ (មិនបាច់គណនាលីមីតចុងដែន) ។

ⓓ គណនា $\lim\limits_{x\to-\infty} g(x)$ និង $\lim\limits_{x\to+\infty} g(x)$ ទាញសមីការអាស៊ីមតូតទ្រេតខាង $-\infty$ នៃ $g$ រួចទាញរកសញ្ញា $g$ ។ ស្រាយបញ្ជាក់ថា $e^x \geq 1+x, \forall x \in \mathbb{R}$ ។

ⓔ សង់ខ្សែកោង $C$ តាង $g$ និងអាស៊ីមតូតទ្រេតនៅក្នុងតម្រុយអរតូណរមេ $(O,\vec{i},\vec{j})$ ។

ⓕ ដោយប្រើខ្សែកោង $C$ ចូរពិភាក្សាតាមតម្លៃប៉ារ៉ាម៉ែត្រ $m$នូវចំនួនឫសនៃសមីការ $e^x - 1 = m + x$ ។

ⓖ គណនាផ្ទៃក្រឡា$S$ ដែលខណ្ឌដោយខ្សែកោង $C$ នឹងអ័ក្ស $(x'Ox)$ និងបន្ទាត់ $x=0, x=1$ ។

## ដំណោះស្រាយ

**1** សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ខាងក្រោម

ⓐ $y = 4 - 2e^{-x}$

- ដែនកំណត់ ៖
  - ដោយ $e^{-x} > 0$ ចំពោះគ្រប់ $x \in \mathbb{R}$
    នាំឱ្យអនុគមន៍ $f(x)$ មានដែនកំណត់ $D = \mathbb{R} = (-\infty, +\infty)$ ॥
- ទិសដៅអថេរភាព ៖
  - ដេរីវេ ៖

$$f'(x) = (4 - 2e^{-x})' = -2(-e^{-x}) = 2e^{-x}$$

ដោយ $e^{-x} > 0$ ចំពោះគ្រប់ $x \in \mathbb{R}$ នាំឱ្យ $f'(x) = 2e^{-x} > 0$ ចំពោះគ្រប់ $x \in \mathbb{R}$ ॥
ដូចនេះ អនុគមន៍ $f$ ជាអនុគមន៍កើនដាច់ខាតលើ $\mathbb{R}$ ហើយគ្មានបរមាធៀបឡើយ ॥

  - គណនាលីមីត និងអាស៊ីមតូត ៖

· $\lim\limits_{x\to-\infty} f(x) = \lim\limits_{x\to-\infty}(4 - 2e^{-x}) = -\infty$ (ព្រោះ $\lim\limits_{x\to-\infty} e^{-x} = +\infty$)
· $\lim\limits_{x\to+\infty} f(x) = \lim\limits_{x\to+\infty}(4 - 2e^{-x}) = 4$ (ព្រោះ $\lim\limits_{x\to+\infty} e^{-x} = 0$)
$\Longrightarrow$ បន្ទាត់ $y = 4$ ជាអាស៊ីមតូតដេកនៃក្រាប $(C)$ ខាង $+\infty$ ॥

  - តារាងអថេរភាព ៖

| $x$ | $-\infty$ | | $+\infty$ |
|---|---|---|---|
| $f'(x)$ | | $+$ | |
| $f(x)$ | $-\infty$ | ↗ | $4$ |

- សំណង់ក្រាប $(C)$ ៖
  - ចំណុចប្រសព្វរវាងក្រាប $(C)$ និងអ័ក្ស $y'Oy$ ៖
    $x = 0 \Longrightarrow f(0) = 4 - 2e^0 = 2 \Longrightarrow$ ក្រាបកាត់អ័ក្ស $y'Oy$ ត្រង់ចំណុច $(0,2)$ ॥


- ចំណុចប្រសព្វរវាងក្រាប $(C)$ និងអ័ក្ស $x'Ox$ ៖

  $y=0 \iff 4-2e^{-x}=0 \iff e^{-x}=2 \iff x=-\ln 2 \approx -0.69 \implies$ ក្រាបកាត់អ័ក្ស $x'Ox$ ត្រង់ចំណុច $(-\ln 2, 0)$ ៕

- ចំណុចជំនួយបន្ថែម ៖

  $\cdot\ x=1 \implies y=4-2e^{-1} \approx 3.26$

  $\cdot\ x=-1 \implies y=4-2e \approx -1.44$




**b** $y=x-e^x$

- ដែនកំណត់ ៖
  - ដោយ $e^x$ កំណត់លើ $\mathbb{R}$ នាំឱ្យអនុគមន៍ $f(x)$ មានដែនកំណត់ $D=\mathbb{R}=(-\infty,+\infty)$ ៕
- ទិសដៅអថេរភាព ៖
  - ដេរីវេ ៖

$$f'(x)=(x)'-(e^x)'=1-e^x$$

$f'(x)=0 \iff 1-e^x=0 \iff e^x=1 \implies x=0$ ៕

$\cdot\ f'(x)>0 \iff 1-e^x>0 \iff e^x<1 \iff x\in(-\infty,0)$

$\cdot\ f'(x)<0 \iff 1-e^x<0 \iff e^x>1 \iff x\in(0,+\infty)$

ដូចនេះ អនុគមន៍កើនលើចន្លោះ $(-\infty,0)$ និងចុះលើចន្លោះ $(0,+\infty)$ ៕

  - អតិបរមាធៀប ៖ ត្រង់ $x=0$ ដេរីវេ $f'(x)$ ប្តូរសញ្ញាពីបូក $(+)$ ទៅដក $(-)$ នាំឱ្យអនុគមន៍ $f$ មានអតិបរមាធៀបមួយត្រង់ $x=0$ គឺ ៖

$$f(0)=0-e^0=-1$$

  - គណនាលីមីត និងអាស៊ីមតូត ៖

· $\lim\limits_{x\to-\infty} f(x) = \lim\limits_{x\to-\infty}(x-e^x) = -\infty$ (ព្រោះ $\lim\limits_{x\to-\infty} e^x = 0$)

· $\lim\limits_{x\to+\infty} f(x) = \lim\limits_{x\to+\infty}(x-e^x) = \lim\limits_{x\to+\infty} e^x\left(\frac{x}{e^x}-1\right) = -\infty$ (ព្រោះ $\lim\limits_{x\to+\infty}\frac{x}{e^x} = 0$)

· អាស៊ីមតូតទ្រេត ៖ ដោយ $\lim\limits_{x\to-\infty}[f(x)-x] = \lim\limits_{x\to-\infty}(-e^x) = 0$
នាំឱ្យបន្ទាត់ $(d): y = x$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ខាង $-\infty$ ៕

○ តារាងអថេរភាព ៖


| $x$ | $-\infty$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | |
| $f(x)$ | $-\infty$ | ↗ | $-1$ | ↘ | $-\infty$ |

• សំណង់ក្រាប $(C)$ ៖

○ ចំណុចប្រសព្វរវាងក្រាប $(C)$ និងអ័ក្ស $y'Oy$ ៖
$x = 0 \implies f(0) = -1 \implies$ ក្រាបកាត់អ័ក្ស $y'Oy$ ត្រង់ចំណុច $(0,-1)$ (ជាចំណុចអតិបរមាធៀប) ៕

○ ចំណុចប្រសព្វរវាងក្រាប $(C)$ និងអ័ក្ស $x'Ox$ ៖
$y = 0 \iff x - e^x = 0 \iff e^x = x$ (គ្មានឫសក្នុង $\mathbb{R}$ ព្រោះ $e^x > x$ គ្រប់ $x$)
$\implies$ ក្រាបមិនកាត់អ័ក្ស $x'Ox$ ទេ ៕

○ ចំណុចជំនួយបន្ថែម ៖
· $x = -1 \implies y = -1 - e^{-1} \approx -1.37$
· $x = 1 \implies y = 1 - e \approx -1.72$
· $x = 2 \implies y = 2 - e^2 \approx -5.39$




ⓒ $y = xe^x$

- ដែនកំណត់ ៖
  - ដោយ $e^x$ និង $x$ កំណត់លើ $\mathbb{R}$ នាំឱ្យអនុគមន៍ $f(x) = xe^x$ មានដែនកំណត់ $D = \mathbb{R} = (-\infty, +\infty)$ ។
- ទិសដៅអថេរភាព ៖
  - ដេរីវេ ៖

$$f'(x) = (x)'e^x + x(e^x)' = e^x + xe^x = (x+1)e^x$$

$f'(x) = 0 \iff (x+1)e^x = 0 \iff x+1 = 0 \implies x = -1$ (ព្រោះ $e^x > 0 \, \forall x \in \mathbb{R}$) ។

$\cdot \; f'(x) > 0 \iff x+1 > 0 \iff x > -1 \iff x \in (-1, +\infty)$

$\cdot \; f'(x) < 0 \iff x+1 < 0 \iff x < -1 \iff x \in (-\infty, -1)$

ដូចនេះ អនុគមន៍ចុះលើចន្លោះ $(-\infty, -1)$ និងកើនលើចន្លោះ $(-1, +\infty)$ ។

  - អប្បបរមាធៀប ៖ ត្រង់ $x = -1$ ដេរីវេ $f'(x)$ ប្តូរសញ្ញាពីដក $(-)$ ទៅបូក $(+)$ នាំឱ្យអនុគមន៍ $f$ មានអប្បបរមាធៀបមួយត្រង់ $x = -1$ គឺ ៖

$$f(-1) = (-1)e^{-1} = -\frac{1}{e} \approx -0.37$$


  - គណនាលីមីត និងអាស៊ីមតូត ៖
    - $\lim\limits_{x \to -\infty} f(x) = \lim\limits_{x \to -\infty} xe^x = 0$
    - អាស៊ីមតូតដេក ៖ ដោយ $\lim\limits_{x \to -\infty} f(x) = 0$ នាំឱ្យបន្ទាត់ $y = 0$ (អ័ក្សអាប់ស៊ីស $x'Ox$) ជាអាស៊ីមតូតដេកនៃក្រាប $(C)$ ខាង $-\infty$ ។
    - $\lim\limits_{x \to +\infty} f(x) = \lim\limits_{x \to +\infty} xe^x = +\infty$
  - តារាងអថេរភាព ៖

| $x$ | $-\infty$ | | $-1$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $-$ | $0$ | $+$ | |
| $f(x)$ | $0$ | ↘ | $-\frac{1}{e}$ | ↗ | $+\infty$ |

- សំណង់ក្រាប $(C)$ ៖
  - ចំណុចប្រសព្វរវាងក្រាប $(C)$ និងអ័ក្ស $y'Oy$ ៖

$x = 0 \implies f(0) = 0 \cdot e^0 = 0 \implies$ ក្រាបកាត់អ័ក្ស $y'Oy$ ត្រង់គល់កូអរដោនេ $O(0,0)$ ។

- ចំណុចប្រសព្វរវាងក្រាប $(C)$ និងអ័ក្ស $x'Ox$ ៖
  $y=0 \iff xe^x=0 \iff x=0 \implies$ ក្រាបកាត់អ័ក្ស $x'Ox$ ត្រង់គល់កូអរដោនេ $O(0,0)$ ។
- ចំណុចជំនួយបន្ថែម ៖
  - $x=-2 \implies y=-2e^{-2}\approx -0.27$
  - $x=-1 \implies y=-\dfrac{1}{e}\approx -0.37$ (ជាចំណុចអប្បបរមាធៀប)
  - $x=1 \implies y=1\cdot e=e\approx 2.72$




**d** $y=x+e^x$

- ដែនកំណត់ ៖
  - ដោយ $e^x$ កំណត់លើ $\mathbb{R}$ នាំឱ្យអនុគមន៍ $f(x)=x+e^x$ មានដែនកំណត់ $D=\mathbb{R}=(-\infty,+\infty)$ ។
- ទិសដៅអថេរភាព ៖
  - ដេរីវេ ៖

$$f'(x)=(x)'+(e^x)'=1+e^x$$


ដោយ $e^x>0$ គ្រប់ $x\in\mathbb{R}$ នាំឱ្យ $f'(x)=1+e^x>0$ គ្រប់ $x\in\mathbb{R}$ ។
ដូចនេះ អនុគមន៍កើនដាច់ខាតលើ $\mathbb{R}=(-\infty,+\infty)$ ។

  - តម្លៃបរមា ៖ ដោយ $f'(x)>0$ គ្រប់ $x\in\mathbb{R}$ នាំឱ្យអនុគមន៍គ្មានតម្លៃបរមាធៀបទេ ។
  - គណនាលីមីត និងអាស៊ីមតូត ៖
    - $\lim\limits_{x\to-\infty} f(x)=\lim\limits_{x\to-\infty}(x+e^x)=-\infty$ (ព្រោះ $\lim\limits_{x\to-\infty}e^x=0$)
    - $\lim\limits_{x\to+\infty} f(x)=\lim\limits_{x\to+\infty}(x+e^x)=+\infty$
    - អាស៊ីមតូតទ្រេត ៖ ដោយ $\lim\limits_{x\to-\infty}[f(x)-x]=\lim\limits_{x\to-\infty}e^x=0$
      នាំឱ្យបន្ទាត់ $(d):y=x$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ខាង $-\infty$ ។

- តារាងអថេរភាព ៖

| $x$ | $-\infty$ | | $+\infty$ |
|---|---|---|---|
| $f'(x)$ | | $+$ | |
| $f(x)$ | $-\infty$ | $\nearrow$ | $+\infty$ |

- សំណង់ក្រាប $(C)$ ៖
  - ចំណុចប្រសព្វរវាងក្រាប $(C)$ និងអ័ក្ស $y'Oy$ ៖
    $x = 0 \implies f(0) = 0 + e^0 = 1 \implies$ ក្រាបកាត់អ័ក្ស $y'Oy$ ត្រង់ចំណុច $(0, 1)$ ៕
  - ចំណុចប្រសព្វរវាងក្រាប $(C)$ និងអ័ក្ស $x'Ox$ ៖
    $y = 0 \iff x + e^x = 0 \iff e^x = -x \implies x \approx -0.57 \implies$ ក្រាបកាត់អ័ក្ស $x'Ox$ ត្រង់ចំណុច $(-0.57, 0)$ ៕
  - ចំណុចជំនួយបន្ថែម ៖
    - $x = -2 \implies y = -2 + e^{-2} \approx -1.86$
    - $x = -1 \implies y = -1 + e^{-1} \approx -0.63$
    - $x = 1 \implies y = 1 + e \approx 3.72$




◈ $y = \dfrac{1}{1 + 2e^{-5x}}$

- ដែនកំណត់ ៖
  - ដោយ $e^x \neq 0$ គ្រប់ $x \in \mathbb{R}$ នាំឱ្យអនុគមន៍ $f(x) = \dfrac{x}{e^x}$ មានដែនកំណត់ $D = \mathbb{R} = (-\infty, +\infty)$ ៕
- ទិសដៅអថេរភាព ៖

- ដេរីវេ ៖

$$f'(x) = \left(\frac{x}{e^x}\right)' = \frac{(x)'e^x - x(e^x)'}{(e^x)^2} = \frac{e^x - xe^x}{e^{2x}} = \frac{1-x}{e^x}$$

$f'(x) = 0 \iff \frac{1-x}{e^x} = 0 \iff 1-x = 0 \implies x = 1$ (ព្រោះ $e^x > 0\ \forall x \in \mathbb{R}$) ៕

· $f'(x) > 0 \iff 1-x > 0 \iff x < 1 \iff x \in (-\infty, 1)$

· $f'(x) < 0 \iff 1-x < 0 \iff x > 1 \iff x \in (1, +\infty)$

ដូចនេះ អនុគមន៍កើនលើចន្លោះ $(-\infty, 1)$ និងចុះលើចន្លោះ $(1, +\infty)$ ៕

- អតិបរមាធៀប ៖ ត្រង់ $x = 1$ ដេរីវេ $f'(x)$ ប្តូរសញ្ញាពីបូក $(+)$ ទៅដក $(-)$ នាំឱ្យអនុគមន៍ $f$ មានអតិបរមាធៀបមួយត្រង់ $x = 1$ គឺ ៖

$$f(1) = \frac{1}{e^1} = \frac{1}{e} \approx 0.37$$

- គណនាលីមីត និងអាស៊ីមតូត ៖

· $\lim\limits_{x \to -\infty} f(x) = \lim\limits_{x \to -\infty} \frac{x}{e^x} = -\infty$

· $\lim\limits_{x \to +\infty} f(x) = \lim\limits_{x \to +\infty} \frac{x}{e^x} = 0$

· អាស៊ីមតូតដេក ៖ ដោយ $\lim\limits_{x \to +\infty} f(x) = 0$ នាំឱ្យបន្ទាត់ $y = 0$ (អ័ក្សអាប់ស៊ីស $x'Ox$) ជាអាស៊ីមតូតដេកនៃក្រាប $(C)$ ខាង $+\infty$ ៕

- តារាងអថេរភាព ៖

| $x$ | $-\infty$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | |
| $f(x)$ | $-\infty$ | ↗ | $\frac{1}{e}$ | ↘ | $0$ |

- សំណង់ក្រាប $(C)$ ៖

- ចំណុចប្រសព្វរវាងក្រាប $(C)$ និងអ័ក្ស $y'Oy$ ៖

$x = 0 \implies f(0) = \frac{0}{e^0} = 0 \implies$ ក្រាបកាត់អ័ក្ស $y'Oy$ ត្រង់គល់កូអរដោនេ $O(0,0)$ ៕

- ចំណុចប្រសព្វរវាងក្រាប $(C)$ និងអ័ក្ស $x'Ox$ ៖

$y = 0 \iff \frac{x}{e^x} = 0 \iff x = 0 \implies$ ក្រាបកាត់អ័ក្ស $x'Ox$ ត្រង់គល់កូអរដោនេ $O(0,0)$ ៕


- ចំណុចជំនួយបន្ថែម ៖

· $x=-1 \implies y=\dfrac{-1}{e^{-1}}=-e\approx -2.72$

· $x=1 \implies y=\dfrac{1}{e}\approx 0.37$ (ជាចំណុចអតិបរមាធៀប)

· $x=2 \implies y=\dfrac{2}{e^2}\approx 0.27$

· $x=3 \implies y=\dfrac{3}{e^3}\approx 0.15$





- ដែនកំណត់ ៖
  - ដោយ $e^{-5x}>0$ គ្រប់ $x\in\mathbb{R}$ នាំឱ្យ $1+2e^{-5x}\neq 0$ គ្រប់ $x\in\mathbb{R}$ ។
    ដូចនេះ អនុគមន៍ $f(x)=\dfrac{1}{1+2e^{-5x}}$ មានដែនកំណត់ $D=\mathbb{R}=(-\infty,+\infty)$ ។
- ទិសដៅអថេរភាព ៖
  - ដេរីវេ ៖

$$f'(x)=\left(\frac{1}{1+2e^{-5x}}\right)'=\frac{-(1+2e^{-5x})'}{(1+2e^{-5x})^2}=\frac{10e^{-5x}}{(1+2e^{-5x})^2}$$

    ដោយ $e^{-5x}>0$ គ្រប់ $x\in\mathbb{R}$ នាំឱ្យ $f'(x)>0$ គ្រប់ $x\in\mathbb{R}$ ។
    ដូចនេះ អនុគមន៍កើនដាច់ខាតលើ $\mathbb{R}=(-\infty,+\infty)$ ។
  - តម្លៃបរមា ៖ ដោយ $f'(x)>0$ គ្រប់ $x\in\mathbb{R}$ នាំឱ្យអនុគមន៍គ្មានតម្លៃបរមាធៀបទេ ។
  - គណនាលីមីត និងអាស៊ីមតូត ៖
    · $\lim\limits_{x\to-\infty}f(x)=\lim\limits_{x\to-\infty}\dfrac{1}{1+2e^{-5x}}=0$ (ព្រោះ $\lim\limits_{x\to-\infty}e^{-5x}=+\infty$)
    នាំឱ្យបន្ទាត់ $y=0$ (អ័ក្សអាប់ស៊ីស $x'Ox$) ជាអាស៊ីមតូតដេកនៃក្រាប $(C)$ ខាង $-\infty$ ។
    · $\lim\limits_{x\to+\infty}f(x)=\lim\limits_{x\to+\infty}\dfrac{1}{1+2e^{-5x}}=1$ (ព្រោះ $\lim\limits_{x\to+\infty}e^{-5x}=0$)
    នាំឱ្យបន្ទាត់ $y=1$ ជាអាស៊ីមតូតដេកនៃក្រាប $(C)$ ខាង $+\infty$ ។
  - តារាងអថេរភាព ៖

| $x$ | $-\infty$ $\quad\quad$ $+\infty$ |
|---|---|
| $f'(x)$ | $+$ |
| $f(x)$ | $0 \nearrow 1$ |

- សំណង់ក្រាប $(C)$ ៖
  - ចំណុចប្រសព្វរវាងក្រាប $(C)$ និងអ័ក្ស $y'Oy$ ៖
    $x=0 \implies f(0)=\dfrac{1}{1+2e^0}=\dfrac{1}{3} \implies$ ក្រាបកាត់អ័ក្ស $y'Oy$ ត្រង់ចំណុច $\left(0,\dfrac{1}{3}\right)$ ។
  - ចំណុចប្រសព្វរវាងក្រាប $(C)$ និងអ័ក្ស $x'Ox$ ៖
    $y=0 \iff \dfrac{1}{1+2e^{-5x}}=0$ (គ្មានឫស) $\implies$ ក្រាបមិនកាត់អ័ក្ស $x'Ox$ ទេ ។
  - ចំណុចជំនួយបន្ថែម ៖
    - $x=-0.5 \implies y=\dfrac{1}{1+2e^{2.5}}\approx 0.04$
    - $x=\dfrac{\ln 2}{5}\approx 0.14 \implies y=\dfrac{1}{2}=0.5$ (ជាចំណុចរបត់)
    - $x=0.5 \implies y=\dfrac{1}{1+2e^{-2.5}}\approx 0.86$




ⓕ $y=\dfrac{x}{e^x}$

- ដែនកំណត់ ៖
  - ដោយ $e^x\neq 0$ គ្រប់ $x\in\mathbb{R}$ នាំឱ្យអនុគមន៍ $f(x)=\dfrac{x}{e^x}$ មានដែនកំណត់ $D=\mathbb{R}=(-\infty,+\infty)$ ។
- ទិសដៅអថេរភាព ៖

- ដេរីវេ ៖

$$f'(x) = \left(\frac{x}{e^x}\right)' = \frac{(x)'e^x - x(e^x)'}{(e^x)^2} = \frac{e^x - xe^x}{e^{2x}} = \frac{1-x}{e^x}$$

$f'(x) = 0 \iff \frac{1-x}{e^x} = 0 \iff 1-x = 0 \implies x = 1$ (ព្រោះ $e^x > 0\ \forall x \in \mathbb{R}$) ។

· $f'(x) > 0 \iff 1-x > 0 \iff x < 1 \iff x \in (-\infty, 1)$

· $f'(x) < 0 \iff 1-x < 0 \iff x > 1 \iff x \in (1, +\infty)$

ដូចនេះ អនុគមន៍កើនលើចន្លោះ $(-\infty, 1)$ និងចុះលើចន្លោះ $(1, +\infty)$ ។

- អតិបរមាធៀប ៖ ត្រង់ $x = 1$ ដេរីវេ $f'(x)$ ប្តូរសញ្ញាពីបូក $(+)$ ទៅដក $(-)$ នាំឱ្យអនុគមន៍ $f$ មានអតិបរមាធៀបមួយត្រង់ $x = 1$ គឺ ៖

$$f(1) = \frac{1}{e^1} = \frac{1}{e} \approx 0.37$$

- គណនាលីមីត និងអាស៊ីមតូត ៖

· $\lim\limits_{x \to -\infty} f(x) = \lim\limits_{x \to -\infty} \frac{x}{e^x} = -\infty$

· $\lim\limits_{x \to +\infty} f(x) = \lim\limits_{x \to +\infty} \frac{x}{e^x} = 0$

· អាស៊ីមតូតដេក ៖ ដោយ $\lim\limits_{x \to +\infty} f(x) = 0$ នាំឱ្យបន្ទាត់ $y = 0$ (អ័ក្សអាប់ស៊ីស $x'Ox$) ជាអាស៊ីមតូតដេកនៃក្រាប $(C)$ ខាង $+\infty$ ។

- តារាងអថេរភាព ៖

| $x$ | $-\infty$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | |
| $f(x)$ | $-\infty$ | ↗ | $\frac{1}{e}$ | ↘ | $0$ |

- សំណង់ក្រាប $(C)$ ៖

- ចំណុចប្រសព្វរវាងក្រាប $(C)$ និងអ័ក្ស $y'Oy$ ៖

$x = 0 \implies f(0) = \frac{0}{e^0} = 0 \implies$ ក្រាបកាត់អ័ក្ស $y'Oy$ ត្រង់គល់កូអរដោនេ $O(0,0)$ ។

- ចំណុចប្រសព្វរវាងក្រាប $(C)$ និងអ័ក្ស $x'Ox$ ៖

$y = 0 \iff \frac{x}{e^x} = 0 \iff x = 0 \implies$ ក្រាបកាត់អ័ក្ស $x'Ox$ ត្រង់គល់កូអរដោនេ $O(0,0)$ ។


- ចំណុចជំនួយបន្ថែម ៖

· $x=-1 \implies y=\dfrac{-1}{e^{-1}}=-e\approx -2.72$

· $x=1 \implies y=\dfrac{1}{e}\approx 0.37$ (ជាចំណុចអតិបរមាធៀប)

· $x=2 \implies y=\dfrac{2}{e^2}\approx 0.27$

· $x=3 \implies y=\dfrac{3}{e^3}\approx 0.15$




**2** $f$ ជាអនុគមន៍កំណត់ដោយ $f(x)=e^{1-x}$ ហើយ $C$ ជាក្រាបរបស់ $f$ ។

**a** បញ្ជាក់ដែនកំណត់នៃ $f$ និងបង្ហាញថា $f$ ជាអនុគមន៍ចុះលើ $\mathbb{R}$ ៖

○ ដោយកន្សោម $1-x$ កំណត់បានគ្រប់ $x\in\mathbb{R}$ នាំឱ្យដែនកំណត់នៃអនុគមន៍ $f$ គឺ ៖

$$D=\mathbb{R}=(-\infty,+\infty)$$

○ ដេរីវេ ៖ $f'(x)=(1-x)'e^{1-x}=-e^{1-x}$

ដោយ $e^{1-x}>0$ គ្រប់ $x\in\mathbb{R}$ នាំឱ្យ $f'(x)=-e^{1-x}<0$ គ្រប់ $x\in\mathbb{R}$ ។

ដូចនេះ អនុគមន៍ $f$ ជាអនុគមន៍ចុះដាច់ខាតលើ $\mathbb{R}$ ។

**b** គណនាលីមីត និងបកស្រាយសមីការអាស៊ីមតូត ៖

○ $\lim\limits_{x\to+\infty} f(x)=\lim\limits_{x\to+\infty} e^{1-x}=0$ (ព្រោះ $\lim\limits_{x\to+\infty}(1-x)=-\infty$)

○ $\lim\limits_{x\to-\infty} f(x)=\lim\limits_{x\to-\infty} e^{1-x}=+\infty$ (ព្រោះ $\lim\limits_{x\to-\infty}(1-x)=+\infty$)

○ អាស៊ីមតូត ៖ ដោយ $\lim\limits_{x\to+\infty} f(x)=0$ នាំឱ្យបន្ទាត់ $y=0$ (អ័ក្សអាប់ស៊ីស $x'Ox$) ជាអាស៊ីមតូតដេកនៃក្រាប $(C)$ ខាង $+\infty$ ។

**c** តារាងអថេរភាពនៃ $f$ ៖

| $x$ | $-\infty$ $\quad\quad$ $+\infty$ |
|---|---|
| $f'(x)$ | $-$ |
| $f(x)$ | $+\infty$ ↘ $0$ |

ⓓ គណនាចំណុចប្រសព្វរវាងក្រាប $C$ និងអ័ក្សកូអរដោនេ ៖


- ប្រសព្វជាមួយអ័ក្សអាប់ស៊ីស $x'Ox$ $(y=0)$ ៖
  $y=0 \iff e^{1-x}=0$ (គ្មានឫស ព្រោះ $e^{1-x}>0\ \forall x\in\mathbb{R}$) $\implies$ ក្រាប $C$ មិនកាត់អ័ក្សអាប់ស៊ីស $x'Ox$ ទេ ៕
- ប្រសព្វជាមួយអ័ក្សអរដោនេ $y'Oy$ $(x=0)$ ៖
  $x=0 \implies f(0)=e^{1-0}=e\approx 2.7 \implies$ ក្រាប $C$ កាត់អ័ក្សអរដោនេ $y'Oy$ ត្រង់ចំណុច $(0,e)\approx(0,2.7)$ ៕

ⓔ សរសេរសមីការបន្ទាត់បន្ទាត់ប៉ះ $L$ ត្រង់ $x=1$ ៖

- រូបមន្តសមីការបន្ទាត់បន្ទាត់ប៉ះ ៖ $L: y=f'(x_0)(x-x_0)+f(x_0)$ ត្រង់ $x_0=1$
- គណនា ៖ $f(1)=e^{1-1}=e^0=1$
- គណនា ៖ $f'(1)=-e^{1-1}=-e^0=-1$
- នាំឱ្យសមីការបន្ទាត់ប៉ះ $L$ គឺ ៖

$$L: y=-1(x-1)+1 \iff y=-x+2$$

ⓕ សង់ក្រាប $C$ និងបន្ទាត់បន្ទាត់ប៉ះ $L$ ៖




3 គេឲ្យអនុគមន៍ $g$ មួយកំណត់ដោយ $g(x)=e^x+ax+b$

ⓐ គណនា $g'(x), g''(x)$ និងបកស្រាយ $g''(x) > 0$ ៖

- ដេរីវេទី១ ៖ $g'(x) = (e^x + ax + b)' = e^x + a$
- ដេរីវេទី២ ៖ $g''(x) = (e^x + a)' = e^x$
- បកស្រាយ ៖ ដោយ $e^x > 0$ គ្រប់ $x \in \mathbb{R}$ នាំឱ្យ $g''(x) = e^x > 0$ ចំពោះគ្រប់ $a, b \in \mathbb{R}$ ទាំងអស់ ៕

  ការណ៍នេះបញ្ជាក់ថា ដេរីវេ $g'(x)$ ជាអនុគមន៍កើនដាច់ខាតលើ $\mathbb{R}$ ហើយក្រាប $C$ នៃអនុគមន៍ $g$ មានភាពប៉ោងរងើកឡើងលើគ្រប់ $x \in \mathbb{R}$ ៕

ⓑ គណនា $a$ និង $b$ ៖

- បន្ទាត់ប៉ះនឹងខ្សែកោង $C$ ត្រង់គល់ $O(0,0)$ នាំឱ្យ ៖
  - ក្រាប $C$ ឆ្លងកាត់គល់ $O(0,0) \implies g(0) = 0$ ៖

$$g(0) = e^0 + a(0) + b = 1 + b = 0 \implies b = -1$$

  - បន្ទាត់ប៉ះត្រង់ $O(0,0)$ ស្របនឹងអ័ក្ស $(x'Ox)$ នាំឱ្យមេគុណប្រាប់ទិសស្មើ 0 គឺ $g'(0) = 0$ ៖

$$g'(0) = e^0 + a = 1 + a = 0 \implies a = -1$$

ដូចនេះ យើងបាន $a = -1$ និង $b = -1$ ៕

ⓒ គណនា $g'(x)$ និងសង់តារាងអថេរភាព ៖

- ជំនួស $a = -1, b = -1$ យើងបាន $g(x) = e^x - x - 1$
- $g'(x) = e^x - 1$
- $g'(x) = 0 \iff e^x - 1 = 0 \iff e^x = 1 \implies x = 0$
- $g'(x) > 0 \iff e^x > 1 \iff x > 0$
- $g'(x) < 0 \iff e^x < 1 \iff x < 0$
- តម្លៃអប្បបរមាធៀបត្រង់ $x = 0$ គឺ $g(0) = e^0 - 0 - 1 = 0$
- តារាងអថេរភាពនៃ $g$ ៖

| $x$ | $-\infty$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $g'(x)$ | | $-$ | $0$ | $+$ | |
| $g(x)$ | $\searrow$ | | $0$ | | $\nearrow$ |

ⓓ គណនាលីមីត អាស៊ីមតូតទ្រេត សញ្ញា $g(x)$ និងស្រាយបញ្ជាក់ $e^x \geq 1 + x$ ៖


- $\lim\limits_{x \to -\infty} g(x) = \lim\limits_{x \to -\infty} (e^x - x - 1) = 0 - (-\infty) - 1 = +\infty$

- $\lim\limits_{x\to+\infty} g(x) = \lim\limits_{x\to+\infty}(e^x - x - 1) = \lim\limits_{x\to+\infty} e^x\left(1 - \dfrac{x}{e^x} - \dfrac{1}{e^x}\right) = +\infty$
- អាស៊ីមតូតទ្រេត ៖
  ដោយ $\lim\limits_{x\to-\infty}[g(x) - (-x-1)] = \lim\limits_{x\to-\infty} e^x = 0$
  នាំឱ្យបន្ទាត់ $(d) : y = -x - 1$ ជាអាស៊ីមតូតទ្រេតនៃក្រាប $C$ ខាង $-\infty$ ៕
- ទាញរកសញ្ញានៃ $g(x)$ ៖
  តាមតារាងអថេរភាព $g(x)$ មានតម្លៃអប្បបរមាស្មើ $0$ ត្រង់ $x = 0$ នាំឱ្យ ៖

$$g(x) \geq 0 \quad \forall x \in \mathbb{R}$$

- ស្រាយបញ្ជាក់ថា $e^x \geq 1 + x, \forall x \in \mathbb{R}$ ៖
  ដោយ $g(x) \geq 0 \quad \forall x \in \mathbb{R} \iff e^x - x - 1 \geq 0 \iff e^x \geq 1 + x \quad \forall x \in \mathbb{R}$ ៕

(e) សង់ខ្សែកោង $C$ និងអាស៊ីមតូតទ្រេត $(d)$ ៖




(f) ពិភាក្សាចំនួនឫសនៃសមីការ $e^x - 1 = m + x$ តាមប៉ារ៉ាម៉ែត្រ $m$ ៖

- សមីការអាស្រ័យ ៖ $e^x - 1 = m + x \iff e^x - x - 1 = m \iff g(x) = m$
- ចំនួនឫសនៃសមីការ ជាចំនួនចំណុចប្រសព្វរវាងខ្សែកោង $C : y = g(x)$ និងបន្ទាត់ដេក $y = m$ ៖
  - បើ $m < 0$ ៖ បន្ទាត់ $y = m$ មិនកាត់ខ្សែកោង $C$ ទេ $\implies$ សមីការ**គ្មានឫស** ៕
  - បើ $m = 0$ ៖ បន្ទាត់ $y = 0$ (អ័ក្ស $x'Ox$) ប៉ះខ្សែកោង $C$ ត្រង់ $x = 0$ $\implies$ សមីការមាន**ឫសឌុប $x = 0$** ៕
  - បើ $m > 0$ ៖ បន្ទាត់ $y = m$ កាត់ខ្សែកោង $C$ ត្រង់ពីរចំណុចផ្សេងគ្នា $\implies$ សមីការមាន**ឫសពីរផ្សេងគ្នា** ៕

(g) គណនាផ្ទៃក្រឡា $S$ ៖

- ដោយ $g(x) \geq 0$ គ្រប់ $x \in [0,1]$ នាំឱ្យផ្ទៃក្រឡា $S$ គណនាដោយ ៖

$$S = \int_0^1 g(x)\,dx = \int_0^1 (e^x - x - 1)\,dx$$

$$S = \left[e^x - \frac{x^2}{2} - x\right]_0^1 = \left(e^1 - \frac{1^2}{2} - 1\right) - (e^0 - 0 - 0)$$

$$S = e - \frac{3}{2} - 1 = e - \frac{5}{2} \approx 0.22 \text{ (ឯកតាផ្ទៃ)}$$

## ២.៥ អនុវត្តន៍

គេប្រើអនុគមន៍អិចស្ប៉ូណង់ស្យែលគោល $e$ សម្រាប់គណនាកំណើន និងតំហាយចុះ ។

**លំហាត់គំរូ ១** ជំងឺអាសន្នរោគកើតឡើងដោយបាក់តេរីក្នុងពោះវៀនដែលបំបែកខ្លួនតាមរូបមន្ត អិចស្ប៉ូណង់ស្យែល $N = N_0 e^{1.386t}$ , $N$ ជាចំនួនបាក់តេរីក្រោយពេល $t$ ម៉ោង ហើយ $N_0$ ជាចំនួនបាក់តេរីនៅខណៈ $t = 0$ ។ បើបាក់តេរីចាប់ផ្តើមពី ចំនួន 1 តើមានបាក់តេរីប៉ុន្មាននៅរយៈពេល :

(a) 5 ម៉ោង ? (b) 12 ម៉ោង ?

**ដំណោះស្រាយ**

(a) បើ $N_0 = 1$ និង $t = 5$ នោះ $N = N_0 e^{1.386t}$ ឬ $N = e^{1.386(5)} = 1022$

(b) បើ $N_0 = 1$ និង $t = 12$ នោះ $N = N_0 e^{1.386t}$ ឬ $N = e^{1.386(12)} = 16718057$ ។

**សម្គាល់**

**រូបមន្តការប្រាក់សមាស** $\boxed{A = p\left(1 + \frac{r}{n}\right)^{nt}}$ ដែល $p$ជាប្រាក់ដើម $r$ជាអត្រាការប្រាក់ប្រចាំឆ្នាំ $n$ ជាចំនួនដងនៃការទូទាត់ក្នុងមួយឆ្នាំ $A$ ជាចំនួនប្រាក់សរុបក្នុងរយៈពេល $t$ឆ្នាំ។

**ចំណាំ** បើចំនួនដងនៃការទូទាត់ច្រើនអនន្ត ឬការទូទាត់ជាបន្តបន្ទាប់ នោះរូបមន្តការប្រាក់សមាសកំណត់ដោយ $\boxed{A = p \cdot e^{rt}}$

**លំហាត់គំរូ 1** បើយកប្រាក់ 100 ដុល្លារទៅធ្វើវិនិយោគដោយទទួលបានអត្រាការប្រាក់សមាស 8% ក្នុងមួយឆ្នាំ ។ តើគេបានប្រាក់សរុបប៉ុន្មាន បើគេដាក់ប្រាក់រយៈពេល 2 ឆ្នាំ ហើយចំនួនដងនៃការទូទាត់ច្រើនអនន្ត ?

តាមរូបមន្តការប្រាក់សមាស $A = pe^{rt}$ ដែល $p = 100$ , $r = 0.08$ , $r = 2$ ។

គេបាន $A = pe^{rt} = 100e^{0.08(2)}$

$= 117.35$ លទ្ធផលនេះផ្ទៀងផ្ទាត់ទៅនឹងតារាងតម្លៃខាងលើ ។

**លំហាត់គំរូ 2** តម្លៃនៅសល់របស់ម៉ាស៊ីនមួយកំណត់ដោយ $f(x) = 100000e^{-0.1t}$ ។

ⓐ រកតម្លៃដើមដំបូង(ថ្លៃទិញ) របស់ម៉ាស៊ីន

ⓑ រកតម្លៃនៅសល់របស់ម៉ាស៊ីនបន្ទាប់ពីប្រើប្រាស់ 5 ឆ្នាំ ។

## ដំណោះស្រាយ

ⓐ តម្លៃដើមដំបូងរបស់ម៉ាស៊ីន ជាតម្លៃដែលត្រូវនឹង $t = 0$

គេបាន $f(0) = 100000e^{-0.1(0)} = 100000$ ។

ដូច្នេះ តម្លៃដើមរបស់ម៉ាស៊ីនគឺ 100000 ដុល្លារ ។

ⓑ តម្លៃនៅសល់របស់ម៉ាស៊ីនបន្ទាប់ពីប្រើប្រាស់ 5 ឆ្នាំ ជាតម្លៃដែលត្រូវនឹង $t = 5$

គេបាន $f(5) = 100000e^{-0.1(5)} = 60650$ ។

ដូច្នេះ តម្លៃនៅសល់ម៉ាស៊ីនបន្ទាប់ពីប្រើប្រាស់ 5 ឆ្នាំ គឺ 60650 ដុល្លារ ។

## ប្រតិបត្តិ

ⓐ សង់ក្រាបនៃអនុគមន៍ដែលមានសមីការ $N = e^{1.386t}$ ចំពោះ $0 \leq t \leq 5$ ។

ⓑ គេយកប្រាក់ 100 ដុល្លារទៅចងការរយៈពេល 9 ឆ្នាំ ដោយទទួលបានអត្រាការប្រាក់សមាស 12% ក្នុងមួយឆ្នាំ ។ តើគេបានប្រាក់សរុបប៉ុន្មាន បើគេទូទាត់ 1 ឆ្នាំម្តង ? មួយត្រីមាសម្តង ? ជាបន្តបន្ទាប់ ?

ⓒ នៅឆ្នាំ 1970 ទីក្រុងមួយមានចំនួនប្រជាជន 30000 នាក់ និងមាន 40500 នាក់នៅឆ្នាំ 1980 ។ ប្រសិនបើរបមន្ត $p(t) = p_0e^{kt}$ ($p_0$ ជាចំនួនប្រជាជននៅដើមគ្រា ហើយ $k$ ជាអត្រាកំណើនមធ្យម) ត្រូវបានគេយកមកប្រើ ដើម្បីរកចំនួនប្រជាជននៅក្នុងទីក្រុងនេះ តើឆ្នាំ 2008 ទីក្រុងនេះមានប្រជាជនចំនួនប៉ុន្មាននាក់ ?


## ចម្លើយ

ⓐ

- ការសិក្សា និងតារាងតម្លៃលឿន ៖
  - អនុគមន៍ $N(t) = e^{1.386t}$ កំណត់លើចន្លោះ $[0,5]$ ។
  - ដោយ $N'(t) = 1.386e^{1.386t} > 0$ គ្រប់ $t \in [0,5]$ នាំឱ្យអនុគមន៍ $N$ កើនដាច់ខាតលើ $[0,5]$ ។
  - តារាងតម្លៃជំនួយ ៖

| $t$ | 0 | 1 | 2 | 3 | 4 | 5 |
|---|---|---|---|---|---|---|
| $N$ | 1 | $e^{1.386} \approx 4$ | $e^{2.772} \approx 16$ | $e^{4.158} \approx 64$ | $e^{5.544} \approx 256$ | $e^{6.93} \approx 1024$ |

- សំណង់ក្រាប ៖




(b) 277.30, 289.82, 294.46 គិតជាដុល្លារ

(c) 93812នាក់

## លំហាត់

1. មនុស្សម្នាក់បានទិញរថយន្តថ្មីមួយគ្រឿងម៉ាកតូយ៉ូតាកាម៉ារី ក្នុងតម្លៃ3900 ដុល្លារ ។ រថយន្តនោះចុះថ្លៃ14%ជារៀងរាល់ឆ្នាំ ។ រកតម្លៃរថយន្តក្នុងរយៈពេល10ឆ្នាំក្រោយ ។
2. បើគេយកប្រាក់ 100 ដុល្លារទៅធ្វើវិនិយោគដោយទទួលបានអត្រាការប្រាក់សមាស8% ក្នុងមួយឆ្នាំ ។ តើគេបានប្រាក់សរុបប៉ុន្មាន បើគេដាក់ប្រាក់ រយៈពេល 2 ឆ្នាំ ហើយចំនួនដងនៃការទូទាត់ច្រើនអនន្ត ?
3. តម្លៃនៅសល់របស់ម៉ាស៊ីនមួយកំណត់ដោយ $f(x) = 100000e^{-0.1t}$ ។
   (a) រកថ្លៃដើមដំបូង (ថ្លៃទិញ) របស់ប៉ាស៊ីន
   (b) រកថ្លៃនៅសល់របស់ម៉ាស៊ីនបន្ទាប់ពីប្រើប្រាស់ 5 ឆ្នាំ ។
4. គេយកប្រាក់ 100 ដុល្លារទៅចងការរយៈពេល 1 ឆ្នាំ ដោយទទួលបានអត្រា ការប្រាក់សមាស 12% ក្នុងមួយឆ្នាំ ។ តើគេបានប្រាក់សរុបប៉ុន្មាន បើគេទូទាត់ 1ឆ្នាំម្តង ? មួយត្រីមាសម្តង ? ជាបន្តបន្ទាប់ ?
5. នៅឆ្នាំ 1970 ទីក្រុងមួយមានចំនួនប្រជាជន 30000 នាក់ និងមាន 40500 នាក់ នៅឆ្នាំ 1980 ។ ប្រសិនបើរូបមន្ត $p(t) = p_0e^{kt}$($p_0$ ជាចំនួនប្រជាជននៅ ដើមត្រា ហើយ $k$ ជាអត្រាកំណើនមធ្យម) ត្រូវបានគេយកមកប្រើ ដើម្បី រកចំនួនប្រជាជននៅក្នុងទីក្រុងនេះ តើឆ្នាំ 2008 ទីក្រុងនេះមានប្រជាជន ចំនួនប៉ុន្មាននាក់ ?

## ដំណោះស្រាយ

1. មនុស្សម្នាក់បានទិញរថយន្តថ្មីមួយគ្រឿងម៉ាកតូយ៉ូតាកាម៉ារី ក្នុងតម្លៃ3900 ដុល្លារ ។ រថយន្តនោះចុះថ្លៃ14%ជារៀងរាល់ឆ្នាំ ។ រកតម្លៃរថយន្តក្នុងរយៈពេល10ឆ្នាំក្រោយ ។
   តាមរូបមន្តរំលស់ថ្លៃ (Depreciation Formula) ៖

$$V(t) = V_0(1 - r)^t$$

ដែល ៖

- $V_0 = 3900$ ដុល្លារ (តម្លៃដើមនៃរថយន្ត)
- $r = 14\% = 0.14$ (អត្រាចុះថ្លៃប្រចាំឆ្នាំ)
- $t = 10$ ឆ្នាំ (រយៈពេល)

ជំនួសតម្លៃចូលរូបមន្ត យើងបាន ៖

$$V(10) = 3900 \times (1 - 0.14)^{10}$$

$$V(10) = 3900 \times (0.86)^{10}$$

ដោយ $(0.86)^{10} \approx 0.2213016$
នាំឱ្យ ៖

$$V(10) \approx 3900 \times 0.2213016 \approx 863.08 \text{ ដុល្លារ}$$

ដូចនេះ តម្លៃរថយន្តក្នុងរយៈពេល 10 ឆ្នាំក្រោយគឺប្រហែល **863.08 ដុល្លារ** ។

**2** បើគេយកប្រាក់ 100 ដុល្លារទៅធ្វើវិនិយោគដោយទទួលបានអត្រាការប្រាក់សមាស8% ក្នុងមួយឆ្នាំ ។ តើគេបានប្រាក់សរុបប៉ុន្មាន បើគេដាក់ប្រាក់ រយៈពេល 2 ឆ្នាំ ហើយចំនួនដងនៃការទូទាត់ច្រើនអនន្ត ?
កាលណាការប្រាក់សមាសត្រូវទូទាត់ច្រើនដងរហូតដល់អនន្ត នោះជា**ការប្រាក់សមាសបន្តបន្ទាប់** (Continuous Compounding) តាមរូបមន្ត ៖

$$A = P \cdot e^{rt}$$

ដែល ៖

- $P = 100$ ដុល្លារ (ប្រាក់ដើមដំបូង)
- $r = 8\% = 0.08$ (អត្រាការប្រាក់ប្រចាំឆ្នាំ)
- $t = 2$ ឆ្នាំ (រយៈពេល)

ជំនួសតម្លៃចូលរូបមន្ត យើងបាន ៖

$$A = 100 \times e^{0.08 \times 2} = 100 \times e^{0.16}$$

ដោយ $e^{0.16} \approx 1.17351$
នាំឱ្យ ៖

$$A \approx 100 \times 1.17351 \approx 117.35 \text{ ដុល្លារ}$$

ដូចនេះ ប្រាក់សរុបដែលទទួលបានក្នុងរយៈពេល 2 ឆ្នាំគឺប្រហែល **117.35 ដុល្លារ** ។

**3** តម្លៃនៅសល់របស់ម៉ាស៊ីនមួយកំណត់ដោយ $f(x) = 100000e^{-0.1t}$ ។

**a** រកថ្លៃដើមដំបូង (ថ្លៃទិញ) របស់ម៉ាស៊ីន ៖

- ថ្លៃដើមដំបូងត្រូវគិតត្រង់ខណៈ $t = 0$ ឆ្នាំ ៖

$$f(0) = 100000e^{-0.1(0)} = 100000e^{0} = 100000 \times 1 = 100000$$

ដូចនេះ ថ្លៃដើមដំបូងរបស់ម៉ាស៊ីនគឺ **100000** ដុល្លារ (ឬឯកតាតម្លៃ) ។

**b** រកថ្លៃនៅសល់របស់ម៉ាស៊ីនបន្ទាប់ពីប្រើប្រាស់ 5 ឆ្នាំ ៖

- ជំនួស $t = 5$ ចូលក្នុងអនុគមន៍ $f(t)$ យើងបាន ៖

$$f(5) = 100000e^{-0.1(5)} = 100000e^{-0.5}$$

ដោយ $e^{-0.5} \approx 0.60653$

$$f(5) \approx 100000 \times 0.60653 \approx 60653$$

ដូចនេះ ថ្លៃនៅសល់របស់ម៉ាស៊ីនបន្ទាប់ពីប្រើប្រាស់ 5 ឆ្នាំគឺប្រហែល **60653** ដុល្លារ ។

**4** គេយកប្រាក់ 100 ដុល្លារទៅចងការរយៈពេល 1 ឆ្នាំ ដោយទទួលបានអត្រា ការប្រាក់សមាស 12% ក្នុងមួយឆ្នាំ ។ តើគេបានប្រាក់សរុបប៉ុន្មាន បើគេទូទាត់ 1ឆ្នាំម្តង ? មួយត្រីមាសម្តង ? ជាបន្តបន្ទាប់ ?
រូបមន្តការប្រាក់សមាសទូទៅ ៖ $A = P\left(1 + \frac{r}{n}\right)^{nt}$
និងរូបមន្តការប្រាក់សមាសបន្តបន្ទាប់ ៖ $A = P \cdot e^{rt}$
ដែល ៖

- $P = 100$ ដុល្លារ (ប្រាក់ដើមដំបូង)
- $r = 12\% = 0.12$ (អត្រាការប្រាក់ប្រចាំឆ្នាំ)
- $t = 1$ ឆ្នាំ (រយៈពេល)

a) បើទូទាត់ 1 ឆ្នាំម្តង ($n = 1$) ៖

$$A = 100 \times \left(1 + \frac{0.12}{1}\right)^{1\times1} = 100 \times 1.12 = 112 \text{ ដុល្លារ}$$

b) បើទូទាត់មួយត្រីមាសម្តង ($n = 4$) ៖

$$A = 100 \times \left(1 + \frac{0.12}{4}\right)^{4\times1} = 100 \times (1 + 0.03)^4 = 100 \times (1.03)^4$$

ដោយ $(1.03)^4 \approx 1.12551$

$$A \approx 100 \times 1.12551 \approx 112.55 \text{ ដុល្លារ}$$

c) បើទូទាត់ជាបន្តបន្ទាប់ ($n \to \infty$) ៖

$$A = 100 \times e^{0.12 \times 1} = 100 \times e^{0.12}$$

ដោយ $e^{0.12} \approx 1.1275$

$$A \approx 100 \times 1.1275 \approx 112.75 \text{ ដុល្លារ}$$

**5** នៅឆ្នាំ 1970 ទីក្រុងមួយមានចំនួនប្រជាជន 30000 នាក់ និងមាន 40500 នាក់ នៅឆ្នាំ 1980។ ប្រសិនបើរូបមន្ត $p(t) = p_0 e^{kt}$ ($p_0$ ជាចំនួនប្រជាជននៅ ដើមត្រា ហើយ $k$ ជាអត្រាកំណើនមធ្យម) ត្រូវបានគេយកមកប្រើ ដើម្បីរកចំនួនប្រជាជននៅក្នុងទីក្រុងនេះ តើឆ្នាំ 2008 ទីក្រុងនេះមានប្រជាជន ចំនួនប៉ុន្មាននាក់?
រូបមន្តកំណើនប្រជាជន ៖ $p(t) = p_0 e^{kt}$
យកឆ្នាំ 1970 ជាគល់នៃការរាប់ពេលវេលា ($t = 0$) ៖

- នៅឆ្នាំ 1970 ($t = 0$) ៖ $p(0) = p_0 = 30000$ នាក់
- នៅឆ្នាំ 1980 ($t = 1980 - 1970 = 10$ ឆ្នាំ) ៖ $p(10) = 40500$ នាក់

១. ស្វែងរកអត្រាកំណើន $k$ ៖

$$p(10) = 30000 e^{10k} = 40500$$

$$e^{10k} = \frac{40500}{30000} = 1.35$$

$$10k = \ln(1.35) \implies k = \frac{\ln(1.35)}{10} \approx 0.03001$$

២. គណនាចំនួនប្រជាជននៅឆ្នាំ 2008 ($t = 2008 - 1970 = 38$ ឆ្នាំ) ៖

$$p(38) = 30000 e^{38k} = 30000 \times \left(e^{10k}\right)^{\frac{38}{10}}$$

$$p(38) = 30000 \times (1.35)^{3.8}$$

ដោយ $(1.35)^{3.8} \approx 3.12801$
នាំឱ្យ ៖ $p(38) \approx 30000 \times 3.12801 \approx 93840$ នាក់
ដូចនេះ នៅឆ្នាំ 2008 ទីក្រុងនេះមានប្រជាជនប្រហែល **93840** នាក់ ៕

# ក្រុមលំហាត់បន្ថែម

**1** គណនលីមីតខាងក្រោម ៖

ⓐ $\lim\limits_{x\to+\infty} xe^{x+1}$ ⓑ $\lim\limits_{x\to-\infty} x^2e^{4x}$ ⓒ $\lim\limits_{x\to+\infty}\left(1+\frac{n}{x}\right)^x$

**2** គណនលីមីតអនុគមន៍ខាងក្រោម ៖

ⓐ $\lim\limits_{x\to+\infty}\frac{3e^{x-2}}{x^3}$ ⓑ $\lim\limits_{x\to+\infty}\left(\frac{x+3}{x-1}\right)^{x+2}$ ⓒ $\lim\limits_{x\to0}\frac{e^x-e^{-x}}{x}$

**3** គណនដេរីវេនៃអនុគមន៍ខាងក្រោម ៖

ⓐ $y=xe^{-x}$ ⓑ $f(x)=x^2e^x$ ⓒ $g(x)=\frac{e^x-e^{-x}}{e^x+e^{-x}}$

**4** គណនដេរីវេនៃអនុគមន៍ខាងក្រោម ៖

ⓐ $y=\frac{e^x+e^{-x}}{2}$ ⓑ $f(x)=\frac{e^x(1+\cos x)}{1-\cos x}$ ⓒ $g(x)=e^{x+1}\cdot x^{\frac{x-1}{1}}$

**5** សិក្សាអថេរភាព និងសង់ក្រាបតាងអនុគមន៍ខាងក្រោម

ⓐ $y=x^2e^{-x}$ ⓑ $y=5+2e^{-x}$ ⓒ $g(x)=e^{-x}-x^2$

**6** រកប្រាក់សរុបនៃប្រាក់ដើមចំនួន 2000 ដុល្លារ ដែលគេបានធ្វើវិនិយោគក្នុងរយៈពេល 4 ឆ្នាំ ដោយទទួលអត្រាការប្រាក់ 6% តាមរយៈពេលកំណត់ដូចខាងក្រោម ៖

ⓐ គិតជាឆ្នាំ ⓑ គិតជាឆមាស ⓒ គិតជាត្រីមាស ⓓ គិតជាខែ

**7** ឧបមាថា គេយកប្រាក់5000 ដុល្លារ ទៅផ្ញើនៅធនាគារមួយដោយទទួលបានអត្រាការប្រាក់ សមាស 11% ក្នុងមួយឆ្នាំ ។ បើគេផ្ញើប្រាក់រយៈពេល 10 ឆ្នាំ ។ តើគេទទួលបានប្រាក់សរុប ទាំងអស់ចំនួនប៉ុន្មាន បើការទូទាត់ច្រើនដងក្នុងមួយឆ្នាំ ?

**8** ឧបមាថា បើគេយកប្រាក់ទៅផ្ញើនៅធនាគារមួយដោយទទួលបានអត្រាការសមាស 7% ។ តើប៉ុន្មានឆ្នាំ ទើបគេទទួលបានប្រាក់សរុបស្មើនឹងបីដងនៃប្រាក់ដើមបើការទូទាត់ច្រើនដង ក្នុងមួយឆ្នាំ ? (ចម្លើយគិតជាឆ្នាំ)

**9** គេឲ្យអនុគមន៍ $f$ កំណត់លើ $\mathbb{R}$ ដោយ $y=f(x)=(x^2+x+1)e^x$ ហើយមានក្រាប $C_f$ ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ដែលមានឯកតា $2cm$ ។

ⓐ គណនា $\lim\limits_{x\to-\infty} f(x)$ និង $\lim\limits_{x\to+\infty} f(x)$ រួចទាញរកសមីការអាស៊ីមតូតនៃក្រាប$C_f$ ។

(b) បង្ហាញថា $f'(x)=(x+1)(x+2)e^x$ រួចសិក្សាសញ្ញា $f'(x)$ រួចសង់តារាងអថេរភាព នៃអនុគមន៍ $f$ ។

(c) កំណត់សមីការ $f$ លើ $\mathbb{R}$ ។

(d) សង់ក្រាប $C_f$ ។

(e) គេឲ្យ $F(x)=(x^2-x+2)e^x$ រួចបង្ហាញ $F$ ជាព្រីមីទីវមួយនៃ $f$ លើ $\mathbb{R}$ ។ គណនាផ្ទៃ ក្រឡានៃផ្ទៃប្លង់ដែលខណ្ឌដោយក្រាប $C_f$, អ័ក្សអាប់ស៊ីស និង បន្ទាត់ $x=-1$ និង $x=0$ ។

**10** គេឲ្យអនុគមន៍ $f$ និង $g$ កំណត់លើ $\mathbb{R}$ ដោយ $f(x)=x-e^x$ និង $g(x)=(1-x)e^x$ ហើយ មានក្រាប $C_f, C_g$ ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ដែលមានឯកតា $2cm$ ។

(a) គណនាលីមីត $f$ និង $g$ ត្រង់ $-\infty$ និង $+\infty$ ។ រួចសិក្សាសមីការអាស៊ីមតូតនៃក្រាប $C_f, C_g$ ។

(b) គណនា $f'(x)$ និង $g'(x)$ រួចសង់តារាងអថេរភាព $f(x)$ និង $g(x)$ ។ បង្ហាញថា $f(x)<0$ ចំពោះគ្រប់ចំនួនពិត $x$ ។

(c) គេឲ្យ $h(x)=f(x)-g(x)$ រួចបង្ហាញ $h'(x)=1-g(x)$ ។ កំណត់សមីការអថេរភាពនៃ $h$ លើ $\mathbb{R}$ ។

(d) ស្រាយបញ្ជាក់ថា ក្រាប $C_f, C_g$ ប្រសព្វគ្នាតម្លៃមួយគត់ដែលមានអាប់ស៊ីសតាងដោយ $\alpha$ ដែល $1<\alpha<2$ ។

(e) សង់ក្រាប $C_f$ និង $C_g$ ក្នុងតម្រុយមួយ ។

**11** គេឲ្យ $f$ ជាអនុគមន៍កំណត់ចំពោះគ្រប់ចំនួនពិត $x$ ដោយ $f(x)=x-2+e^{1-x}$ ហើយមានក្រាប $C$ ។

(a) គណនា $\lim\limits_{x\to-\infty} f(x)$ និង $\lim\limits_{x\to+\infty} f(x)$ ។

(b) បង្ហាញថាបន្ទាត់ $D: y=x-2$ ជាអាស៊ីមតូតនៃក្រាប $C$ កាលណា $x\to+\infty$ ។

(c) សិក្សាទីតាំងរវាងក្រាប $C$ និងបន្ទាត់ $D$ ។

(d) គណនាដេរីវេ $f'(x)$ រួចសិក្សាអថេរភាពនៃអនុគមន៍ $f$ ។

(e) សង់បន្ទាត់ $D$ និង ក្រាប $C$ ។

(f) គណនាផ្ទៃក្រឡានៃផ្ទៃប្លង់ដែលខណ្ឌដោយក្រាប $C$ អាស៊ីមតូត បន្ទាត់ $D$ និង $x=1$ និង $x=2$ ។

**12** គេឲ្យអនុគមន៍ $f$ កំណត់លើ $\mathbb{R}$ ដោយ $y=f(x)=(x^2+x+1)e^x$ ហើយមានក្រាប $C_f$ ក្នុងបម្រាប់អរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ដែលមានរង្វាស់ $2cm$ ។

(a) គណនា $\lim\limits_{x\to-\infty} f(x)$ និង $\lim\limits_{x\to+\infty} f(x)$ រួចទាញរកសមីការអាស៊ីមតូតដេកនៃក្រាប $C_f$ ។

(b) បង្ហាញ $f'(x)=(x+1)(x+2)e^x$ រួចសិក្សាសញ្ញា $f'(x)$ និង សង់តារាងអថេរភាពនៃអនុគមន៍ $f$ ។

(c) កំណត់សញ្ញា $f$ លើ $\mathbb{R}$ ។

(d) សង់ក្រាប $C_f$ ។

(e) គេឲ្យ $F(x)=(x^2-x+2)e^x$ ។ បង្ហាញ $F$ ជាព្រីមីទីវមួយនៃ $f$ លើ $\mathbb{R}$ ។ គណនាតម្លៃក្រឡាផ្ទៃខណ្ឌដោយខ្សែកោងក្រាប $C_f$, អ័ក្សអាប់ស៊ីស និង បន្ទាត់ឈរ $x=-1$ និង $x=0$ ។

**13** គេឲ្យអនុគមន៍ $f$ និង $g$ កំណត់លើ $\mathbb{R}$ ដោយ $f(x)=x-e^x$ និង $g(x)=(1-x)e^x$ ហើយមានក្រាប

$C_f, C_g$ ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ដែលមានរង្វាស់ $2cm$ ។

ⓐ គណនាលីមីតនៃ $f$ និង $g$ ត្រង់ $-\infty$ និង $+\infty$ ។ រួចទាញរកសមីការអាស៊ីមតូតនៃក្រាប $C_f, C_g$ ។

ⓑ គណនា $f'(x)$ និង $g'(x)$ រួចសិក្សាសញ្ញាអថេរភាពនៃ $f(x)$ និង $g(x)$ ។ បង្ហាញ $f(x) < 0$ ចំពោះគ្រប់ចំនួនពិត $x$ ។

ⓒ តេឲ្យ $h(x) = f(x) - g(x)$ ។ បង្ហាញ $h'(x) = 1 - g(x)$ ។ កំណត់សាខាអាស៊ីមតូតនៃ $h$ លើ $\mathbb{R}$ ។

ⓓ ស្រាយបញ្ជាក់ថា ក្រាប $C_f$, និង $C_g$ ប្រសព្វគ្នាត្រង់មួយចំណុចដែលមានអាប់ស៊ីស $\alpha$ តែមួយគត់ $1 < \alpha < 2$ ។

ⓔ សង់ក្រាប $C_f$, និង $C_g$ ក្នុងបម្រាប់មួយ ។

**14** តេឲ្យ $f$ ជាអនុគមន៍កំណត់ត្រង់គ្រប់ចំនួនពិត $x$ ដោយ $f(x) = x - 2 + e^{-x}$ ហើយមានក្រាប $C$ ។

ⓐ គណនា $\lim\limits_{x\to-\infty} f(x)$ និង $\lim\limits_{x\to+\infty} f(x)$ ។

ⓑ បង្ហាញថាបន្ទាត់ $D : y = x - 2$ ជាអាស៊ីមតូតទ្រេតនៃក្រាប $C$ កាលណា $x \to +\infty$ ។

ⓒ សិក្សារទីតាំងរវាងក្រាប $C$ និងបន្ទាត់ $D$ ។

ⓓ គណនាដេរីវេ $f'(x)$ រួចសិក្សាអថេរភាពនៃអនុគមន៍ $f$ ។

ⓔ សង់បន្ទាត់ $D$ និងក្រាប $C$ ។

ⓕ គណនាតម្លៃក្រឡាផ្ទៃក្នុងប្លង់ខណ្ឌដោយក្រាប $C$, អាស៊ីមតូតទ្រេត និងបន្ទាត់ឈរ $x = 1$ និង $x = 2$ ។

**15** តេឲ្យ $C$ ជាក្រាបនៃអនុគមន៍ $f$ កំណត់ដោយ $f(x) = x + 3 - e^x$ កំណត់លើ $\mathbb{R}$ ។

ⓐ គណនាលីមីត $\lim\limits_{x\to-\infty} f(x)$ និង $\lim\limits_{x\to+\infty} f(x)$ ។ បង្ហាញថាបន្ទាត់ $D : y = x + 3$ ជាអាស៊ីមតូតទ្រេតត្រង់ $-\infty$ ។

ⓑ សិក្សារទីតាំងរវាងក្រាប $C$ និងបន្ទាត់ $D$ ។

ⓒ បង្ហាញថា $f$ មានអតិបរមាមួយដែលត្រូវកំណត់អាប់ស៊ីសរបស់វា ។

ⓓ សង់តារាងអថេរភាពនៃ $f$ ។

ⓔ គណនា $f(-2), f(-1), f(1)$ និង $f(2)$ ។ សង់ក្រាប $C$ ។

**16** $f$ ជាអនុគមន៍កំណត់លើ $\mathbb{R}$ ដោយ $f(x) = x + 1 + \dfrac{1+x}{e^{2x}}$

ⓐ គណនាដេរីវេ $f'(x)$

ⓑ អនុគមន៍ $g$ កំណត់ដោយ $g(x) = e^{2x} - 2x - 1$ ។ គណនា $g'(x)$ រួចគូសតារាងអថេរភាពនៃ $g$ (មិនបាច់គណនាលីមីត) ។ ទាញរកសញ្ញានៃ $f'(x)$ ។

ⓒ គណនាលីមីត $\lim\limits_{x\to-\infty} f(x)$ និង $\lim\limits_{x\to+\infty} f(x)$ បង្ហាញថា $y = x + 1$ ជាអស៊ីមតូតទ្រេតនៃ $C$ តាងអនុគមន៍ $f$ ខាង $+\infty$ ។

ⓓ សង់តារាងអថេរភាពនៃ $f$ ។

ⓔ គណនា $f(1)$ និង $f\left(-\dfrac{3}{2}\right)$ ។ សង់ក្រាប $C$ (តេឱ្យ $e^2 = 7.4, e^{-2} = 0.13$ និង $e^3 = 20$) ។

**17** តេឱ្យអនុគមន៍ $f$ កំណត់ចំពោះគ្រប់ចំនួនពិត $x \neq 0$ ដោយ $y = f(x) = x - \dfrac{e^x}{e^x - 1}$ ហើយមានក្រាប

$C$ ក្នុងប្លង់កូអរដោនេ $(O,\vec{i},\vec{j})$ ។

(a) គណនា $\lim\limits_{x\to 0^+} f(x)$, $\lim\limits_{x\to 0^-} f(x)$ និង $\lim\limits_{x\to\pm\infty} f(x)$ ។ ទាញរកសមីការអាស៊ីមតូតទ្រេតនៃក្រាប $C$ ។

(b) បង្ហាញថាបន្ទាត់ $L: y=x$ និង $M: y=x-1$ ជាអាស៊ីមតូតទ្រេតនៃក្រាប $C$ ខាង $-\infty$ និង $+\infty$ រៀងគ្នា ។

(c) គណនា $f'(x)$ ហើយបង្ហាញថា $f'(x)>0$ ចំពោះ $x\neq 0$ ។ សង់តារាងអថេរភាព $f$ ។

(d) គណនា $f(1)$ និង $f(-1)$ ហើយសង់បន្ទាត់ $L, M$ និងក្រាប $C$ ក្នុងប្លង់កូអរដោនេ $(O,\vec{i},\vec{j})$ ។
(គេឱ្យ $\dfrac{e}{e-1}=1.6$, $\dfrac{1}{1-e}=-0.6$)

(e) គណនាផ្ទៃក្រឡាក្នុងប្លង់កំណត់ ខណ្ឌដោយខ្សែកោង $C$ បន្ទាត់ $M$ និងបន្ទាត់ឈរ $x=1, x=2$ ។

**18** $f$ ជាអនុគមន៍កំណត់លើ $\mathbb{R}$ ដោយ $f(x)=x-1+\dfrac{3}{e^x+1}$ និងមានក្រាប $C$ ។

(a) គណនា $\lim\limits_{x\to+\infty} f(x)$ និង $\lim\limits_{x\to-\infty} f(x)$ ។

(b) គណនាដេរីវេ $f'(x)$ និងសិក្សាសញ្ញារបស់វា ។ សង់តារាងអថេរភាព $f$ ។

(c) បង្ហាញថាបន្ទាត់ $D_1: y=x-1$ ជាអាស៊ីមតូតទ្រេតនៃ $C$ ខាង $+\infty$ និង $D_2: y=x+2$ ជាអាស៊ីមតូតទ្រេតនៃ $C$ ខាង $-\infty$ ។ បញ្ជាក់ទីតាំងធៀបរវាងអស៊ីមតូតទាំងពីរ និងខ្សែកោង $C$ ។

(d) រកសមីការបន្ទាត់ប៉ះ $T$ នឹងក្រាប $C$ ត្រង់ចំណុចមានអាប់ស៊ីស 0 ។

(e) សង់បន្ទាត់ $D_1, D_2, T$ និងក្រាប $C$ ក្នុងតម្រុយមួយ ។

## ចម្លើយកម្រងលំហាត់បន្ថែម

**1** គណនលីមីតខាងក្រោម ៖

(a) $\lim\limits_{x\to+\infty} xe^{x+1}=(+\infty)\cdot(+\infty)=+\infty$ (ព្រោះ $\lim\limits_{x\to+\infty} x=+\infty$ និង $\lim\limits_{x\to+\infty} e^{x+1}=+\infty$) ॥

(b) $\lim\limits_{x\to-\infty} x^2e^{4x}$ ៖

- តាង $u=4x \implies x=\dfrac{u}{4}$
- កាលណា $x\to-\infty$ នាំឱ្យ $u\to-\infty$

យើងបាន ៖ $\lim\limits_{x\to-\infty} x^2e^{4x}=\lim\limits_{u\to-\infty}\left(\dfrac{u}{4}\right)^2e^u=\lim\limits_{u\to-\infty}\dfrac{1}{16}u^2e^u=0$ (ព្រោះ $\lim\limits_{u\to-\infty} u^2e^u=0$)

(c) $\lim\limits_{x\to+\infty}\left(1+\dfrac{n}{x}\right)^x$

- តាង $u=\dfrac{x}{n} \implies x=nu$ (ចំពោះ $n\neq 0$)
- កាលណា $x\to+\infty$ នាំឱ្យ $u\to+\infty$

យើងបាន ៖

$$\lim_{x\to+\infty}\left(1+\frac{n}{x}\right)^x=\lim_{u\to+\infty}\left(1+\frac{1}{u}\right)^{nu}=\lim_{u\to+\infty}\left[\left(1+\frac{1}{u}\right)^u\right]^n$$

ដោយ $\lim\limits_{u\to+\infty}\left(1+\dfrac{1}{u}\right)^{u}=e$

$$\Longrightarrow \lim_{x\to+\infty}\left(1+\frac{n}{x}\right)^{x}=e^{n}$$

$$= 3x^2$$

ដូចនេះ $\boxed{f'(x) = 3x^2}$

① $f(x)=\ln\left(\dfrac{x^2+1}{x^3-x}\right)$

$$f(x)=\ln(x^2+1)-\ln(x^3-x)$$

$$f'(x)=\frac{\frac{d}{dx}(x^2+1)}{x^2+1}-\frac{\frac{d}{dx}(x^3-x)}{x^3-x}$$

$$=\frac{2x}{x^2+1}-\frac{3x^2-1}{x^3-x}$$

$$=\frac{2x(x^3-x)-(3x^2-1)(x^2+1)}{(x^2+1)(x^3-x)}$$

$$=\frac{-x^4-4x^2+1}{x^5-x}$$

ដូចនេះ $\boxed{f'(x)=\dfrac{-x^4-4x^2+1}{x^5-x}}$

## ៣.៤ សមីការ និងវិសមីការលោការីតនេពែ

### ៣.៤.១ សមីការ

**លំហាត់គំរូ 1** ដោះស្រាយសមីការក្នុង $\mathbb{R}$ : $\ln(x-2)+\ln(x+2)=\ln 45$ ។

**ដំណោះស្រាយ** លក្ខខណ្ឌ $x-2>0$ និង $x+2>0$

គេបាន $x>2$ ជាលក្ខខណ្ឌដែលធ្វើឱ្យសមីការមានន័យ

$\ln(x-2)+\ln(x+2)=\ln 45$

$(x-2)(x+2)=45$ ឬ $x^2-49=0$ គេបាន $x=7\,,x=-7$

តាមលក្ខខណ្ឌ $x>2$ ដូច្នេះសមីការមានឫសតែមួយគត់គឺ $x=7$ ។

**លំហាត់គំរូ 2** ដោះស្រាយសមីការក្នុង $\mathbb{R}$ : $3e^{2x}+e^x-10=0$ ។

**ដំណោះស្រាយ** សមីការអាចសរសេរ $3(e^x)^2+e^x-10=0$

តាង $t=e^x>0$ សមីការទៅជា $3t^2+t-10=0$

គេបាន $t=\dfrac{5}{3}\,,t=-2$ ដោយ $e^x>0$ គេបាន $e^x=\dfrac{5}{3}\,,x=\ln\dfrac{5}{3}$ ។

**ប្រតិបត្តិ** ដោះស្រាយសមីការខាងក្រោម៖

ក. $\ln(1-x)+\ln(2x+3)-\ln(x+1)=\ln 3$ ខ. $\dfrac{e^x-2}{e^x-3}=4$ ។

**ចម្លើយ** ក. $x=0$ ខ. $x=\ln\dfrac{10}{3}$ ។

**លំហាត់គំរូ** ដោះស្រាយប្រព័ន្ធសមីការក្នុង $\mathbb{R}$ : $\begin{cases} \ln y = \ln x + 2 \\ xy = 9e^2 \end{cases}$

លក្ខខណ្ឌនៃប្រព័ន្ធគឺ $x > 0$ និង $y > 0$

ប្រព័ន្ធសមីការអាចសរសេរ $\begin{cases} \ln \frac{y}{x} = 2 \\ xy = 9e^2 \end{cases}$ ឬ $\begin{cases} \ln \frac{y}{x} = \ln e^2 \\ xy = 9e^2 \end{cases}$

គេបាន $\begin{cases} \frac{y}{x} = e^2 \\ xy = 9e^2 \end{cases}$ ដោះស្រាយប្រព័ន្ធ $x = \pm 3$

ដោយ $x > 0$ នោះ $x = 3$ ហើយ $y = 3e^2$ ។

**ប្រតិបត្តិ** ដោះស្រាយប្រព័ន្ធសមីការខាងក្រោម ៖

ក. $\begin{cases} e^x + 2e^y = 1 \\ -3e^x + e^y = 4 \end{cases}$ ខ. $\begin{cases} x + y = 65 \\ \ln x + \ln y = \ln 1000 \end{cases}$

**ចម្លើយ** ក. គ្មានចម្លើយ ខ. $(x = 25, y = 40), (x = 40, y = 25)$ ។

### ៣.៤.២ វិសមីការ

**លំហាត់គំរូ** ដោះស្រាយវិសមីការក្នុង $\mathbb{R}$ : $\ln(x+3) + \ln(x+5) \leq \ln 15$ ។

**ដំណោះស្រាយ** លក្ខខណ្ឌ $x + 3 > 0$ និង $x + 5 > 0$ នាំឱ្យ $x > -3$

វិសមីការអាចសរសេរ $\ln(x+3)(x+5) \leq \ln 15$ ដោយ $e > 1$ វិសមីការមិនប្តូរទិសដៅ $(x+3)(x+5) \leq 15$ ឬ $x^2 + 8x \leq 0$ ដោះស្រាយវិសមីការ $-8 \leq x \leq 0$

តាមលក្ខខណ្ឌ $x > -3$ វិសមីការមានចម្លើយត្រឹមតែ $-3 < x \leq 0$ ។

**ប្រតិបត្តិ** ដោះស្រាយវិសមីការខាងក្រោម ៖

ក. $\ln(x^2 - 4e^2) < 1 + \ln 3x$ ខ. $3e^x - 10e^{-x} + 1 \geq 0$

**ចម្លើយ** ក. $x \in (2e, 4e)$ ខ. $x \geq \ln \frac{5}{3}$ ។

**សម្គាល់**

- បើ $a > 0, a \neq 1$ នោះសមីការ $\log_a x = \log_a y$ គេបាន $x = y$ ។

- បើ $a > 1$ វិសមីការ $\log_a f(x) < \log_a g(x) \Leftrightarrow \begin{cases} f(x) > 0 \\ f(x) < g(x) \end{cases}$
- បើ $0 < a < 1$ វិសមីការ $\log_a f(x) < \log_a g(x) \Leftrightarrow \begin{cases} g(x) > 0 \\ f(x) > g(x) \end{cases}$ ។

## លំហាត់

**1** ដោះស្រាយសមីការខាងក្រោម

(a) $\ln(x-2) + \ln(x-2) = \ln 45$
(b) $3e^{2x} + e^x - 10 = 0$
(c) $\ln(1-x)(2x+3) - \ln(x+1) = \ln 3$
(d) $\dfrac{e^x - 2}{e^x - 3} = 4$

**2** ដោះស្រាយវិសមីការខាងក្រោម

(a) $\ln(x+3) + \ln(x+5) \leq \ln 15$
(b) $\ln(x^2 - 4e^2) < 1 + \ln 3x$
(c) $3e^x - 10e^{-x} + 1 \geq 0$

**3** ដោះស្រាយប្រពន្ធវិសមីការខាងក្រោម

(a) $\begin{cases} \ln y = \ln x + 2 \\ xy = 9e^2 \end{cases}$
(b) $\begin{cases} e^x + 2e^y = 1 \\ -3e^x + e^y = 4 \end{cases}$
(c) $\begin{cases} x + y = 65 \\ \ln x + \ln y = \ln 1000 \end{cases}$

## ដំណោះស្រាយ

**1** ដោះស្រាយសមីការខាងក្រោម

(a) $\ln(x-2) + \ln(x-2) = \ln 45$

លក្ខខណ្ឌ៖ $x-2>0 \Rightarrow x>2$

$$2\ln(x-2)=\ln 45$$
$$\ln(x-2)^2=\ln 45$$
$$(x-2)^2=45$$
$$x-2=\sqrt{45} \quad (\text{ព្រោះ } x-2>0)$$
$$x-2=3\sqrt{5}$$
$$x=2+3\sqrt{5}$$

ដូចនេះ $\boxed{x=2+3\sqrt{5}}$

◈ b $3e^{2x}+e^x-10=0$

$$3(e^x)^2+e^x-10=0$$

តាង $t=e^x$ $(t>0)$ សមីការទៅជា៖

$$3t^2+t-10=0$$
$$(3t-5)(t+2)=0$$

យើងបាន $t=\frac{5}{3}$ ឬ $t=-2$ (មិនយកព្រោះ $t>0$)

$$e^x=\frac{5}{3}$$
$$x=\ln\left(\frac{5}{3}\right)$$

ដូចនេះ $\boxed{x=\ln\left(\frac{5}{3}\right)}$

◈ c $\ln(1-x)(2x+3)-\ln(x+1)=\ln 3$

លក្ខខណ្ឌ៖ $\begin{cases} 1-x>0 \\ 2x+3>0 \\ x+1>0 \end{cases} \Rightarrow -1<x<1$

$$\ln\left(\frac{(1-x)(2x+3)}{x+1}\right)=\ln 3$$

$$\frac{(1-x)(2x+3)}{x+1}=3$$

$$(1-x)(2x+3)=3(x+1)$$

$$-2x^2-x+3=3x+3$$

$$-2x^2-4x=0$$

$$-2x(x+2)=0$$

នាំឲ្យ $x=0$ (យក) ឬ $x=-2$ (មិនយក ព្រោះមិនផ្ទៀងផ្ទាត់លក្ខខណ្ឌ)

ដូចនេះ $\boxed{x=0}$

(d) $\dfrac{e^x-2}{e^x-3}=4$

លក្ខខណ្ឌ៖ $e^x-3\neq 0 \Rightarrow e^x\neq 3 \Rightarrow x\neq \ln 3$

$$e^x-2=4(e^x-3)$$

$$e^x-2=4e^x-12$$

$$3e^x=10$$

$$e^x=\frac{10}{3}$$

$$x=\ln\left(\frac{10}{3}\right)$$

ដូចនេះ $\boxed{x=\ln\left(\frac{10}{3}\right)}$

2 ដោះស្រាយវិសមីការខាងក្រោម

(a) $\ln(x+3)+\ln(x+5)\leq \ln 15$

លក្ខខណ្ឌ៖ $\begin{cases} x+3>0 \\ x+5>0 \end{cases} \Rightarrow x>-3$

$$\ln((x+3)(x+5)) \leq \ln 15$$

$$(x+3)(x+5) \leq 15$$

$$x^2+8x+15 \leq 15$$

$$x^2+8x \leq 0$$

$$x(x+8) \leq 0$$

ដំណោះស្រាយនៃវិសមីការ $x(x+8) \leq 0$ គឺ $-8 \leq x \leq 0$

ប្រសព្វជាមួយលក្ខខណ្ឌ $x>-3$ យើងបាន៖

ដូចនេះ $\boxed{-3<x\leq 0}$

(b) $\ln(x^2-4e^2)<1+\ln 3x$

លក្ខខណ្ឌ៖ $\begin{cases} x^2-4e^2>0 \\ 3x>0 \end{cases} \Rightarrow x>2e$

$$\ln(x^2-4e^2)<\ln e+\ln 3x$$

$$\ln(x^2-4e^2)<\ln(3ex)$$

$$x^2-4e^2<3ex$$

$$x^2-3ex-4e^2<0$$

$$(x-4e)(x+e)<0$$

ដំណោះស្រាយនៃវិសមីការគឺ $-e<x<4e$

ប្រសព្វជាមួយលក្ខខណ្ឌ $x>2e$ យើងបាន៖

ដូចនេះ $\boxed{2e<x<4e}$

(c) $3e^x-10e^{-x}+1\geq 0$

គុណអង្គទាំងពីរនឹង $e^x>0$ ៖

$$3(e^x)^2+e^x-10\geq 0$$

តាង $t = e^x$ $(t > 0)$ វិសមីការទៅជា៖

$$3t^2 + t - 10 \geq 0$$

$$(3t - 5)(t + 2) \geq 0$$

ដោយសារ $t > 0$ នាំឲ្យ $t + 2 > 0$ ជានិច្ច ដូចនេះ៖

$$3t - 5 \geq 0$$

$$t \geq \frac{5}{3}$$

ជំនួស $t = e^x$ វិញ៖

$$e^x \geq \frac{5}{3}$$

$$x \geq \ln\left(\frac{5}{3}\right)$$

ដូចនេះ $\boxed{x \geq \ln\left(\frac{5}{3}\right)}$

**3** ដោះស្រាយប្រពន្ធវិសមីការខាងក្រោម

**a** $\begin{cases} \ln y = \ln x + 2 \\ xy = 9e^2 \end{cases}$

លក្ខខណ្ឌ៖ $x > 0$ និង $y > 0$

$$\ln y - \ln x = 2$$

$$\ln\left(\frac{y}{x}\right) = 2$$

$$\frac{y}{x} = e^2 \Rightarrow y = xe^2$$

$$x(xe^2) = 9e^2$$

$$x^2e^2 = 9e^2$$

$$x^2 = 9 \Rightarrow x = 3 \quad (\text{ព្រោះ } x > 0)$$

គណនា $y$ ៖ $y = 3e^2$

ដូចនេះ $\boxed{(x,y)=(3,3e^2)}$

**b** $\begin{cases} e^x+2e^y=1 \\ -3e^x+e^y=4 \end{cases}$

គុណសមីការទី១ និង 3 រួចបូកជាមួយសមីការទី២៖

$$3(e^x+2e^y)+(-3e^x+e^y)=3(1)+4$$

$$7e^y=7$$

$$e^y=1\Rightarrow y=0$$

ជំនួស $e^y=1$ ចូលក្នុងសមីការទី១៖

$$e^x+2(1)=1$$

$$e^x=-1$$

ដោយសារ $e^x>0$ ចំពោះគ្រប់ $x\in\mathbb{R}$ នោះសមីការ $e^x=-1$ គ្មានឫស។

ដូចនេះ $\boxed{\text{ប្រព័ន្ធសមីការគ្មានដំណោះស្រាយ}}$

**c** $\begin{cases} x+y=65 \\ \ln x+\ln y=\ln 1000 \end{cases}$

លក្ខខណ្ឌ៖ $x>0$ និង $y>0$

$$\ln x+\ln y=\ln 1000$$

$$\ln(xy)=\ln 1000$$

$$xy=1000$$

យើងបានប្រព័ន្ធសមីការ៖ $\begin{cases} x+y=65 \\ xy=1000 \end{cases}$ នាំឲ្យ $x$ និង $y$ ជាឫសនៃសមីការ៖

$$t^2-65t+1000=0$$

$$\Delta=(-65)^2-4(1)(1000)=4225-4000=225=15^2$$

$$t_1 = \frac{65+15}{2} = 40$$

$$t_2 = \frac{65-15}{2} = 25$$

ដោយសារ $t_1, t_2 > 0$ ផ្ទៀងផ្ទាត់លក្ខខណ្ឌ

ដូចនេះ $\boxed{(x,y) = (40,25) \text{ ឬ } (x,y) = (25,40)}$

## ៣.៥ សិក្សាអនុគមន៍ដែលទាក់ទងនឹងអនុគមន៍លោការីត

**សម្គាល់**

**ដើម្បីសិក្សាអនុគមន៍លោការីតគេត្រូវ**

- (a) ដែនកំណត់ $D$
- (b) ទិសដៅអថេរភាព
  - លីមីត
  - ដេរីវេ
  - សញ្ញាដេរីវេ
  - តារាងអថេរភាព
- (c) សង់ក្រាប
  - ចំណុចប្រសព្វ
  - អាស៊ីមតូត

**លំហាត់គំរូ 1** សិក្សាអថេរភាពនិងសង់ក្រាបនៃអនុគមន៍ $f(x) = x - \ln x$ ។

**ដំណោះស្រាយ** $C : f(x) = x - \ln x$

- ដែនកំណត់ $D = (0, +\infty)$
- ទិសដៅអថេរភាព
  - លីមីត

$$\lim_{x\to 0^+} f(x) = \lim_{x\to 0^+} (x - \ln x) = +\infty \quad (\text{ព្រោះ } \lim_{x\to 0^+} \ln x = -\infty)$$

$$\lim_{x\to +\infty} f(x) = \lim_{x\to +\infty} (x - \ln x) \quad (\text{រាងមិនកំណត់ } +\infty - \infty)$$

$$= \lim_{x\to +\infty} x\left(1 - \frac{\ln x}{x}\right) = +\infty \quad (\text{ព្រោះ } \lim_{x\to +\infty} \frac{\ln x}{x} = 0)$$

  - ដេរីវេ : $f'(x) = (x - \ln x)' = 1 - \frac{1}{x} = \frac{x-1}{x}$

- សញ្ញានៃដេរីវេ : ដោយ $x>0$ នោះ $f'(x)$ មានសញ្ញាដូច $x-1$ ។
  $f'(x)=0$ គេបាន $x-1=0$ នាំឱ្យ $x=1$

- សញ្ញាដេរីវេ


| $x$ | $0$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $-$ | $0$ | $+$ | |

  - $f$ ចុះលើ $(0,1)$ ហើយកើនលើ $(1,+\infty)$
  - តម្លៃអប្បបរមាធៀប $f(1)=1-\ln 1=1-0=1$ ។

- តារាងអថេរភាពនៃ $f$

| $x$ | $0$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | ‖ $+\infty$ | $\searrow$ | $1$ | $\nearrow$ | $+\infty$ |

- សង់ក្រាប
  - បន្ទាត់ $x=0$ ជាអាស៊ីមតូតឈរនៃក្រាប $C$ ព្រោះ $\lim\limits_{x\to 0^+} f(x)=+\infty$ ។
  - រកចំណុចជំនួយ
    $f(2)=2-\ln 2=2-0.7=1.3 \Rightarrow C$ កាត់តាមចំណុច $(2,1.3)$
    $f(3)=3-\ln 3=3-1.1=1.9 \Rightarrow C$ កាត់តាមចំណុច $(3,1.9)$ ។




**លំហាត់គំរូ 2** សិក្សាអថេរភាពនិងសង់ក្រាបនៃអនុគមន៍ $f(x)=\dfrac{\ln x}{x}$ ។

**ដំណោះស្រាយ** $C: f(x)=\dfrac{\ln x}{x}$

- ដែនកំណត់ $D=(0,+\infty)$

- ទិសដៅអថេរភាព
  - លីមីត : $\lim\limits_{x\to 0^+} f(x) = \lim\limits_{x\to 0^+} \dfrac{\ln x}{x} = -\infty$ (ព្រោះ $\lim\limits_{x\to 0^+} \ln x = -\infty$)
    $\lim\limits_{x\to +\infty} f(x) = \lim\limits_{x\to +\infty} \dfrac{\ln x}{x} = 0$
  - ដេរីវេ : $f'(x) = \left(\dfrac{\ln x}{x}\right)' = \dfrac{(\ln x)' \cdot x - (x)' \ln x}{x^2} = \dfrac{1-\ln x}{x^2}$
  - សញ្ញានៃដេរីវេ

    ដោយ $x^2 > 0, \forall x \in D$ នោះ $f'(x)$ មានសញ្ញាដូច $1-\ln x$ ។

    $1-\ln x = 0 \Leftrightarrow \ln x = 1 \Leftrightarrow x = e$

    $1-\ln x > 0 \Leftrightarrow \ln x < 1 \Leftrightarrow 0 < x < e$


    $1-\ln x < 0 \Leftrightarrow \ln x > 1 \Leftrightarrow x > e$

| $x$ | $0$ | | $e$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $+$ | $0$ | $-$ | |

- $f$ កើនលើ $(0,e)$ ហើយចុះលើ $(e,+\infty)$
- តម្លៃអតិបរមាធៀប : $f(e) = \dfrac{\ln e}{e} = \dfrac{1}{e}$
- តារាងអថេរភាពនៃ $f$

| $x$ | $0$ | | $e$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $+$ | $0$ | $-$ | |
| $f(x)$ | ‖ $-\infty$ | ↗ | $\dfrac{1}{e}$ | ↘ | $0$ |

- សំណង់ក្រាប
  - បន្ទាត់ $x = 0$ ជាអាស៊ីមតូតឈរនៃក្រាប $C$ ព្រោះ $\lim\limits_{x\to 0^+} f(x) = -\infty$ ។
  - បន្ទាត់ $y = 0$ ជាអាស៊ីមតូតដេកនៃក្រាប $C$ ព្រោះ $\lim\limits_{x\to +\infty} f(x) = 0$ ។
  - ជំនួស : $f(1) = \dfrac{\ln 1}{1} = \dfrac{0}{1} = 0 \Rightarrow C$ កាត់តាមចំណុច $(1,0)$ ។




**លំហាត់គំរូ 3** អនុគមន៍ $f$ កំណត់លើ $\mathbb{R}-\{0\}$ ដោយ $f(x)=\ln(x^2)$ មានក្រាប $C$ ។

ក. គណនា $\lim\limits_{x\to\pm\infty} f(x)$ និង $\lim\limits_{x\to 0} f(x)$ ។ រកសមីការអាស៊ីមតូតនៃក្រាប $C$ ។

ខ. សិក្សាអថេរភាពនៃ $f$ និងសង់តារាងអថេរភាពនៃ $f$ ។

គ. រកសមីការបន្ទាត់ $d_1$ ប៉ះក្រាប $C$ ត្រង់ចំណុច $A(e,2)$ និងបន្ទាត់ $d_2$ ប៉ះក្រាប $C$ ត្រង់ចំណុច $B(-e,2)$ ។

ឃ. រកកូអរដោនេចំណុចប្រសព្វរវាងក្រាប $C$ និងអ័ក្សអាប់ស៊ីស ។ សង់ក្រាប $C$ បន្ទាត់ $d_1,d_2$ ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ មួយ ។

**ដំណោះស្រាយ**

$C: f(x)=\ln(x^2)$ ដែនកំណត់ $D=\mathbb{R}-\{0\}$

ក. គណនាលីមីត និងរកសមីការអាស៊ីមតូតនៃក្រាប $C$

$\lim\limits_{x\to\pm\infty} f(x)=\lim\limits_{x\to\pm\infty}\ln(x^2)=+\infty$

$\lim\limits_{x\to 0} f(x)=\lim\limits_{x\to 0}\ln(x^2)=-\infty$

បន្ទាត់ $x=0$ ជាអាស៊ីមតូតឈរនៃក្រាប $C$ ។

ខ. សិក្សាអថេរភាពនៃ $f$

- ដេរីវេ $f'(x)=[\ln(x^2)]'=\dfrac{(x^2)'}{x^2}=\dfrac{2x}{x^2}=\dfrac{2}{x}$ មានសញ្ញាដូច $x$
- សញ្ញានៃដេរីវេ

| $x$ | $-\infty$ | $0$ | $+\infty$ |
|---|---|---|---|
| $f'(x)$ | $-$ | ‖ | $+$ |

អនុគមន៍ $f$ ចុះលើចន្លោះ $(-\infty,0)$ ព្រោះ $f'(x)<0$

អនុគមន៍ $f$ កើនលើចន្លោះ $(0,+\infty)$ ព្រោះ $f'(x)>0$

តារាងអថេរភាពនៃ $f$

| $x$ | $-\infty$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $-$ | ‖ | $+$ | |
| $f(x)$ | $+\infty$ | ↘ | $-\infty$ $-\infty$ | ↗ | $+\infty$ |

គ. រកសមីការបន្ទាត់ $d_1$ ប៉ះក្រាប $C$ ត្រង់ចំណុច $A(e,2)$

$d_1: y-y_0=f'(x_0)(x-x_0)$ ដោយ $d_1$ ប៉ះ $C$ ត្រង់ $A(e,2)\Rightarrow x_0=e, y_0=2$

និង $f'(x_0)=f'(e)=\dfrac{2}{e}$ នោះ $d_1: y-2=\dfrac{2}{e}(x-e)=\dfrac{2}{e}x-2$

ដូច្នេះ $d_1: y=\dfrac{2}{e}x$ ។

រកសមីការបន្ទាត់ $d_2$ ប៉ះក្រាប $C$ ត្រង់ចំណុច $B(-e,2)$

$d_2: y-y_0=f'(x_0)(x-x_0)$ ដោយ $d_2$ ប៉ះ $C$ ត្រង់ $B(-e,2)\Rightarrow x_0=-e, y_0=2$

និង $f'(x_0)=f'(-e)=\dfrac{2}{-e}=-\dfrac{2}{e}$ នោះ $d_2: y-2=-\dfrac{2}{e}(x-(-e))=-\dfrac{2}{e}x-2$

ដូច្នេះ $d_2: y=-\dfrac{2}{e}x$ ។

ឃ. រកកូអរដោនេចំណុចប្រសព្វរវាងក្រាប $C$ និងអ័ក្សអាប់ស៊ីស

$C\cap x'x$ ត្រង់ $y=0\Rightarrow \ln(x^2)=0\Rightarrow x^2=1\Rightarrow x=\pm 1$

ដូច្នេះ $C$ កាត់អ័ក្សអាប់ស៊ីសត្រង់ចំណុច $(-1,0)$ និង $(1,0)$ ។


សង់ក្រាប $C$ និងបន្ទាត់ $d_1, d_2$

$d_1: y=\dfrac{2}{e}x$

| $x$ | $0$ | $e$ |
|---|---|---|
| $y$ | $0$ | $2$ |

$d_2: y=-\dfrac{2}{e}x$

| $x$ | $0$ | $-e$ |
|---|---|---|
| $y$ | $0$ | $2$ |



**ប្រតិបត្តិ** សិក្សាអថេរភាពនិងសង់ក្រាបអនុគមន៍ខាងក្រោម ៖

ក. $f(x) = x^2 - 8\ln x$ ខ. $y = x^2 \ln x$ ឃ. $y = g(x) = 2x + \dfrac{x}{\ln x}$ ។

## ៣.៦ អនុវត្ត

**លំហាត់គំរូ 1** តំហាយអិចស្ប៉ូណង់ស្យែលដែលមានទម្រង់ $y = ae^{-kt}$

ធាតុវិទ្យុសកម្មនៃកាបូន $(C-14)$ មានការថយចុះជាបន្តបន្ទាប់ក្នុងអត្រាមួយ ថេរ ។ ពាក់កណ្តាលជីវិតនៃកាបូន $(C-14)$ គឺ 5760 ឆ្នាំ ។ មានន័យថា 5760 ឆ្នាំ កាបូន $(C-14)$ បានពុកផុយម៉ាស ចំនួនពាក់កណ្តាល ។

ក. រកតម្លៃអត្រាថយចុះ $k$ នៃកាបូន $(C-14)$ ?

ខ. អ្នកវិទ្យាសាស្ត្រខាងបុរាណវិទ្យាបានត្រួតពិនិត្យឆ្អឹងសត្វមួយប្រភេទ ហើយ ប៉ាន់ស្មានថាមានធាតុកាបូន $(C-14)$ នៅសល់ចំនួន 3% ។ តើសត្វនេះបានស្លាប់ប្រហែលប៉ុន្មានឆ្នាំហើយ ?

**ដំណោះស្រាយ** ក. តម្លៃអត្រាថយចុះ $k$ នៃកាបូន $(C-14)$

គេមានរូបមន្តតំហាយអិចស្ប៉ូណង់ស្យែល $y = ae^{-kt}$ ដែល $k$ ជាអត្រាថយចុះ នៃកាបូន $(C-14)$ $a$ ជាចំនួនចាប់ផ្តើម $y$ ជាបរិមាណនៅសល់បន្ទាប់ពី $t = 5760$ ឆ្នាំនៃពាក់កណ្តាលជីវិតរបស់កាបូន $(C-14)$ គឺ $\dfrac{1}{2}a = 0.5a$ ។

គេបាន $y = ae^{-kt}$ សមមូល $0.5a = ae^{-k(5760)}$

សមមូល $0.5 = e^{-5760k}$ សមមូល $\ln 0.5 = \ln e^{-5760k}$

សមមូល $-5760k = \ln 0.5$ សមមូល $k = \dfrac{-\ln 0.5}{5760} = \dfrac{\ln 2}{5760} = 0.00012$

ដូច្នេះ អត្រាថយចុះថេរនៃកាបូន $(C-14)$ គឺ 0.00012 ។

ខ. តាង $a$ ជាបរិមាណដំបូងនៃកាបូន $(C-14)$ ក្នុងខ្លួនផ្ទស៊ីលសត្វ

គេបាន $y = ae^{-0.00012t}$ $\Leftrightarrow 0.03a = ae^{-0.00012t}$

$\Leftrightarrow 0.03 = e^{-0.00012t}$ $\Leftrightarrow \ln 0.03 = \ln e^{-0.00012t}$

$\Leftrightarrow \ln 0.03 = -0.00012t$ $\Leftrightarrow t = \dfrac{\ln 0.03}{-0.00012}$

$\Rightarrow t \approx 29221$ ។

ដូច្នេះ ផ្ទស៊ីលសត្វនេះស្លាប់តាំងពី 29221 ឆ្នាំមុន ។

**លំហាត់គំរូ 2** កំណើនអិចស្ប៉ូណង់ស្យែលមានទម្រង់ $y = ae^{kt}$ ។ តាមការប៉ាន់ស្មានបានឱ្យដឹងថា នៅឆ្នាំ 2000 ប្រទេសចិនមានប្រជាជនប្រហែល 1.26 ពាន់លាននាក់ ដែលជាចំនួនច្រើនបំផុតនៅលើពិភពលោក ហើយប្រទេសឥណ្ឌាមានប្រជាជន 1.01 ពាន់លាននាក់ ដែលជាចំនួនលំដាប់ទី 2 បន្ទាប់ពី ប្រទេសចិន ។ ចំនួនប្រជាជននៃប្រទេសចិនកើនឡើងតាមសមីការ $C(t) = 1.26e^{0.009t}$ ហើយប្រជាជនឥណ្ឌាកើនឡើងតាមសមីការ $I(t) = 1.01e^{0.015t}$ ។ តាមសមីការនេះ តើប៉ុន្មានឆ្នាំទៀត ទើបប្រទេសឥណ្ឌា មានចំនួនប្រជាជនច្រើនជាងប្រទេសចិន ?

**ដំណោះស្រាយ** គេមានវិសមីការ $I(t) > C(t)$

$$\begin{aligned}
1.01e^{0.015t} &> 1.26e^{0.009t} \\
\ln 1.01e^{0.015t} &> \ln 1.26e^{0.009t} \\
\ln 1.01 + \ln e^{0.015t} &> \ln 1.26 + e^{0.009t} \\
\ln e^{0.015t} - e^{0.015t} &> \ln 1.26 - \ln 1.01 \\
0.006t &> \ln 1.26 - \ln 1.01 \\
t &> \frac{\ln 1.26 - \ln 1.01}{0.0006} \quad \text{នាំឱ្យ } t > 36.86 \text{ ។}
\end{aligned}$$

ដូច្នេះ ប្រហែល 37 ឆ្នាំទៀត ប្រទេសឥណ្ឌានឹងមានប្រជាជនច្រើនជាងប្រទេសចិន ។

## លំហាត់

1. សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ $y = f(x) = x - \ln x$ ។
2. សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ $y = f(x) = \dfrac{\ln x}{x}$ ។
3. សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ $y = f(x) = e^x \ln x$ ។
4. សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ $y = f(x) = f(x) = x^2 - 8\ln x$ ។
5. សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ $y = f(x) = y = x^2 \ln x$ ។
6. សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ $y = f(x) = 2x + \dfrac{x}{\ln x}$ ។
7. អនុគមន៍ $f$ កំណត់លើ $\mathbb{R} \setminus \{0\}$ ដោយ $f(x) = \ln(x^2)$ មានក្រាប $C$ ។
   - (a) គណនា $\lim\limits_{x\to\pm\infty} f(x)$ និង $\lim\limits_{x\to 0} f(x)$ ។ រកសមីការអាស៊ីមតូតនៃក្រាប $C$ ។
   - (b) សិក្សាអថេរភាពអនុគមន៍ $f$ និងសង់តារាងអថេរភាពនៃ $f$ ។
   - (c) រកសមីការបន្ទាត់ប៉ះ $d_1$ ក្រាប $C$ ត្រង់ចំនុច $A(e,2)$ និងបន្ទាត់ប៉ះ $d_2$ ពី ក្រាប $C$ ត្រង់ចំនុច $B(-e,2)$
   - (d) បង្ហាញថាចំនុចប្រសព្វរវាងក្រាប $C$ និងអ័ក្សអាប់ស៊ីស។ សង់ក្រាប $C$ បន្ទាត់ $d_1, d_2$ ក្នុងតម្រុយអរតូណរម៉ាល់ $(O, \vec{i}, \vec{j})$ មួយ ។

## ដំណោះស្រាយ

**1** សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ $y = f(x) = x - \ln x$

**a** ដែនកំណត់ និងគណនាលីមីតត្រង់ចុងដែនកំណត់ ៖

- ដែនកំណត់ ៖ $D = ]0, +\infty[$
- $\lim\limits_{x\to 0^+} f(x) = \lim\limits_{x\to 0^+} (x - \ln x) = 0 - (-\infty) = +\infty$
  (នាំឱ្យបន្ទាត់ $x = 0$ ឬអ័ក្សអរដោនេ ជាអាស៊ីមតូតឈរនៃក្រាប $C$)
- $\lim\limits_{x\to +\infty} f(x) = \lim\limits_{x\to +\infty} x\left(1 - \dfrac{\ln x}{x}\right) = +\infty(1-0) = +\infty$
  (ព្រោះ $\lim\limits_{x\to +\infty} \dfrac{\ln x}{x} = 0$)

**b** គណនាដេរីវេ $f'(x)$ សិក្សាសញ្ញារបស់វា និងសង់តារាងអថេរភាពនៃ $f$ ៖

- គណនាដេរីវេ ៖

$$f'(x) = (x)' - (\ln x)' = 1 - \frac{1}{x} = \frac{x-1}{x}$$


- សិក្សាសញ្ញានៃ $f'(x)$ ៖
  ដោយ $x > 0$ គ្រប់ $x \in ]0, +\infty[$ នាំឱ្យសញ្ញានៃ $f'(x)$ យកតាមសញ្ញានៃភាគយក $x - 1$ ៖
  - $f'(x) = 0 \iff x - 1 = 0 \iff x = 1$
  - ចំពោះ $x \in ]0, 1[$ ៖ $f'(x) < 0 \implies f$ ជាអនុគមន៍ចុះដាច់ខាត
  - ចំពោះ $x \in ]1, +\infty[$ ៖ $f'(x) > 0 \implies f$ ជាអនុគមន៍កើនដាច់ខាត
- តម្លៃបរមាបរិមា ៖
  អនុគមន៍ $f$ មានតម្លៃអប្បបរមាធៀបត្រង់ $x = 1$ គឺ $f(1) = 1 - \ln(1) = 1$ ។
- តារាងអថេរភាព ៖

| $x$ | $0$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | ‖ $+\infty$ | ↘ | $1$ | ↗ | $+\infty$ |

**c** អាស៊ីមតូត និងបន្ទាត់ប៉ះ ៖

- បន្ទាត់ $x = 0$ (អ័ក្សអរដោនេ) ជាអាស៊ីមតូតឈរនៃក្រាប $C$ ព្រោះ $\lim\limits_{x\to 0^+} f(x) = +\infty$ ។
- ត្រង់ចំណុចអប្បបរមា $A(1,1)$ ក្រាប $C$ មានបន្ទាត់ប៉ះដេក (ស្របនឹងអ័ក្សអាប់ស៊ីស) មានសមីការ $y = 1$ ។

**d** សង់ក្រាប $C$ ៖




**2** សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ $y = f(x) = \dfrac{\ln x}{x}$ ។

**a** ដែនកំណត់ និងគណនាលីមីតត្រង់ចុងដែនកំណត់ ៖

- ដែនកំណត់ ៖ $D = ]0, +\infty[$
- $\lim\limits_{x\to 0^+} f(x) = \lim\limits_{x\to 0^+} \dfrac{\ln x}{x} = -\infty$
  (នាំឱ្យបន្ទាត់ $x = 0$ ឬអ័ក្សអរដោនេ ជាអាស៊ីមតូតឈរនៃក្រាប $C$)
- $\lim\limits_{x\to +\infty} f(x) = \lim\limits_{x\to +\infty} \dfrac{\ln x}{x} = 0$
  (នាំឱ្យបន្ទាត់ $y = 0$ ឬអ័ក្សអាប់ស៊ីស ជាអាស៊ីមតូតដេកនៃក្រាប $C$ ខាង $+\infty$)

**b** គណនាដេរីវេ $f'(x)$ សិក្សាសញ្ញារបស់វា និងសង់តារាងអថេរភាពនៃ $f$ ៖

- គណនាដេរីវេ ៖

$$f'(x) = \frac{(\ln x)' \cdot x - (\ln x)(x)'}{x^2} = \frac{\frac{1}{x} \cdot x - \ln x}{x^2} = \frac{1 - \ln x}{x^2}$$


- សិក្សាសញ្ញានៃ $f'(x)$ ៖
  ដោយ $x^2 > 0$ គ្រប់ $x \in ]0, +\infty[$ នាំឱ្យសញ្ញានៃ $f'(x)$ យកតាមសញ្ញានៃភាគយក $1 - \ln x$ ៖
  - $f'(x) = 0 \iff 1 - \ln x = 0 \iff \ln x = 1 \iff x = e$
  - ចំពោះ $x \in ]0, e[$ ៖ $f'(x) > 0 \implies f$ ជាអនុគមន៍កើនដាច់ខាត
  - ចំពោះ $x \in ]e, +\infty[$ ៖ $f'(x) < 0 \implies f$ ជាអនុគមន៍ចុះដាច់ខាត
- តម្លៃបរមាបរិមា ៖
  អនុគមន៍ $f$ មានតម្លៃអតិបរមាធៀបត្រង់ $x = e$ គឺ $f(e) = \dfrac{\ln e}{e} = \dfrac{1}{e}$ ។
- តារាងអថេរភាព ៖

| $x$ | $0$ | | $e$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $+$ | $0$ | $-$ | |
| $f(x)$ | ‖ $-\infty$ | ↗ | $\frac{1}{e}$ | ↘ | $0$ |

ⓒ អាស៊ីមតូត និងបន្ទាត់ប៉ះ ៖

- បន្ទាត់ $x=0$ (អ័ក្សអរដោនេ) ជាអាស៊ីមតូតឈរនៃក្រាប $C$ ព្រោះ $\lim\limits_{x\to 0^+} f(x) = -\infty$ ។
- បន្ទាត់ $y=0$ (អ័ក្សអាប់ស៊ីស) ជាអាស៊ីមតូតដេកនៃក្រាប $C$ ខាង $+\infty$ ព្រោះ $\lim\limits_{x\to +\infty} f(x) = 0$
- ត្រង់ចំណុចអតិបរមា $A\left(e, \frac{1}{e}\right)$ ក្រាប $C$ មានបន្ទាត់ប៉ះដេក (ស្របនឹងអ័ក្សអាប់ស៊ីស) មានសមីការ $y = \frac{1}{e}$ ។

ⓓ សង់ក្រាប $C$ ៖




**3** សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ $y = f(x) = e^x \ln x$

ⓐ ដែនកំណត់ និងគណនាលីមីតត្រង់ចុងដែនកំណត់ ៖

- ដែនកំណត់ ៖ $D = ]0, +\infty[$
- $\lim\limits_{x\to 0^+} f(x) = \lim\limits_{x\to 0^+} (e^x \ln x) = 1 \cdot (-\infty) = -\infty$
  (នាំឱ្យបន្ទាត់ $x=0$ ឬអ័ក្សអរដោនេ ជាអាស៊ីមតូតឈរនៃក្រាប $C$)
- $\lim\limits_{x\to +\infty} f(x) = \lim\limits_{x\to +\infty} (e^x \ln x) = (+\infty)(+\infty) = +\infty$

ⓑ គណនាដេរីវេ $f'(x)$ សិក្សាសញ្ញារបស់វា និងសង់តារាងអថេរភាពនៃ $f$ ៖

- គណនាដេរីវេ ៖

$$f'(x) = (e^x)' \ln x + e^x (\ln x)' = e^x \ln x + \frac{e^x}{x} = e^x \left(\ln x + \frac{1}{x}\right)$$

- សិក្សាសញ្ញានៃ $f'(x)$ ៖
  តាង $g(x) = \ln x + \dfrac{1}{x}$ លើ $]0,+\infty[$ ៖

$$g'(x) = \frac{1}{x} - \frac{1}{x^2} = \frac{x-1}{x^2}$$

  - $g'(x) = 0 \iff x - 1 = 0 \iff x = 1$
  - ចំពោះ $x \in ]0,1[$ ៖ $g'(x) < 0 \implies g$ ជាអនុគមន៍ចុះ
  - ចំពោះ $x \in ]1,+\infty[$ ៖ $g'(x) > 0 \implies g$ ជាអនុគមន៍កើន
  - តម្លៃអប្បបរមានៃ $g(x)$ គឺ $g(1) = \ln 1 + \dfrac{1}{1} = 1 > 0$

  ដូចនេះ $g(x) \geq 1 > 0$ គ្រប់ $x \in ]0,+\infty[$ នាំឱ្យ $f'(x) = e^x g(x) > 0$ គ្រប់ $x \in ]0,+\infty[$ ៖

  - $f$ ជាអនុគមន៍កើនដាច់ខាតលើ $]0,+\infty[$

- ចំណុចប្រសព្វ ៖
  ក្រាប $C$ កាត់អ័ក្សអាប់ស៊ីសត្រង់ $f(x) = 0 \iff e^x \ln x = 0 \iff \ln x = 0 \iff x = 1$ គឺចំណុច $(1,0)$ ។


- តារាងអថេរភាព ៖

| $x$ | $0$ | | $+\infty$ |
|---|---|---|---|
| $f'(x)$ | ‖ | $+$ | |
| $f(x)$ | ‖ $-\infty$ | ↗ | $+\infty$ |

◈ អាស៊ីមតូត និងបន្ទាត់ប៉ះ ៖

- បន្ទាត់ $x = 0$ (អ័ក្សអរដោនេ) ជាអាស៊ីមតូតឈរនៃក្រាប $C$ ព្រោះ $\lim\limits_{x \to 0^+} f(x) = -\infty$ ។
- ត្រង់ចំណុច $(1,0)$ ក្រាប $C$ មានបន្ទាត់ប៉ះមានសមីការ $y = f'(1)(x-1) + f(1) = e(x-1)$ ។

◈ សង់ក្រាប $C$ ៖




**4** សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ $y = f(x) = f(x) = x^2 - 8\ln x$

**a** ដែនកំណត់ និងគណនាលីមីតត្រង់ចុងដែនកំណត់ ៖

- ដែនកំណត់ ៖ $D = ]0, +\infty[$
- $\lim\limits_{x\to 0^+} f(x) = \lim\limits_{x\to 0^+} (x^2 - 8\ln x) = 0 - 8(-\infty) = +\infty$
  (នាំឱ្យបន្ទាត់ $x = 0$ ឬអ័ក្សអរដោនេ ជាអាស៊ីមតូតឈរនៃក្រាប $C$)
- $\lim\limits_{x\to +\infty} f(x) = \lim\limits_{x\to +\infty} x^2\left(1 - \dfrac{8\ln x}{x^2}\right) = +\infty(1-0) = +\infty$
  (ព្រោះ $\lim\limits_{x\to +\infty} \dfrac{\ln x}{x^2} = 0$)

**b** គណនាដេរីវេ $f'(x)$ សិក្សាសញ្ញារបស់វា និងសង់តារាងអថេរភាពនៃ $f$ ៖

- គណនាដេរីវេ ៖

$$f'(x) = (x^2)' - 8(\ln x)' = 2x - \frac{8}{x} = \frac{2(x^2-4)}{x}$$


- សិក្សាសញ្ញានៃ $f'(x)$ ៖
  ដោយ $x > 0$ គ្រប់ $x \in ]0, +\infty[$ នាំឱ្យសញ្ញានៃ $f'(x)$ យកតាមសញ្ញានៃភាគយក $x^2 - 4$ ៖
  - $f'(x) = 0 \iff x^2 - 4 = 0 \iff x = 2$ (ព្រោះ $x > 0$)
  - ចំពោះ $x \in ]0, 2[$ ៖ $f'(x) < 0 \implies f$ ជាអនុគមន៍ចុះដាច់ខាត
  - ចំពោះ $x \in ]2, +\infty[$ ៖ $f'(x) > 0 \implies f$ ជាអនុគមន៍កើនដាច់ខាត
- តម្លៃបរមាបរិមា ៖
  អនុគមន៍ $f$ មានតម្លៃអប្បបរមាធៀបត្រង់ $x = 2$ គឺ $f(2) = 2^2 - 8\ln 2 = 4 - 8\ln 2 \approx -1.55$ ។
- តារាងអថេរភាព ៖

| $x$ | $0$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | ‖ $+\infty$ | ↘ | $4-8\ln 2$ | ↗ | $+\infty$ |

ⓒ អាស៊ីមតូត និងបន្ទាត់ប៉ះ ៖

- បន្ទាត់ $x=0$ (អ័ក្សអរដោនេ) ជាអាស៊ីមតូតឈរនៃក្រាប $C$ ព្រោះ $\lim\limits_{x\to 0^+} f(x)=+\infty$ ។
- ត្រង់ចំណុចអប្បបរមា $A(2,4-8\ln 2)$ ក្រាប $C$ មានបន្ទាត់ប៉ះដេក (ស្របនឹងអ័ក្សអាប់ស៊ីស) មានសមីការ $y=4-8\ln 2$ ។

ⓓ សង់ក្រាប $C$ ៖




**5** សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ $y=f(x)=y=x^2\ln x$

ⓐ ដែនកំណត់ និងគណនាលីមីតត្រង់ចុងដែនកំណត់ ៖

- ដែនកំណត់ ៖ $D=]0,+\infty[$
- $\lim\limits_{x\to 0^+} f(x)=\lim\limits_{x\to 0^+}(x^2\ln x)=0$
  (ព្រោះ $\lim\limits_{x\to 0^+} x^2\ln x=0$ នាំឱ្យក្រាប $C$ ទិតជិតចំណុចគល់ $O(0,0)$)
- $\lim\limits_{x\to+\infty} f(x)=\lim\limits_{x\to+\infty}(x^2\ln x)=(+\infty)(+\infty)=+\infty$

ⓑ គណនាដេរីវេ $f'(x)$ សិក្សាសញ្ញារបស់វា និងសង់តារាងអថេរភាពនៃ $f$ ៖

- គណនាដេរីវេ ៖

$$f'(x)=(x^2)'\ln x+x^2(\ln x)'=2x\ln x+x=x(2\ln x+1)$$

- សិក្សាសញ្ញានៃ $f'(x)$ ៖

ដោយ $x>0$ គ្រប់ $x\in]0,+\infty[$ នាំឱ្យសញ្ញានៃ $f'(x)$ យកតាមសញ្ញានៃ $2\ln x+1$ ៖

· $f'(x)=0 \iff 2\ln x+1=0 \iff \ln x=-\dfrac{1}{2} \iff x=e^{-1/2}=\dfrac{1}{\sqrt{e}}$

· ចំពោះ $x\in\left]0,\dfrac{1}{\sqrt{e}}\right[$ ៖ $f'(x)<0 \implies f$ ជាអនុគមន៍ចុះដាច់ខាត

· ចំពោះ $x\in\left]\dfrac{1}{\sqrt{e}},+\infty\right[$ ៖ $f'(x)>0 \implies f$ ជាអនុគមន៍កើនដាច់ខាត

○ តម្លៃបរមាបរិមា ៖

អនុគមន៍ $f$ មានតម្លៃអប្បបរមាធៀបត្រង់ $x=\dfrac{1}{\sqrt{e}}$ គឺ $f\left(\dfrac{1}{\sqrt{e}}\right)=\left(\dfrac{1}{\sqrt{e}}\right)^2\ln\left(\dfrac{1}{\sqrt{e}}\right)=-\dfrac{1}{2e}$ ។

○ ចំណុចប្រសព្វ ៖

ក្រាប $C$ កាត់អ័ក្សអាប់ស៊ីសត្រង់ $f(x)=0 \iff x^2\ln x=0 \iff x=1$ គឺចំណុច $(1,0)$ ។

○ តារាងអថេរភាព ៖


| $x$ | $0$ | | $\dfrac{1}{\sqrt{e}}$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $0$ ‖ $0$ | ↘ | $-\dfrac{1}{2e}$ | ↗ | $+\infty$ |

ⓒ អាស៊ីមតូត និងបន្ទាត់ប៉ះ ៖

○ ក្រាប $C$ គ្មានអាស៊ីមតូតទេ ព្រោះ $\lim\limits_{x\to0^+}f(x)=0$ និង $\lim\limits_{x\to+\infty}f(x)=+\infty$ ។

○ ត្រង់ចំណុចអប្បបរមា $A\left(\dfrac{1}{\sqrt{e}},-\dfrac{1}{2e}\right)$ ក្រាប $C$ មានបន្ទាត់ប៉ះដេក (ស្របនឹងអ័ក្សអាប់ស៊ីស) មានសមីការ $y=-\dfrac{1}{2e}$ ។

ⓓ សង់ក្រាប $C$ ៖




**6** សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ $y=f(x)=2x+\dfrac{x}{\ln x}$

**a** ដែនកំណត់ និងគណនាលីមីតត្រង់ចុងដែនកំណត់ ៖

- ដែនកំណត់ ៖ $D=]0,1[\cup]1,+\infty[$
- $\lim\limits_{x\to 0^+} f(x)=\lim\limits_{x\to 0^+}\left(2x+\dfrac{x}{\ln x}\right)=0+0=0$
- $\lim\limits_{x\to 1^-} f(x)=\lim\limits_{x\to 1^-}\left(2x+\dfrac{x}{\ln x}\right)=2+(-\infty)=-\infty$
- $\lim\limits_{x\to 1^+} f(x)=\lim\limits_{x\to 1^+}\left(2x+\dfrac{x}{\ln x}\right)=2+(+\infty)=+\infty$

  (នាំឱ្យបន្ទាត់ $x=1$ ជាអាស៊ីមតូតឈរនៃក្រាប $C$)
- $\lim\limits_{x\to+\infty} f(x)=\lim\limits_{x\to+\infty}\left(2x+\dfrac{x}{\ln x}\right)=+\infty+(+\infty)=+\infty$

**b** គណនាដេរីវេ $f'(x)$ សិក្សាសញ្ញារបស់វា និងសង់តារាងអថេរភាពនៃ $f$ ៖

- គណនាដេរីវេ ៖

$$f'(x)=2+\frac{(x)'\ln x-x(\ln x)'}{(\ln x)^2}=\frac{2(\ln x)^2+\ln x-1}{(\ln x)^2}$$

- សិក្សាសញ្ញានៃ $f'(x)$ ៖

  ដោយ $(\ln x)^2>0$ គ្រប់ $x\in D$ នាំឱ្យសញ្ញានៃ $f'(x)$ យកតាមសញ្ញានៃភាគយក $2(\ln x)^2+\ln x-1$ ៖

  · $f'(x)=0 \iff \ln x=-1$ ឬ $\ln x=\dfrac{1}{2} \iff x=\dfrac{1}{e}$ ឬ $x=\sqrt{e}$

  · ចំពោះ $x\in\left]0,\dfrac{1}{e}\right[\cup]\sqrt{e},+\infty[$ ៖ $f'(x)>0 \implies f$ ជាអនុគមន៍កើនដាច់ខាត

  · ចំពោះ $x\in\left]\dfrac{1}{e},1\right[\cup]1,\sqrt{e}[$ ៖ $f'(x)<0 \implies f$ ជាអនុគមន៍ចុះដាច់ខាត

- តម្លៃបរមាបរិមា ៖

  · អនុគមន៍ $f$ មានតម្លៃអតិបរមាធៀបត្រង់ $x=\dfrac{1}{e}$ គឺ $f\left(\dfrac{1}{e}\right)=\dfrac{1}{e}$ ។

  · អនុគមន៍ $f$ មានតម្លៃអប្បបរមាធៀបត្រង់ $x=\sqrt{e}$ គឺ $f(\sqrt{e})=4\sqrt{e}$ ។


- ចំណុចប្រសព្វ ៖
  ក្រាប $C$ កាត់អ័ក្សអាប់ស៊ីសត្រង់ $f(x)=0 \iff \ln x=-\frac{1}{2} \iff x=\frac{1}{\sqrt{e}}$ គឺចំណុច $\left(\frac{1}{\sqrt{e}},0\right)$ ។
- តារាងអថេរភាព ៖

| $x$ | $0$ | | $\frac{1}{e}$ | | $1$ | | $\sqrt{e}$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | ‖ | $+$ | $0$ | $-$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $0$ | $\nearrow$ | $\frac{1}{e}$ | $\searrow$ | ‖ | $\searrow$ | $4\sqrt{e}$ | $\nearrow$ | $+\infty$ |
| | | | $-\infty$ | | | $+\infty$ | | | |

ⓒ អាស៊ីមតូត និងបន្ទាត់ប៉ៈ ៖

- បន្ទាត់ $x=1$ ជាអាស៊ីមតូតឈរនៃក្រាប $C$ ព្រោះ $\lim\limits_{x\to 1^-} f(x)=-\infty$ និង $\lim\limits_{x\to 1^+} f(x)=+\infty$ ។
- ត្រង់ចំណុចអតិបរមា $A\left(\frac{1}{e},\frac{1}{e}\right)$ ក្រាប $C$ មានបន្ទាត់ប៉ៈដេក (ស្របនឹងអ័ក្សអាប់ស៊ីស) មានសមីការ $y=\frac{1}{e}$ ។
- ត្រង់ចំណុចអប្បបរមា $B(\sqrt{e},4\sqrt{e})$ ក្រាប $C$ មានបន្ទាត់ប៉ៈដេក (ស្របនឹងអ័ក្សអាប់ស៊ីស) មានសមីការ $y=4\sqrt{e}$ ។

ⓓ សង់ក្រាប $C$ ៖




**7** អនុគមន៍ $f$ កំណត់លើ $\mathbb{R}\setminus\{0\}$ ដោយ $f(x)=\ln(x^2)$ មានក្រាប $C$ ។

ⓐ គណនាលីមីតត្រង់ចុងដែនកំណត់ និងរកសមីការអាស៊ីមតូត ៖

- $\lim\limits_{x\to-\infty} f(x)=\lim\limits_{x\to-\infty}\ln(x^2)=+\infty$
- $\lim\limits_{x\to+\infty} f(x)=\lim\limits_{x\to+\infty}\ln(x^2)=+\infty$

- $\lim\limits_{x\to 0} f(x) = \lim\limits_{x\to 0} \ln(x^2) = -\infty$
- អាស៊ីមតូត ៖ បន្ទាត់ $x = 0$ (អ័ក្សអរដោនេ) ជាអាស៊ីមតូតឈរនៃក្រាប $C$ ព្រោះ $\lim\limits_{x\to 0} f(x) = -\infty$ ៕

(b) សិក្សាអថេរភាពអនុគមន៍ $f$ និងសង់តារាងអថេរភាព ៖

- គណនាដេរីវេ ៖

$$f'(x) = \frac{(x^2)'}{x^2} = \frac{2x}{x^2} = \frac{2}{x}$$

- សិក្សាសញ្ញានៃ $f'(x)$ ៖
  - ចំពោះ $x \in ]-\infty, 0[$ ៖ $f'(x) < 0 \implies f$ ជាអនុគមន៍ចុះដាច់ខាត
  - ចំពោះ $x \in ]0, +\infty[$ ៖ $f'(x) > 0 \implies f$ ជាអនុគមន៍កើនដាច់ខាត
- តារាងអថេរភាព ៖


| $x$ | $-\infty$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | $-$ | $d$ | $+$ | | |
| $f(x)$ | $+\infty$ ↘ | $-\infty$ | ‖ $-\infty$ | ↗ | $+\infty$ |

(c) រកសមីការបន្ទាត់ប៉ះ $d_1$ និង $d_2$ ៖

- បន្ទាត់ប៉ះ $d_1$ ត្រង់ $A(e, 2)$ ៖
  មេគុណប្រាប់ទិស $f'(e) = \frac{2}{e} \implies d_1 : y = \frac{2}{e}(x - e) + 2 = \frac{2}{e}x$ ៕
- បន្ទាត់ប៉ះ $d_2$ ត្រង់ $B(-e, 2)$ ៖
  មេគុណប្រាប់ទិស $f'(-e) = -\frac{2}{e} \implies d_2 : y = -\frac{2}{e}(x + e) + 2 = -\frac{2}{e}x$ ៕

(d) ចំណុចប្រសព្វរវាងក្រាប $C$ និងអ័ក្សអាប់ស៊ីស និងការសង់ក្រាប ៖

- ចំណុចប្រសព្វ ៖ $f(x) = 0 \iff \ln(x^2) = 0 \iff x^2 = 1 \iff x = \pm 1$ គឺចំណុច $(-1, 0)$ និង $(1, 0)$ ៕
- សង់ក្រាប $C, d_1$ និង $d_2$ ៖




## ការប្រែងលំហាត់បន្ថែម

**1** គណនាតម្លៃនៃកន្សោមខាងក្រោម ៖

ⓐ $e^{\ln 7}$ ⓑ $\ln e^{x-2}$ ⓒ $\ln e^{7x}$

**2** គណនាលីមីតនៃអនុគមន៍ខាងក្រោម ៖

ⓐ $\lim\limits_{x\to+\infty} x^5 \ln x$ ⓑ $\lim\limits_{x\to+\infty} \dfrac{(1+\ln x)}{x^2}$ ⓒ $\lim\limits_{x\to 0}(x \ln x)$

**3** គណនាដេរីវេនៃអនុគមន៍ខាងក្រោម ៖

ⓐ $y = \sqrt{x} \cdot \ln x$ ⓑ $y = x^2\sqrt{\ln x}$ ⓒ $y = \ln(x + \sqrt{1+x^2})$

**4** គណនាដេរីវេនៃអនុគមន៍ខាងក្រោម ៖

ⓐ $y = \ln \dfrac{e^x}{e^x+1}$ ⓑ $y = x \ln x - x$ ⓒ $y = x^2 \ln \dfrac{1}{x^2}$

**5** សង់ក្រាបនៃអនុគមន៍

ⓐ $y = 3 - \ln x$ ⓑ $y = \ln(x-3)$ ⓒ $y = \ln(2+e^x)$

**6** សិក្សាអថេរភាពនិងសង់ក្រាបនៃអនុគមន៍ខាងក្រោម ៖

ⓐ $y = \dfrac{x}{\ln x}$ ⓑ $y = \ln x + e^x$ ⓒ $y = \ln^2 x + \dfrac{1}{\ln^2 x + 2}$ ។

**7** សិក្សាអថេរភាពនិងសង់ក្រាបនៃអនុគមន៍ខាងក្រោម ៖

ⓐ $y = \dfrac{x^2}{2} - \ln x$

ⓑ $y = 2x - x\ln x$

**8** ⓐ សិក្សាអថេរភាពនិងសង់ក្រាប $C$ របស់អនុគមន៍ $y = -2\ln|x| + x - 2$

ⓑ ក្រាប $C$ កាត់ $Ox$ ត្រង់បីចំណុច $P, Q, R$ ដែលមានអាប់ស៊ីសរៀងគ្នា $p, q, r$ ។
ចូរបៀបធៀប $p, q, r$ និងបណ្តាចំនួន $-1, 0, 1, 5, 6$ ។

**9** រោងចក្រឧស្សាហកម្មមួយបានទិញម៉ាស៊ីនហុត្តតម្លៃ 250 ដុល្លារ ហើយមានអត្រាតម្លៃថយចុះ 25 % ក្នុងមួយឆ្នាំ ។ តើបីឆ្នាំក្រោយ ម៉ាស៊ីនហុត្តនេះនឹងមានតម្លៃប៉ុន្មាន ?

**10** បាក់តេរីមួយប្រភេទបំបែកខ្លួនដោយមានមេគុណអត្រាកំណើន $k = 0.872$ ដែល $t$ គិតជាថ្ងៃ ។
បើដំបូងមានបាក់តេរីចំនួន 9 តើរយៈពេលប៉ុន្មានថ្ងៃ ទើបចំនួនបាក់តេរីកើនដល់ 738 ?

**11** នៅទីក្រុងមួយកាលពី 10 ឆ្នាំមុន មានប្រជាជនចំនួន 45600 នាក់ ហើយចំនួនប្រជាជនមានការកើនឡើងដោយអត្រាមួយថេរជារៀងរាល់ឆ្នាំ ។ បើបច្ចុប្បន្នមានប្រជាជនចំនួន 64800 នាក់ រកអត្រាកំណើននៃចំនួនប្រជាជនប្រចាំឆ្នាំក្នុងទីក្រុងនេះ ។

## ចម្លើយកម្រងលំហាត់បន្ថែម

**1** គណនាតម្លៃនៃកន្សោមខាងក្រោម ៖

ⓐ $e^{\ln 7} = 7$

ⓑ $\ln e^{x-2} = x - 2$

ⓒ $\ln e^{7x} = 7x$

**2** គណនាលីមីតនៃអនុគមន៍ខាងក្រោម ៖

ⓐ $\lim\limits_{x\to+\infty} x^5 \ln x$

កាលណា $x \to +\infty$ យើងបាន $x^5 \to +\infty$ និង $\ln x \to +\infty$

ដូចនេះ $\lim\limits_{x\to+\infty} x^5 \ln x = +\infty$

ⓑ $\lim\limits_{x\to+\infty} \dfrac{1+\ln x}{x^2}$

បំបែកភាគយក ៖

$\lim\limits_{x\to+\infty} \left(\dfrac{1}{x^2} + \dfrac{\ln x}{x^2}\right)$ ដោយ $\lim\limits_{x\to+\infty} \dfrac{1}{x^2} = 0$ និងតាមរូបមន្តគ្រឹះ $\lim\limits_{x\to+\infty} \dfrac{\ln x}{x^2} = 0$

ដូចនេះ $\lim\limits_{x\to+\infty} \dfrac{1+\ln x}{x^2} = 0 + 0 = 0$

ⓒ $\lim\limits_{x\to 0^+} (x\ln x)$

តាមរូបមន្តលីមីតគ្រឹះ $\lim\limits_{x\to 0^+} x^n \ln x = 0$ (ចំពោះ $n > 0$)

ដូចនេះ $\lim\limits_{x\to 0^+} (x\ln x) = 0$

**3** គណនាដេរីវេនៃអនុគមន៍ខាងក្រោម ៖

◈ $y = \sqrt{x} \cdot \ln x \quad (x > 0)$

តាមរូបមន្តផលគុណដេរីវេ $(uv)' = u'v + uv'$ ៖

$$\begin{aligned} y' &= (\sqrt{x})' \cdot \ln x + \sqrt{x} \cdot (\ln x)' \\ &= \frac{1}{2\sqrt{x}} \cdot \ln x + \sqrt{x} \cdot \frac{1}{x} \\ &= \frac{\ln x}{2\sqrt{x}} + \frac{1}{\sqrt{x}} \\ &= \frac{\ln x + 2}{2\sqrt{x}} \end{aligned}$$

◈ $y = x^2\sqrt{\ln x} \quad (x > 1)$

តាមរូបមន្តផលគុណដេរីវេ $(uv)' = u'v + uv'$ និងរូបមន្តបណ្តាក់ $(\sqrt{u})' = \dfrac{u'}{2\sqrt{u}}$ ៖

$$\begin{aligned} y' &= (x^2)' \cdot \sqrt{\ln x} + x^2 \cdot (\sqrt{\ln x})' \\ &= 2x\sqrt{\ln x} + x^2 \cdot \frac{(\ln x)'}{2\sqrt{\ln x}} \\ &= 2x\sqrt{\ln x} + x^2 \cdot \frac{\frac{1}{x}}{2\sqrt{\ln x}} \\ &= 2x\sqrt{\ln x} + \frac{x}{2\sqrt{\ln x}} \\ &= \frac{4x\ln x + x}{2\sqrt{\ln x}} = \frac{x(4\ln x + 1)}{2\sqrt{\ln x}} \end{aligned}$$

◈ $y = \ln(x + \sqrt{1 + x^2})$

តាមរូបមន្តដេរីវេបណ្តាក់ $(\ln u)' = \dfrac{u'}{u}$ ដែល $u = x + \sqrt{1 + x^2}$ ៖

គណនា $u'$ ៖

$$u' = (x + \sqrt{1 + x^2})' = 1 + \frac{2x}{2\sqrt{1 + x^2}} = 1 + \frac{x}{\sqrt{1 + x^2}} = \frac{\sqrt{1 + x^2} + x}{\sqrt{1 + x^2}}$$

ជំនួសចូលរូបមន្ត $y' = \dfrac{u'}{u}$ ៖

$$y' = \frac{\frac{\sqrt{1 + x^2} + x}{\sqrt{1 + x^2}}}{x + \sqrt{1 + x^2}} = \frac{1}{\sqrt{1 + x^2}}$$

**4** គណនាដេរីវេនៃអនុគមន៍ខាងក្រោម ៖

**a** $y = \ln \dfrac{e^x}{e^x+1}$

សម្រួលអនុគមន៍តាមលក្ខណៈលោការីត ៖ $y = \ln(e^x) - \ln(e^x+1) = x - \ln(e^x+1)$

គណនាដេរីវេ ៖

$$\begin{aligned} y' &= (x - \ln(e^x+1))' \\ &= 1 - \frac{(e^x+1)'}{e^x+1} \\ &= 1 - \frac{e^x}{e^x+1} \\ &= \frac{e^x+1-e^x}{e^x+1} \\ &= \frac{1}{e^x+1} \end{aligned}$$

**b** $y = x\ln x - x$

គណនាដេរីវេតាមរូបមន្តផលគុណ $(uv)' = u'v + uv'$ ៖

$$\begin{aligned} y' &= (x)'\ln x + x(\ln x)' - (x)' \\ &= 1\cdot \ln x + x\cdot \frac{1}{x} - 1 \\ &= \ln x + 1 - 1 = \ln x \end{aligned}$$

**c** $y = x^2 \ln \dfrac{1}{x^2}$

សម្រួលអនុគមន៍តាមលក្ខណៈលោការីត ៖ $y = x^2\ln(x^{-2}) = -2x^2\ln x$

គណនាដេរីវេ ៖


$$\begin{aligned} y' &= (-2x^2)'\ln x + (-2x^2)(\ln x)' \\ &= -4x\ln x - 2x^2\cdot\frac{1}{x} \\ &= -4x\ln x - 2x \\ &= -2x(2\ln x + 1) \end{aligned}$$

**5** សង់ក្រាបនៃអនុគមន៍

**a** អនុគមន៍ $y = 3 - \ln x$ ៖


- ដែនកំណត់ ៖ $D = ]0, +\infty[$

- លីមីត ៖ $\lim\limits_{x\to 0^+}(3-\ln x)=+\infty$ (បន្ទាត់ $x=0$ ជាអាស៊ីមតូតឈរ)
  $\lim\limits_{x\to+\infty}(3-\ln x)=-\infty$
- ដេរីវេ ៖ $y'=-\dfrac{1}{x}<0$ គ្រប់ $x>0 \implies$ អនុគមន៍ចុះដាច់ខាត




**b** អនុគមន៍ $y=\ln(x-3)$ ៖

- ដែនកំណត់ ៖ $D=]3,+\infty[$
- លីមីត ៖ $\lim\limits_{x\to 3^+}\ln(x-3)=-\infty$ (បន្ទាត់ $x=3$ ជាអាស៊ីមតូតឈរ)
  $\lim\limits_{x\to+\infty}\ln(x-3)=+\infty$
- ដេរីវេ ៖ $y'=\dfrac{1}{x-3}>0$ គ្រប់ $x>3 \implies$ អនុគមន៍កើនដាច់ខាត





**c** អនុគមន៍ $y=\ln(2+e^x)$ ៖

- ដែនកំណត់ ៖ $D=]-\infty,+\infty[$
- លីមីត និងអាស៊ីមតូត ៖ $\lim\limits_{x\to-\infty}\ln(2+e^x)=\ln 2 \implies y=\ln 2$ ជាអាស៊ីមតូតដេក

$\lim\limits_{x\to+\infty}\ln(2+e^x)=+\infty$ និង $\lim\limits_{x\to+\infty}[\ln(2+e^x)-x]=0 \Longrightarrow y=x$ ជាអាស៊ីមតូតទ្រេត


- ដេរីវេ ៖ $y'=\dfrac{e^x}{2+e^x}>0$ គ្រប់ $x\in\mathbb{R} \Longrightarrow$ អនុគមន៍កើនដាច់ខាត




**6** សិក្សាអថេរភាពនិងសង់ក្រាបនៃអនុគមន៍ខាងក្រោម ៖

**a** អនុគមន៍ $y=\dfrac{x}{\ln x}$ ៖


- ដែនកំណត់ ៖ $D=]0,1[\cup]1,+\infty[$
- លីមីត ៖ $\lim\limits_{x\to0^+}\dfrac{x}{\ln x}=0$, $\lim\limits_{x\to1^-}\dfrac{x}{\ln x}=-\infty$, $\lim\limits_{x\to1^+}\dfrac{x}{\ln x}=+\infty$ ($x=1$ ជាអាស៊ីមតូតឈរ), $\lim\limits_{x\to+\infty}\dfrac{x}{\ln x}=+\infty$
- ដេរីវេ ៖ $y'=\dfrac{\ln x-1}{\ln^2 x}$
- អប្បបរមា ៖ ត្រង់ $x=e$ គឺ $y=e$




**b** អនុគមន៍ $y=\ln x+e^x$ ៖


- ដែនកំណត់ ៖ $D=]0,+\infty[$

- លីមីត ៖ $\lim\limits_{x\to 0^+}(\ln x+e^x)=-\infty$ (បន្ទាត់ $x=0$ ជាអាស៊ីមតូតឈរ), $\lim\limits_{x\to+\infty}(\ln x+e^x)=+\infty$
- ដេរីវេ ៖ $y'=\dfrac{1}{x}+e^x>0$ គ្រប់ $x>0\implies$ អនុគមន៍កើនដាច់ខាត




◈ អនុគមន៍ $y=\ln^2 x+\dfrac{1}{\ln^2 x+2}$ ៖

- ដែនកំណត់ ៖ $D=]0,+\infty[$
- លីមីត ៖ $\lim\limits_{x\to 0^+}h(x)=+\infty$ (បន្ទាត់ $x=0$ ជាអាស៊ីមតូតឈរ), $\lim\limits_{x\to+\infty}h(x)=+\infty$
- ដេរីវេ ៖ $y'=\dfrac{2\ln x}{x}\left(1-\dfrac{1}{(\ln^2 x+2)^2}\right)$
- អប្បបរមា ៖ ត្រង់ $x=1$ គឺ $y=\dfrac{1}{2}$





**7** សិក្សាអថេរភាពនិងសង់ក្រាបនៃអនុគមន៍ខាងក្រោម ៖

◈ អនុគមន៍ $y=f(x)=\dfrac{x^2}{2}-\ln x$ ៖

- ដែនកំណត់ ៖ $D=]0,+\infty[$

- លីមីត ៖ $\lim\limits_{x\to 0^+} f(x) = +\infty$ ($x=0$ ជាអាស៊ីមតូតឈរ), $\lim\limits_{x\to +\infty} f(x) = +\infty$
- ដេរីវេ ៖ $f'(x) = x - \dfrac{1}{x} = \dfrac{x^2-1}{x}$
- អប្បបរមា ៖ ត្រង់ $x=1$ គឺ $f(1) = \dfrac{1}{2}$
- តារាងអថេរភាព ៖


| $x$ | $0$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | ‖ $+\infty$ | ↘ | $\frac{1}{2}$ | ↗ | $+\infty$ |




**b** អនុគមន៍ $y = g(x) = 2x - x\ln x$ ៖

- ដែនកំណត់ ៖ $D = ]0, +\infty[$
- លីមីត ៖ $\lim\limits_{x\to 0^+} g(x) = 0$, $\lim\limits_{x\to +\infty} g(x) = -\infty$
- ដេរីវេ ៖ $g'(x) = 1 - \ln x$
- អតិបរមា ៖ ត្រង់ $x = e$ គឺ $g(e) = e$
- ប្រសព្វអ័ក្សអាប់ស៊ីស ៖ ត្រង់ $x = e^2$
- តារាងអថេរភាព ៖


| $x$ | $0$ | | $e$ | | $+\infty$ |
|---|---|---|---|---|---|
| $g'(x)$ | ‖ | $+$ | $0$ | $-$ | |
| $g(x)$ | ‖ | $0$ ↗ | $e$ | ↘ $-\infty$ | |




**8** ◈ **a** សិក្សាអថេរភាព និងសង់ក្រាប $C$ ៖

- ដែនកំណត់ ៖ $D = \mathbb{R} \setminus \{0\} = ]-\infty, 0[\cup]0, +\infty[$
- លីមីត និងអាស៊ីមតូត ៖
  - $\lim\limits_{x\to-\infty} f(x) = -\infty$, $\lim\limits_{x\to+\infty} f(x) = +\infty$
  - $\lim\limits_{x\to0^-} f(x) = +\infty$, $\lim\limits_{x\to0^+} f(x) = +\infty$
  - បន្ទាត់ $x = 0$ (អ័ក្សអរដោនេ) ជាអាស៊ីមតូតឈរនៃក្រាប $C$ ។
- ដេរីវេ និងអថេរភាព ៖ $f'(x) = \dfrac{x-2}{x}$
  - ចំពោះ $x \in ]-\infty, 0[\cup]2, +\infty[$ ៖ $f'(x) > 0 \implies f$ ជាអនុគមន៍កើន
  - ចំពោះ $x \in ]0, 2[$ ៖ $f'(x) < 0 \implies f$ ជាអនុគមន៍ចុះ
  - តម្លៃអប្បបរមាធៀបត្រង់ $x = 2$ គឺ $f(2) = -2\ln 2 \approx -1.39$
- តារាងអថេរភាព ៖

| $x$ | $-\infty$ | | $0$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | ↗ | $+\infty$ ‖ $+\infty$ | ↘ | $-2\ln 2$ | ↗ | $+\infty$ |




(b) ប្រៀបធៀប $p, q, r$ និងបណ្តាចំនួន $-1, 0, 1, 5, 6$ ៖

- កំណត់ទីតាំង $p$ ៖ $f(-1) = -3 < 0$ និង $\lim\limits_{x \to 0^-} f(x) = +\infty > 0$ ដោយ $f$ ជាប់ និងកើនដាច់ខាតលើ $]-1, 0[$ នាំឱ្យ $p \in ]-1, 0[ \implies -1 < p < 0$ ។
- កំណត់ទីតាំង $q$ ៖ $\lim\limits_{x \to 0^+} f(x) = +\infty > 0$ និង $f(1) = -1 < 0$ ដោយ $f$ ជាប់ និងចុះដាច់ខាតលើ $]0, 1[$ នាំឱ្យ $q \in ]0, 1[ \implies 0 < q < 1$ ។
- កំណត់ទីតាំង $r$ ៖ $f(5) = 3 - 2\ln 5 \approx -0.22 < 0$ និង $f(6) = 4 - 2\ln 6 \approx 0.42 > 0$ ដោយ $f$ ជាប់ និងកើនដាច់ខាតលើ $]5, 6[$ នាំឱ្យ $r \in ]5, 6[ \implies 5 < r < 6$ ។

សន្និដ្ឋាន ៖ $-1 < p < 0 < q < 1 < 5 < r < 6$

**9** រោងចក្រឧស្សាហកម្មមួយបានទិញម៉ាស៊ីនហុត្តតម្លៃ 250 ដុល្លារ ហើយមានអត្រាតម្លៃថយចុះ 25 % ក្នុងមួយឆ្នាំ ។ តើបីឆ្នាំក្រោយ ម៉ាស៊ីនហុត្តនេះនឹងមានតម្លៃប៉ុន្មាន ?

តាមរូបមន្ត

$$V = V_0 \times (1 - r)^t$$

ប្រាប់ទិន្នន័យ៖

- តម្លៃដើម $(V_0) = 250$ ដុល្លារ
- អត្រាតម្លៃថយចុះ $(r) = 25\% = 0.25$
- រយៈពេល $(t) = 3$ ឆ្នាំ

រៀបគណនា៖

$$\begin{aligned} V &= 250 \times (1 - 0.25)^3 \\ &= 250 \times (0.75)^3 \\ &= 250 \times 0.421875 \\ &= 105.46875 \text{ ដុល្លារ} \end{aligned}$$

សន្និដ្ឋាន៖
ដូចនេះ បីឆ្នាំក្រោយ ម៉ាស៊ីននេះនឹងមានតម្លៃប្រមាណ 105.47 ដុល្លារ (ឬ 105.46875 ដុល្លារ) ។

**10** បាក់តេរីមួយប្រភេទបំបែកខ្លួនដោយមានមេគុណអត្រាកំណើន $k = 0.872$ ដែល $t$ គិតជាថ្ងៃ ។ បើដំបូងមានបាក់តេរីចំនួន 9 តើរយៈពេលប៉ុន្មានថ្ងៃ ទើបចំនួនបាក់តេរីកើនដល់ 738 ?

តាមរូបមន្ត $N(t) = N_0\, e^{kt}$

ប្រាប់ទិន្នន័យ៖

- ចំនួនបាក់តេរីដើម ($N_0$) = 9
- មេគុណអត្រាកំណើន ($k$) = 0.872
- ចំនួនបាក់តេរីសរុប ($N(t)$) = 738
- រយៈពេល ($t$) គិតជាថ្ងៃ

រៀបគណនា៖

$$\begin{aligned} 738 &= 9 \cdot e^{0.872t} \\ \frac{738}{9} &= e^{0.872t} \\ 82 &= e^{0.872t} \end{aligned}$$

បំពាក់លោការីតធម្មជាតិ (ln) លើអង្គទាំងពីរ ៖

$$\begin{aligned} \ln(82) &= \ln\left(e^{0.872t}\right) \\ \ln(82) &= 0.872t \\ t &= \frac{\ln(82)}{0.872} \end{aligned}$$

ដោយសារ $\ln(82) \approx 4.4067$ ៖

$$t \approx \frac{4.4067}{0.872} \approx 5.05 \text{ ថ្ងៃ}$$

សន្និដ្ឋាន៖

ដូចនេះ រយៈពេលប្រមាណ 5.05 ថ្ងៃ (ឬប្រហែល 5 ថ្ងៃ) ទើបចំនួនបាក់តេរីកើនឡើងដល់ 738 ។

**11** នៅទីក្រុងមួយកាលពី 10 ឆ្នាំមុន មានប្រជាជនចំនួន 45600 នាក់ ហើយចំនួនប្រជាជនមានការកើនឡើងដោយអត្រាមួយថេរជារៀងរាល់ឆ្នាំ ។ បើបច្ចុប្បន្នមានប្រជាជនចំនួន 64800 នាក់ រកអត្រាកំណើននៃចំនួនប្រជាជនប្រចាំឆ្នាំក្នុងទីក្រុងនេះ ។

តាមរូបមន្តកំណើនសមាស $P(t) = P_0(1+r)^t$

ប្រាប់ទិន្នន័យ៖

- ចំនួនប្រជាជនកាលពី 10 ឆ្នាំមុន ($P_0$) = 45600 នាក់
- ចំនួនប្រជាជនបច្ចុប្បន្ន ($P(t)$) = 64800 នាក់
- រយៈពេល ($t$) = 10 ឆ្នាំ
- អត្រាកំណើនប្រចាំឆ្នាំ ($r$) ជាភាគរយដែលត្រូវរក

របៀបគណនា៖

$$\begin{aligned} 64800 &= 45600 \cdot (1+r)^{10} \\ \frac{64800}{45600} &= (1+r)^{10} \\ \frac{27}{19} &= (1+r)^{10} \\ 1.42105 &\approx (1+r)^{10} \end{aligned}$$

ទាញឫសទី 10 លើអង្គទាំងពីរ ៖

$$\begin{aligned} 1+r &= (1.42105)^{\frac{1}{10}} \\ 1+r &\approx 1.03576 \\ r &\approx 1.03576 - 1 = 0.03576 \implies r \approx 3.58\% \end{aligned}$$

## លំហាត់បាក់ឌុប

**1** (ឆ្នាំ ២០២៦ ថ្នាក់វិទ្យាសាស្ត្រ)

**a** គេមានអនុគមន៍ $g(x)$ កំណត់លើ $\mathbb{R}$ ដោយ $g(x) = 2 + 2e^{2x} - 5e^x$ ។ ផ្ទៀងផ្ទាត់ថា $g(x) = (e^x - 2)(2e^x - 1)$ រួចសិក្សាសញ្ញានៃ $g(x)$ ទៅតាមតម្លៃនៃ $x$ នៅលើសំណុំចំនួនពិត $\mathbb{R}$ ។

**b** គេមានអនុគមន៍ $f(x)$ កំណត់លើ $\mathbb{R}$ ដោយ $f(x) = \dfrac{1}{1+e^x} + \dfrac{2x+18}{9}$ និងគេតាងដោយ $(C)$ ក្រាបរបស់វា ។

រកលីមីតនៃ $f(x)$ ត្រង់ $+\infty$ និង $-\infty$ ។ រកដេរីវេ $f'(x)$ នៃ $f(x)$ រួចបង្ហាញថាគ្រប់ចំនួនពិត $x$,

$f'(x)$ មានសញ្ញាដូច $g(x)$ ។

ⓒ សិក្សាអថេរភាពនៃ $f(x)$ លើ $\mathbb{R}$ ។ បង្ហាញថាគ្រប់ $x$ ក្នុងចន្លោះ $[-\ln 2, +\ln 2]$ $f(x)$ វិជ្ជមាន ។

ⓓ បង្ហាញថាបន្ទាត់ $(D_1)$ សមីការ $y = \frac{2}{9}x + 3$ ជាអាស៊ីមតូតនៃ $(C)$ ត្រង់ $-\infty$ និងបន្ទាត់ $(D_2)$ សមីការ $y = \frac{2}{9}x + 2$ ជាអាស៊ីមតូតនៃ $(C)$ ត្រង់ $+\infty$ ។ សិក្សាទីតាំងនៃ $(C)$ ធៀបបន្ទាត់ $(D_1)$ និងទីតាំងនៃ $(C)$ ធៀបបន្ទាត់ $(D_2)$ ។

ⓔ សង់ក្រាប $(C)$ អាស៊ីមតូត $(D_1)$ និង $(D_2)$ ។ (គេឲ្យតម្លៃ $\frac{2}{9}\ln 2 \approx 0.15$ និង $\ln 2 \approx 0.7$)

**2** (ឧបឆ្នាំ ២០២៥ ថ្នាក់វិទ្យាសាស្ត្រ)

គេមានអនុគមន៍ $g$ ដែល $g(x) = \ln\left(\frac{-x-3}{x-3}\right)$

ⓐ រកដែនកំណត់នៃអនុគមន៍ $g$ និងសិក្សាថាតើ $g$ ជាអនុគមន៍គូ ឬអនុគមន៍សេស ?
($g$ អនុគមន៍គូលុះត្រាតែ $g(-x) = g(x)$ និង $g$ ជាអនុគមន៍សេសលុះត្រាតែ $g(-x) = -g(x)$) ។

ⓑ គណនាលីមីតនៃអនុគមន៍ $g$ ត្រង់ $-3$ និងត្រង់ $+3$ ។ សិក្សាអថេរភាពនៃ $g$ លើដែនកំណត់របស់វា។ សង់តារាងអថេរភាពរបស់វា។

ⓒ $(O, \vec{i}, \vec{j})$ ជាតម្រុយអរតូណរម៉ាល់ ។ តាង $C$ ក្រាបនៃអនុគមន៍ $g$ ក្នុងតម្រុយនេះ។ កំណត់សមីការរបស់បន្ទាត់ប៉ះ $T$ ទៅនឹងក្រាប $C$ ត្រង់ចំណុចដែលមានអាប់ស៊ីស $0$ ។ សង់ក្រាប $C$ និងបន្ទាត់ប៉ះ $T$ ។ សិក្សាសញ្ញានៃ $g(x)$ ទៅតាមតម្លៃនៃ $x$ ។

ⓓ i គណនាដេរីវេនៃអនុគមន៍ $h$ ដែល $h(x) = xg(x)$ ។

ii រកផ្ទៃក្រឡានៃផ្នែកប្លង់នៅចន្លោះក្រាប $C$ អ័ក្សអាប់ស៊ីស និងបន្ទាត់ដែលមានសមីការ $x = 0$ និង $x = 1$ ។

**3** (ឧបឆ្នាំ ២០២៤ ថ្នាក់វិទ្យាសាស្ត្រ)

គេមានអនុគមន៍ $f$ កំណត់លើ $(1, +\infty)$ ដោយ $f(x) = \ln(x+1) - \ln(x-1) - x + 2$ ។ គេតាង $(C)$ ក្រាបរបស់វានៅក្នុងប្លង់ប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $(O, \vec{i}, \vec{j})$ ។

ⓐ បង្ហាញថា $f(x) = 2 - x + \ln\left(\frac{x+1}{x-1}\right)$ ។ គណនាលីមីតនៃ $f(x)$ ត្រង់ $1$ និងត្រង់ $+\infty$ ។

ⓑ បង្ហាញថានៅលើ $(1, +\infty)$ ដេរីវេនៃអនុគមន៍ $f$ គឺ $f'(x) = \frac{-(x^2+1)}{(x+1)(x-1)}$ ។ សិក្សាអថេរភាពនិងសង់តារាងអថេរភាពនៃ $f$ ។

ⓒ បង្ហាញថាបន្ទាត់ $(d)$ មានសមីការ $y = -x + 2$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ។

ⓓ ប្រៀបធៀបទីតាំងនៃ $(C)$ ធៀបនឹង $(d)$ ។ សង់ក្រាប $(C)$ និងបន្ទាត់ $(d)$ ។ (ប្រើតម្លៃ $\ln 3 \approx 1.1$) ។

**4** (ឧបឆ្នាំ ២០២៣ ថ្នាក់វិទ្យាសាស្ត្រ)

គេមានអនុគមន៍ $f$ កំណត់លើ $\mathbb{R}$ ដោយ $f(x) = 4 - x - 2e^{-x}$ ។ គេតាង $(C)$ ក្រាបរបស់ $f$ ។

ⓐ i ផ្ទៀងផ្ទាត់ថាគ្រប់ចំនួនពិត $x$, $f(x) = \frac{4e^x - xe^x - 2}{e^x}$ ។ គណនា $\lim\limits_{x\to+\infty} f(x)$, $\lim\limits_{x\to-\infty} f(x)$

($\lim\limits_{x\to-\infty} xe^x = 0$) ។

ii បង្ហាញថាបន្ទាត់ $(D)$ ដែលមានសមីការ $y=-x+4$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ។

iii សិក្សាទីតាំងនៃ $(C)$ ធៀបនឹង $(D)$ ។

b i គណនា $f'(x)$ ដែល $f'(x)$ ជាដេរីវេនៃ $f(x)$ ។ សិក្សាអថេរភាពនៃ $f$ និងគណនាតម្លៃអតិបរមារបស់ $f$ ។

ii $A$ ជាចំណុចនៃ $(C)$ ដែលមានអាប់ស៊ីស 0 ។ រកសមីការបន្ទាត់ប៉ះ $(T)$ ទៅនឹងក្រាប $(C)$ ត្រង់ចំណុច $A$ ។

iii បង្ហាញថាសមីការ $f(x)=0$ មានចម្លើយតែមួយគត់ $\beta$ នៅក្នុងចន្លោះ $[-1,0]$ ។

iv សង់បន្ទាត់ប៉ះ $(T)$ អាស៊ីមតូត $(D)$ និងក្រាប $(C)$ ។

**5** (ឧបឆ្នាំ ២០២២ ថ្នាក់វិទ្យាសាស្ត្រ)

a គេមានអនុគមន៍ $f$ កំណត់ដោយ $f(x)=x-\ln(1+x)$ ។ យើងតាងដោយ $(C)$ ក្រាបរបស់ $f$ ។

i រកដែនកំណត់ $D$ នៃអនុគមន៍ $f$ ។ គណនា $\lim\limits_{x\to-1^+} f(x)$ និង $\lim\limits_{x\to+\infty} f(x)$ ។

ii សិក្សាអថេរភាពរបស់អនុគមន៍ $f(x)$ ដោយភ្ជាប់តារាងអថេរភាពនៅលើ $D$ និងបញ្ជាក់សញ្ញានៃ $f(x)$ លើ $D$ ។

b គេចង់សិក្សាទីតាំងរបស់ក្រាប $(C)$ នៃ $f$ ធៀបទៅនឹងក្រាប $(P)$ ដែលមានសមីការ $y=\frac{1}{2}x^2$ ។

i ក្នុងន័យនេះ គេបង្កើតអនុគមន៍ $g$ កំណត់លើ $D$ ដែនកំណត់របស់ $f$ ដោយ $g(x)=f(x)-\frac{1}{2}x^2$ ។ សិក្សាអថេរភាពនៃអនុគមន៍ $g$ និងទាញយកសញ្ញានៃ $g(x)$ កាលណា $x$ រត់នៅលើ $D$ ។ សិក្សាទីតាំងនៃក្រាប $(C)$ ធៀបនឹងក្រាប $(P)$ ។

ii សង់ក្រាប $(C)$ និងក្រាប $(P)$ ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

**6** (ឧបឆ្នាំ ២០២១ ថ្នាក់វិទ្យាសាស្ត្រ)

គេមានអនុគមន៍ $f$ ដែល $f(x)=x-2+\frac{2(x+1)}{e^x}$ ។ យើងតាង $(C)$ ក្រាបរបស់អនុគមន៍ $f$ នៅក្នុងប្លង់ប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

a រកដែនកំណត់នៃអនុគមន៍ $f$ ។ គណនា $\lim\limits_{x\to+\infty} f(x)$ និង $\lim\limits_{x\to-\infty} f(x)$ (យើងដឹងថា $\lim\limits_{x\to+\infty}\frac{x}{e^x}=0$) ។

b បង្ហាញថាបន្ទាត់ $(D)$ ដែលមានសមីការ $y=x-2$ ជាអាស៊ីមតូតទ្រេតនៃ $(C)$ ត្រង់ $+\infty$ ។ បញ្ជាក់ទីតាំងនៃក្រាប $(C)$ ធៀបនឹងបន្ទាត់ $(D)$ ។

c យើងតាង $f'(x)$ ដេរីវេនៃ $f(x)$ ។ បង្ហាញថា៖ $f'(x)=\frac{e^x-2x}{e^x}$ ។ គេដឹងថាគ្រប់ $x$ ជាធាតុរបស់ $\mathbb{R}, e^x-2x>0$ ។ ប្រើលទ្ធផលនេះដើម្បីទាញយកការសិក្សាអថេរភាពនៃអនុគមន៍ $f$ ។

d បង្ហាញថាបន្ទាត់ប៉ះ $(\Delta)$ ទៅនឹង $(C)$ ត្រង់ចំណុចដែលមានអាប់ស៊ីស 0 ស្របទៅនឹងបន្ទាត់ $(D)$ ។ សង់បន្ទាត់ $(D),(\Delta)$ និងក្រាប $(C)$ ។

**7** (ឧបឆ្នាំ ២០១៩ ថ្នាក់វិទ្យាសាស្ត្រ)

អនុគមន៍ $f$ កំណត់លើ $(0,+\infty)$ ដោយ $f(x)=\dfrac{x^2-2}{x}-\ln x$ ☐ គេតាង $(C)$ ក្រាបរបស់អនុគមន៍ $f$ នៅក្នុងប្លង់ប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

ⓐ i បង្ហាញថាចំពោះគ្រប់ $x$ លើ $(0,+\infty)$ គេអាចសរសេរ $f(x)=x\left(1-\dfrac{\ln x}{x}-\dfrac{2}{x^2}\right)$ និង $f(x)=\dfrac{1}{x}(x^2-x\ln x-2)$ ។

ii ប្រើលទ្ធផលនេះដើម្បីគណនាលីមីតនៃអនុគមន៍ $f$ ត្រង់ 0 និងត្រង់ $+\infty$ ។

ⓑ i គណនាដេរីវេ $f'(x)$ នៃអនុគមន៍ $f(x)$ និងបង្ហាញថាចំពោះគ្រប់ $x$ លើ $(0,+\infty)$, $f'(x)$ មានសញ្ញាដូច $(x^2-x+2)$ ។

ii សិក្សាអថេរភាពនៃអនុគមន៍ $f$ រួចសង់តារាងអថេរភាពរបស់វា ។

ⓒ i រកសមីការបន្ទាត់ប៉ះទៅក្រាប $(C)$ ត្រង់ចំណុច $A$ នៅលើ $(C)$ ដែលមានអាប់ស៊ីសស្មើ 1 ។

ii រកកូអរដោនេចំណុច $B$ នៃ $(C)$ ដែលបន្ទាត់ប៉ះទៅ $(C)$ ត្រង់ $B$ ស្របនឹងបន្ទាត់ដែលមានសមីការ $y=x$ ។

ⓓ សង់ក្រាប $(C)$ និងបន្ទាត់ប៉ះត្រង់ $A$ និងត្រង់ $B$ ។ (គេឲ្យតម្លៃ $\ln 2\approx 0.7$) ។

**8** (ឧបឆ្នាំ ២០១៨ ថ្នាក់វិទ្យាសាស្ត្រ)

គេមានអនុគមន៍ $f$ កំណត់លើ $(1,+\infty)$ ដោយ $f(x)=-x+4+\ln\left(\dfrac{x+1}{x-1}\right)$ ។ គេតាងដោយ $(C)$ ក្រាបរបស់វា នៅក្នុងប្លង់ប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

ⓐ គណនាលីមីតនៃ $f$ ត្រង់ 1 និង $+\infty$ ។

ⓑ ស្រាយបំភ្លឺថានៅលើ $(1,+\infty)$ គេបានដេរីវេនៃអនុគមន៍ $f$ គឺ $f'(x)=\dfrac{-(x^2+1)}{(x+1)(x-1)}$ ។ សិក្សាអថេរភាពនៃអនុគមន៍ $f$ និងសង់តារាងអថេរភាពនៃ $f$ លើ $(1,+\infty)$ ។

ⓒ i បង្ហាញបន្ទាត់ $d_1$ ដែលមានសមីការ $y=-x+4$ អាស៊ីមតូតទៅនឹងក្រាប $(C)$ ត្រង់ $+\infty$ ។

ii បង្ហាញថាចំពោះគ្រប់ $x$ លើ $(1,+\infty)$ $\dfrac{x+1}{x-1}>1$ និងទាញយកការប្រៀបធៀបទីតាំងនៃ $(C)$ ធៀបនឹង $d_1$ ។

ⓓ កំណត់កូអរដោនេនៃចំណុចនៅលើ $(C)$ ដែលបន្ទាត់ប៉ះ $d_2$ ទៅនឹងក្រាប $(C)$ ត្រង់ចំណុចនេះមានមេគុណប្រាប់ទិសស្មើ $-\dfrac{5}{3}$ និងសរសេរសមីការនៃបន្ទាត់ប៉ះ $d_2$ នេះ ។

ⓔ សង់ក្រាប $(C)$ អាស៊ីមតូត $d_1$ និងបន្ទាត់ប៉ះ $d_2$ ។ ប្រើតម្លៃប្រហែល $\ln 3=1.1$ និងក្រាប $(C)$ កាត់អ័ក្សអាប់ស៊ីសត្រង់ចំណុច $(4.5,0)$ ។

**9** (ឧបឆ្នាំ ២០១៧ ថ្នាក់វិទ្យាសាស្ត្រ)

គេមានអនុគមន៍ $f$ កំណត់លើ $\mathbb{R}$ ដោយ $f(x)=x+\dfrac{1-3e^x}{1+e^x}$ ។ គេតាងដោយ $(C)$ ក្រាបរបស់វា នៅក្នុងប្លង់ប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

ⓐ បង្ហាញថា $f(x)=x+1-\dfrac{4e^x}{1+e^x}$ និងគណនាលីមីតនៃ $f$ ត្រង់ $-\infty$ ។ ស្រាយបំភ្លឺថាបន្ទាត់ $d_1$ ដែលមានសមីការ $y=x+1$ អាស៊ីមតូតទៅនឹងក្រាប $(C)$ ត្រង់ $-\infty$ ។ សិក្សាទីតាំងនៃក្រាប $(C)$ ធៀបនឹងបន្ទាត់ $d_1$ ។

(b) គណនាលីមីត $f$ ត្រង់ $+\infty$ ។ ស្រាយបំភ្លឺថាបន្ទាត់ $d_2$ ដែលមានសមីការ $y=x-3$ អាស៊ីមតូតទៅនឹងក្រាប $(C)$ ត្រង់ $+\infty$ ។ សិក្សាទីតាំងនៃក្រាប $(C)$ ធៀបនឹងបន្ទាត់ $d_2$ ។

(c) i គណនាដេរីវេ $f'(x)$ និងបង្ហាញថាគ្រប់ចំនួនពិត $x$, $f'(x)=\left(\dfrac{e^x-1}{e^x+1}\right)^2$ ។

ii សិក្សាអថេរភាពនៃ $f$ រួចសង់តារាងអថេរភាពនៃ $f$ ។ សង់ក្រាប $(C)$ និងអាស៊ីមតូត $d_1$ និង $d_2$ របស់វា ។

**10** (ឧបឆ្នាំ ២០១៦ ថ្នាក់វិទ្យាសាស្ត្រ)

គេឲ្យអនុគមន៍ $f$ កំណត់លើ $\mathbb{R}$ ដោយ $f(x)=x+2-\dfrac{4e^x}{e^x+3}$ ។ គេតាង $(C)$ ក្រាបរបស់វានៅក្នុងប្លង់ប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

(a) i គណនាលីមីតនៃ $f$ ត្រង់ $-\infty$ និង $+\infty$ ។

ii សិក្សាទីតាំងនៃក្រាប $C$ ធៀបនឹងបន្ទាត់ $d_1$ ដែលមានសមីការ $y=x+2$ ។

(b) i ស្រាយបញ្ជាក់ថាចំពោះគ្រប់ចំនួនពិត $x$, $f'(x)=\left(\dfrac{e^x-3}{e^x+3}\right)^2$ ។

ii សិក្សាអថេរភាពនៃ $f$ លើ $\mathbb{R}$ និងសង់តារាងអថេរភាពនៃ $f$ ។

(c) i តើគេអាចថាយ៉ាងណាចំពោះបន្ទាត់ប៉ះ $d_2$ ទៅនឹងក្រាប $C$ ត្រង់ចំណុច $I$ ដែលមានអាប់ស៊ីស $\ln(3)$ ?

ii សិក្សាទីតាំងនៃក្រាប $C$ ធៀបនឹងបន្ទាត់ $d_2$ ។

(d) i បង្ហាញថាបន្ទាត់ប៉ះ $d_3$ ទៅនឹងក្រាប $C$ ត្រង់ចំណុចដែលមានអាប់ស៊ីសសូន្យមានសមីការ $y=\dfrac{1}{4}x+1$ ។

ii ដោយសន្មតថាចំណុច $I$ ជាផ្ចិតស្នុះនៃក្រាប $(C)$ និងក្នុងតម្លៃប្រហែលនៃ $\ln(3)$ ចូរសង់ក្រាប $C$ និងបន្ទាត់ប៉ះ $d_1,d_2,d_3$ ។ (នៅលើតម្រុយនេះមួយឯកតាស្មើ 2cm) ។

**11** (ឧបឆ្នាំ ២០១៥ ថ្នាក់វិទ្យាសាស្ត្រ)

(a) គេឲ្យអនុគមន៍ $g$ កំណត់លើ $(0,+\infty)$ ដោយ $g(x)=x^2+\ln x$ ។

i a បង្ហាញថា $g$ ជាអនុគមន៍កើនដាច់ខាតលើ $(0,+\infty)$ ។

b គណនា $g(1)$ ។

ii a ទាញយកពីលទ្ធផលនៃសំណួរទី១ បញ្ជាក់លទ្ធផលខាងក្រោម៖
បើ $x\geq 1$ នោះ៖ $x^2+\ln x\geq 1$ និង បើ $0<x\leq 1$ នោះ៖ $x^2+\ln x\leq 1$ ។

b កំណត់សញ្ញានៃកន្សោម $x^2+\ln x-1$ តាលណា $x$ នៅលើ $(0,+\infty)$ ។

(b) គេមានអនុគមន៍ $f$ កំណត់លើ $(0,+\infty)$ ដោយ $f(x)=x+1-\dfrac{\ln x}{x}$ និងតាងដោយ $C$ ក្រាបរបស់វាក្នុងតម្រុយអរតូណរមេ $(O,\vec{i},\vec{j})$ ។

i សិក្សាលីមីតនៃអនុគមន៍ $f$ ត្រង់ 0 និង $+\infty$ (យើងដឹងថា $\lim\limits_{x\to+\infty}\dfrac{\ln x}{x}=0$) ។

ii បង្ហាញថាដេរីវេនៃអនុគមន៍ $f$ គឺ $f'(x)=\dfrac{x^2+\ln x-1}{x^2}$ ។

iii ប្រើលទ្ធផលនៃសំណួរ A. សិក្សាសញ្ញានៃ $f'(x)$ និងសង់តារាងអថេរភាពនៃអនុគមន៍ $f$ លើ $(0,+\infty)$ ។

iv a បង្ហាញថាបន្ទាត់ $\Delta$ មានសមីការ $y=x+1$ អាស៊ីមតូតទៅនឹងក្រាប $C$ ត្រង់ $+\infty$ ។

b សិក្សាទីតាំង $C$ ធៀបនឹង $\Delta$ និងបញ្ជាក់កូអរដោនេនៃចំណុចប្រសព្វ $I$ រវាងក្រាប $C$ និង $\Delta$ ។ សង់ $\Delta$ និងក្រាប $C$ ។

**12** (ឧបត្ថម្ភ ២០១៤ ថ្នាក់វិទ្យាសាស្ត្រ លើកទី២)

គេមានអនុគមន៍ $f$ កំណត់លើ $I=]0,+\infty[$ ដោយ $f(x)=\dfrac{x+\ln x}{x^2}$ ។

a $h$ ជាអនុគមន៍កំណត់លើ $I$ ដោយ $h(x)=-x+1-2\ln x$ ។ គណនា $h(1)$ និងសិក្សាអថេរភាពនៃ $h(x)$ ដោយគេមិនតម្រូវឲ្យគណនាលីមីតនៃ $h(x)$ ត្រង់ 0 និងត្រង់ $+\infty$ ឡើយ។

b i គណនាលីមីតនៃ $f(x)$ ត្រង់ 0 និងត្រង់ $+\infty$ ។

ii គណនាដេរីវេ $f'(x)$ នៃអនុគមន៍ $f(x)$ ។

iii បង្ហាញថានៅលើ $I$, $f'(x)$ មានសញ្ញាដូច $h(x)$ ។

iv ទាញយកអថេរភាពនៃ $f(x)$ លើ $I$ និងសង់ក្រាប $C$ នៃ $f(x)$ នៅលើប្លង់ប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

**13** (ឧបត្ថម្ភ ២០១៤ ថ្នាក់វិទ្យាសាស្ត្រ លើកទី១)

$f$ ជាអនុគមន៍កំណត់លើ $]0,+\infty[$ ដោយ $f(x)=x-5+\dfrac{8\ln x}{x}+\dfrac{9}{x}$ និង $C$ ជាក្រាបរបស់វា។

a i រក $\lim\limits_{x\to+\infty} f(x)$ ។

ii $\lim\limits_{x\to0} f(x)$ ។

iii ស្រាយបំភ្លឺថាបន្ទាត់ $\Delta$ ដែលមានសមីការ $y=x-5$ ជាអាស៊ីមតូតនៃខ្សែកោង $C$ នៅជិត $+\infty$ ។

iv កំណត់អាប់ស៊ីសនៃចំណុចប្រសព្វរវាង $\Delta$ និងខ្សែកោង $C$ ។

b i បង្ហាញថាចំពោះគ្រប់ $x$ លើ $]0,+\infty[$ គេបាន $f'(x)=\dfrac{g(x)}{x^2}$ ។

ii សិក្សាអថេរភាពនៃអនុគមន៍ $f$ ដោយដឹងថាសមីការ $g(x)=0$ មានចម្លើយ $x'=1$ និង $x''=\alpha,(1<\alpha)$ ។

**14** (ឧបត្ថម្ភ ២០១៤ ថ្នាក់វិទ្យាសាស្ត្រ លើកទី១)

$f$ ជាអនុគមន៍កំណត់លើ $\mathbb{R}$ ដោយ $f(x)=4-x-2e^{-x}$ ។ គេតាងដោយ $C$ ជាក្រាបរបស់វា ។

a i រក $\lim\limits_{x\to+\infty} f(x)$ ។

ii បង្ហាញថាបន្ទាត់ $D$ មានសមីការ $y=-x+4$ ជាអាស៊ីមតូតនៃខ្សែកោង $C$ ។

iii តើខ្សែកោង $C$ នៅលើ ឬនៅក្រោមបន្ទាត់ $D$ ចូរបញ្ជាក់។

iv ផ្ទៀងផ្ទាត់ថាគ្រប់ចំនួនពិត $x$, $f(x)=\dfrac{4e^x-xe^x-2}{e^x}$ ។

v រក $\lim\limits_{x\to-\infty} f(x)$, (ប្រើលទ្ធផល $\lim\limits_{x\to-\infty} xe^x=0$) ។

(b) (i) គណនា $f'(x)$ ។ សិក្សាអថេរភាពនៃ $f$ ។ កំណត់តម្លៃពិតនៃអតិបរមារបស់ $f$ ។

(ii) $A$ ជាចំណុចមួយលើខ្សែកោង $C$ ដែលមានអាប់ស៊ីស 0 ។ កំណត់សមីការបន្ទាត់ប៉ះខ្សែកោង $C$ ត្រង់ $A$ ។

(iii) បង្ហាញថាសមីការ $f(x) = 0$ មានចម្លើយតែមួយគត់ដែលគេតាងដោយ $\beta$ នៅក្នុងចន្លោះ $[-1,0]$ ។

**15** (បាក់ឌុបឆ្នាំ ២០១៦ ថ្នាក់សង្គម)

គេមានអនុគមន៍ $f$ ដែល $f(x) = \dfrac{x^2-4}{1-x}$ និង $(C)$ ជាក្រាបរបស់វា ។

(a) រកដែនកំណត់នៃអនុគមន៍ $f$ ។

(b) (i) រកចំនួនពិត $a, b, c$ ដែលគ្រប់ $x \neq 1, f(x) = ax + b + \dfrac{c}{x-1}$ ។

(ii) បង្ហាញថាបន្ទាត់ $(D)$ មានសមីការ $y = -x - 1$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ត្រង់ $+\infty$ និង $-\infty$ ។

បង្ហាញថាបន្ទាត់ដែលមានសមីការ $x = 1$ ជាអាស៊ីមតូតឈរនៃក្រាប $(C)$ ។

(c) សិក្សាអថេរភាពនៃអនុគមន៍ $f$ និងសង់ក្រាប $(C)$ រួចអាស៊ីមតូតទ្រេត និងឈររបស់ $(C)$ ។

**16** (បាក់ឌុបឆ្នាំ ២០២៥ ថ្នាក់សង្គម)

គេមានអនុគមន៍ $f$ ដែល $f(x) = \dfrac{2-x-2x^2}{-1-x}$ ។

(a) រកដែនកំណត់នៃអនុគមន៍ $f$ ។

(b) កំណត់ចំនួនពិត $a, b, c$ ដែល $f(x) = ax + b + \dfrac{c}{x+1}$ ។

(c) បង្ហាញថាបន្ទាត់ $d$ ដែលមានសមីការ $y = 2x - 1$ ជាអាស៊ីមតូតនៃក្រាប $C$ របស់អនុគមន៍ $f$ ត្រង់ $+\infty$ និង $-\infty$ ។

(d) សិក្សាទីតាំងនៃ $d$ ធៀបនឹងក្រាប $C$ ។

(e) សិក្សាអថេរភាពនៃអនុគមន៍ $f$ ។ សង់ក្រាប $C$ និងបន្ទាត់ $d$ ។

**17** (បាក់ឌុបឆ្នាំ ២០២៤ ថ្នាក់សង្គម)

គេមានអនុគមន៍ $f$ កំណត់ដោយ $f(x) = \dfrac{-x^2+x+3}{x+1}$ ។ យើងតាងក្រាប $(C)$ តំណាង $f$ ក្នុងតម្រុយ $(O, \vec{i}, \vec{j})$ ។

(a) រកដែនកំណត់នៃអនុគមន៍ $f$ ។

(b) បង្ហាញថា $f(x) = -x + 2 + \dfrac{1}{x+1}$ ។

(c) គណនា $\lim\limits_{x\to-\infty} f(x)$, $\lim\limits_{x\to+\infty} f(x)$, $\lim\limits_{x\to-1^-} f(x)$, $\lim\limits_{x\to-1^+} f(x)$ ។

(d) រកសមីការអាស៊ីមតូតឈរ និងអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ។

(e) សិក្សាអថេរភាព និងសង់ក្រាប $(C)$ នៃអនុគមន៍ $f$ ។

**18** (បាក់ឌុបឆ្នាំ ២០២៣ ថ្នាក់សង្គម)

គេមានអនុគមន៍ $f$ កំណត់ដោយ $f(x) = \dfrac{3x-1}{(x-1)^2}$ និងតាង $(C)$ ក្រាបរបស់អនុគមន៍ ។

(a) រកដែនកំណត់នៃអនុគមន៍ $f$ ។

(b) គណនា $\lim\limits_{x\to 1} f(x)$, $\lim\limits_{x\to -\infty} f(x)$, $\lim\limits_{x\to +\infty} f(x)$ ។ រកសមីការអាស៊ីមតូតឈរ និងអាស៊ីមតូតដេកនៃក្រាប $(C)$ ។

(c) បង្ហាញថាដេរីវេនៃ $f$ គឺ $f'(x)=\dfrac{-3x-1}{(x-1)^3}$ ។

(d) សិក្សាអថេរភាព និងសង់ក្រាបនៃ $f(x)$ ។

**19** (បាក់ឌុបឆ្នាំ ២០២២ ថ្នាក់សង្គម)

គេមានអនុគមន៍ $f$ កំណត់ដោយ $f(x)=\dfrac{4-x^2}{1-x}$ និងគេតាង $(C)$ ក្រាបរបស់អនុគមន៍ $f$ ។

(a) រកដែនកំណត់នៃអនុគមន៍ $f$ ។

(b) បង្ហាញថា $f(x)=x+1+\dfrac{3}{1-x}$ ។

(c) គណនា $\lim\limits_{x\to 1^+} f(x)$, $\lim\limits_{x\to 1^-} f(x)$, $\lim\limits_{x\to +\infty} f(x)$, $\lim\limits_{x\to -\infty} f(x)$ ហើយទាញយកសមីការអាស៊ីមតូតឈរ និងអាស៊ីមតូតទ្រេតរបស់ក្រាប $(C)$ ។

(d) សិក្សាអថេរភាព និងសង់ក្រាប $(C)$ នៃអនុគមន៍ $f$ ។

**20** (បាក់ឌុបឆ្នាំ ២០២១ ថ្នាក់សង្គម)

គេមានអនុគមន៍ $f$ កំណត់ដោយ $f(x)=\dfrac{x^2-5x+7}{2-x}$ ។ យើងតាង $(C)$ ក្រាបរបស់អនុគមន៍ ក្នុងប្លង់ប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

(a) រកដែនកំណត់នៃអនុគមន៍ $f$ ។

(b) បង្ហាញថា $f(x)=3-x+\dfrac{1}{2-x}$ ។

(c) គណនាលីមីតនៃ $f(x)$ ត្រង់ $-\infty, +\infty$ និង $2$ ។

(d) ចូរកសមីការអាស៊ីមតូតឈរ និងអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ។

(e) សិក្សាអថេរភាពនៃអនុគមន៍ $f$ និងសង់ក្រាប $(C)$ នៃអនុគមន៍ $f$ ។

**21** (បាក់ឌុបឆ្នាំ ២០១៩ ថ្នាក់សង្គម)

គេមានអនុគមន៍ $f$ កំណត់លើ $D=\mathbb{R}-\{-1\}$ ដោយ $f(x)=\dfrac{x^2+2x-2}{x+1}$ ។ យើងតាង $(C)$ ក្រាបរបស់អនុគមន៍នេះ ក្នុងប្លង់ប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

(a) បង្ហាញថា $f(x)=x+1-\dfrac{3}{x+1}$ ។

(b) ចូរកសមីការអាស៊ីមតូតឈរ និងអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ។

(c) សិក្សាអថេរភាព និងសង់ក្រាប $(C)$ នៃអនុគមន៍ $f$ ។

**22** (បាក់ឌុបឆ្នាំ ២០១៨ ថ្នាក់សង្គម)

គេមានអនុគមន៍ $f$ កំណត់ដោយ $f(x)=\dfrac{2x^2-7x+5}{x^2-5x+7}$ ។ យើងតាងដោយ $(C)$ ក្រាបរបស់វានៅលើតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

(a) រកដែនកំណត់ $D$ នៃអនុគមន៍ $f$ ។

(b) សិក្សាលីមីតនៃអនុគមន៍ $f(x)$ ត្រង់ $-\infty$ និងត្រង់ $+\infty$ ។ ទាញយកសមីការអាស៊ីមតូត $d$ ទៅនឹងក្រាប $(C)$ ត្រង់ $-\infty$ និងត្រង់ $+\infty$ ។

(c) (i) ស្រាយបំភ្លឺថាគ្រប់ចំនួនពិត $x \in D$, ដេរីវេ $f'(x) = \dfrac{-3(x^2-6x+8)}{(x^2-5x+7)^2}$ ។

(ii) សិក្សាអថេរភាពនៃអនុគមន៍ $f$ និងសង់តារាងអថេរភាពនៃអនុគមន៍ $f$ ។

(iii) សង់ក្រាប $(C)$ នៃអនុគមន៍ $f$ ។

**23** (បាក់ឌុបឆ្នាំ ២០១៧ ថ្នាក់សង្គម)

គេមានអនុគមន៍ $f$ កំណត់លើ $\mathbb{R}-\{2\}$ ដោយ $f(x) = \dfrac{x^2-x-1}{x-2}$ ។ យើងតាង $C$ ក្រាបរបស់វានៅលើតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

(a) សិក្សាលីមីតនៃអនុគមន៍ $f$ ត្រង់ $-\infty$ ត្រង់ 2 និងត្រង់ $+\infty$ ។

(b) សិក្សាអថេរភាពនិងសង់តារាងអថេរភាពនៃអនុគមន៍ $f$ ។

(c) (i) រកចំនួនពិត $a,b,c$ ដែលគ្រប់ $x \neq 2, f(x) = ax+b+\dfrac{c}{x-2}$ ។

(ii) គេតាង $d$ បន្ទាត់ដែលមានសមីការ $y = x+1$ ។ បង្ហាញថា $d$ អាស៊ីមតូតទៅ $C$ ត្រង់ $+\infty$ និង $-\infty$ ។ សិក្សាទីតាំងនៃក្រាប $C$ ធៀបនឹងបន្ទាត់ $d$ ។

(iii) សង់ក្រាប $C$ និងបន្ទាត់ $d$ ។

**24** (បាក់ឌុបឆ្នាំ ២០១៦ ថ្នាក់សង្គម)

គេមានអនុគមន៍ $f$ កំណត់លើ $\mathbb{R}-\{-2,2\}$ ដោយ $f(x) = \dfrac{2x^2}{x^2-4}$ ។

(a) សិក្សាលីមីតនៃអនុគមន៍ $f$ ត្រង់ $-\infty$ ត្រង់ $-2$ ត្រង់ $+2$ និងត្រង់ $+\infty$ ។ ចូរបញ្ជាក់អំពីអាស៊ីមតូតដេក និងអាស៊ីមតូតឈររបស់ក្រាបនៃអនុគមន៍ $f$ ។

(b) សិក្សាអថេរភាព និងសង់តារាងអថេរភាពនៃអនុគមន៍ $f$ ។

(c) សង់នៅលើតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ក្រាបតាងអនុគមន៍ $f$ ។

**25** (បាក់ឌុបឆ្នាំ ២០១៥ ថ្នាក់សង្គម)

គេមានអនុគមន៍ $f$ ដែល $f(x) = \dfrac{x^2-x-3}{x+1}$ និងគេតាងដោយ $(C)$ ក្រាបនៃអនុគមន៍ $f$ ។

(a) រកដែនកំណត់នៃអនុគមន៍ $f$ ។

(b) បង្ហាញថា $f(x) = x-2-\dfrac{1}{x+1}$ ។

(c) បង្ហាញថាបន្ទាត់ដែលមានសមីការ $y = x-2$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ។

(d) សិក្សាអថេរភាព និងសង់ក្រាបនៃ $f$ ។

**26** (បាក់ឌុបឆ្នាំ ២០១៤ ថ្នាក់សង្គម លើកទី២)

គេមានអនុគមន៍ $f(x) = \dfrac{(x+2)(x-2)}{1-x}$ ។

(a) រកដែនកំណត់នៃ $f(x)$ ។

(b) បង្ហាញថា $f(x) = -x-1+\dfrac{3}{x-1}$ ។

(c) សិក្សាអថេរភាព និងសង់ក្រាប $(C)$ នៃអនុគមន៍ $f(x) = \dfrac{(x+2)(x-2)}{1-x}$ ។

**27** (បាក់ឌុបឆ្នាំ ២០១៤ ថ្នាក់សង្គម លើកទី១)

គេមានអនុគមន៍ $f$ កំណត់លើ $\mathbb{R}$ ដោយ $f(x)=\dfrac{1}{1+e^x}+\dfrac{2}{9}x$ និងតាង $C$ តាងក្រាបរបស់ $f$ ។

ⓐ អនុគមន៍ $g$ កំណត់លើ $\mathbb{R}$ ដោយ $g(x)=2e^{2x}-5e^x+2$ ៖

i ផ្ទៀងផ្ទាត់ថា $g(x)=(2e^x-1)(e^x-2)$ ។

ii ទាញយកតាមតម្លៃនៃ $x$ សញ្ញានៃ $g(x)$ ។

ⓑ i រក $\lim\limits_{x\to+\infty}f(x)$ និង $\lim\limits_{x\to-\infty}f(x)$ ។

ii អនុគមន៍ $f$ មានដេរីវេ $f'$ ។ បង្ហាញថាចំពោះគ្រប់ចំនួនពិត $x$ គេបាន $f'(x)$ និង $g(x)$ មានសញ្ញាដូចគ្នា ។

iii សិក្សាអថេរភាពនៃអនុគមន៍ $f$ លើ $\mathbb{R}$ ។

## ចម្លើយលំហាត់បាក់ឌុប

**1** (ឆ្នាំ ២០២៦ ថ្នាក់វិទ្យាសាស្ត្រ)

ⓐ ផ្ទៀងផ្ទាត់ $g(x)$ និងសិក្សាសញ្ញានៃ $g(x)$ ៖

- ផ្ទៀងផ្ទាត់ ៖

$$\begin{aligned}(e^x-2)(2e^x-1)&=2e^{2x}-e^x-4e^x+2\\&=2e^{2x}-5e^x+2=g(x)\quad\text{(ពិត)}\end{aligned}$$

- សិក្សាសញ្ញានៃ $g(x)$ លើ $\mathbb{R}$ ៖

ឱ្យ $g(x)=0\iff(e^x-2)(2e^x-1)=0$

· $e^x-2=0\iff e^x=2\iff x=\ln 2$

· $2e^x-1=0\iff e^x=\dfrac{1}{2}\iff x=-\ln 2$

សន្និដ្ឋានសញ្ញានៃ $g(x)$ ៖

· ចំពោះ $x\in]-\infty,-\ln 2[\cup]\ln 2,+\infty[$ ៖ $g(x)>0$

· ចំពោះ $x\in]-\ln 2,\ln 2[$ ៖ $g(x)<0$

· ចំពោះ $x=-\ln 2$ ឬ $x=\ln 2$ ៖ $g(x)=0$

ⓑ រកលីមីត និងដេរីវេ $f'(x)$ ៖

- លីមីត ៖

· $\lim\limits_{x\to-\infty}f(x)=\lim\limits_{x\to-\infty}\left(\dfrac{1}{1+e^x}+\dfrac{2x+18}{9}\right)=1+(-\infty)=-\infty$

· $\lim\limits_{x\to+\infty}f(x)=\lim\limits_{x\to+\infty}\left(\dfrac{1}{1+e^x}+\dfrac{2x+18}{9}\right)=0+(+\infty)=+\infty$

- ដេរីវេ $f'(x)$ ៖

$$f'(x) = -\frac{e^x}{(1+e^x)^2} + \frac{2}{9} = \frac{-9e^x + 2(1+2e^x+e^{2x})}{9(1+e^x)^2} = \frac{2e^{2x} - 5e^x + 2}{9(1+e^x)^2} = \frac{g(x)}{9(1+e^x)^2}$$

ដោយសារ $9(1+e^x)^2 > 0$ គ្រប់ $x \in \mathbb{R}$ នាំឲ្យ $f'(x)$ មានសញ្ញាដូច $g(x)$ គ្រប់ $x \in \mathbb{R}$ ៕

ⓒ សិក្សាអថេរភាព និងបង្ហាញថា $f(x) > 0$ លើ $[-\ln 2, \ln 2]$ ៖

- ទិសដៅអថេរភាព ៖
  - $f'(x) > 0$ ចំពោះ $x \in ]-\infty, -\ln 2[ \cup ]\ln 2, +\infty[ \implies f$ ជាអនុគមន៍កើន
  - $f'(x) < 0$ ចំពោះ $x \in ]-\ln 2, \ln 2[ \implies f$ ជាអនុគមន៍ចុះ
- តម្លៃបរមា ៖
  - អតិបរមាធៀបត្រង់ $x = -\ln 2$ គឺ $f(-\ln 2) = \dfrac{24 - 2\ln 2}{9} \approx 2.51$
  - អប្បបរមាធៀបត្រង់ $x = \ln 2$ គឺ $f(\ln 2) = \dfrac{21 + 2\ln 2}{9} \approx 2.49$
- តារាងអថេរភាព ៖

| $x$ | $-\infty$ | | $-\ln 2$ | | $\ln 2$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | ↗ | $\dfrac{24-2\ln 2}{9}$ | ↘ | $\dfrac{21+2\ln 2}{9}$ | ↗ | $+\infty$ |

- បង្ហាញថា $f(x) > 0$ លើ $[-\ln 2, \ln 2]$ ៖
  លើចន្លោះ $[-\ln 2, \ln 2]$, $f(x)$ ជាអនុគមន៍ចុះ ដូច្នេះតម្លៃតូចបំផុតរបស់វាគឺអប្បបរមាធៀប $f(\ln 2)$ ៖

$$f(x) \geq f(\ln 2) = \frac{21 + 2\ln 2}{9} > 0 \quad (\text{ព្រោះ } 21 + 2\ln 2 > 0)$$

ដូចនេះ $f(x) > 0$ គ្រប់ $x \in [-\ln 2, \ln 2]$ ៕

ⓓ អាស៊ីមតូត និងទីតាំងធៀប ៖

- អាស៊ីមតូតទ្រេត $(D_1)$ ត្រង់ $-\infty$ ៖

$$\lim_{x\to-\infty}[f(x) - y_{D_1}] = \lim_{x\to-\infty}\left(\frac{1}{1+e^x} + \frac{2x+18}{9} - \left(\frac{2}{9}x + 3\right)\right) = \lim_{x\to-\infty}\frac{-e^x}{1+e^x} = 0$$

នាំឲ្យបន្ទាត់ $(D_1) : y = \dfrac{2}{9}x + 3$ ជាអាស៊ីមតូតទ្រេតនៃ $(C)$ ត្រង់ $-\infty$ ៕

○ អាស៊ីមតូតទ្រេត $(D_2)$ ត្រង់ $+\infty$ ៖

$$\lim_{x\to+\infty}[f(x)-y_{D_2}]=\lim_{x\to+\infty}\left(\frac{1}{1+e^x}+\frac{2x+18}{9}-\left(\frac{2}{9}x+2\right)\right)=\lim_{x\to+\infty}\frac{1}{1+e^x}=0$$


នាំឲ្យបន្ទាត់ $(D_2): y=\frac{2}{9}x+2$ ជាអាស៊ីមតូតទ្រេតនៃ $(C)$ ត្រង់ $+\infty$ ។

○ ទីតាំងធៀប ៖

· $f(x)-y_{D_1}=\frac{-e^x}{1+e^x}<0$ គ្រប់ $x\in\mathbb{R}\implies$ ក្រាប $(C)$ នៅខាងក្រោមបន្ទាត់ $(D_1)$

· $f(x)-y_{D_2}=\frac{1}{1+e^x}>0$ គ្រប់ $x\in\mathbb{R}\implies$ ក្រាប $(C)$ នៅខាងលើបន្ទាត់ $(D_2)$

ⓔ សង់ក្រាប $(C)$, $(D_1)$ និង $(D_2)$ ៖




## 2 ( ឧបឆ្នាំ ២០២៥ ថ្នាក់វិទ្យាសាស្ត្រ

គេមានអនុគមន៍ $g$ ដែល $g(x)=\ln\left(\frac{-x-3}{x-3}\right)$

ⓐ រកដែនកំណត់ និងសិក្សាភាពគូ-សេសនៃអនុគមន៍ $g$ ៖

○ ដែនកំណត់ ៖

អនុគមន៍ $g(x)=\ln\left(\frac{-x-3}{x-3}\right)=\ln\left(\frac{x+3}{3-x}\right)$ មានន័យលុះត្រាតែ ៖

$$\frac{x+3}{3-x}>0$$

ឱ្យ $x+3=0\iff x=-3$ និង $3-x=0\iff x=3$ ។

តាមតារាងសញ្ញា យើងបានកន្សោម $\frac{x+3}{3-x}>0$ ចំពោះ $x\in]-3,3[$ ៖

$$D_g=]-3,3[$$

○ សិក្សាភាពគូ-សេស ៖

· គ្រប់ $x \in D_g = ]-3,3[$ នាំឲ្យ $-x \in ]-3,3[ = D_g$ (សំណុំ $D_g$ មានផ្ចិតធៀបនឹង 0)

· គណនា $g(-x)$ ៖

$$g(-x) = \ln\left(\frac{-(-x)-3}{(-x)-3}\right) = \ln\left(\frac{x-3}{-x-3}\right) = \ln\left(\frac{-(3-x)}{-(x+3)}\right) = \ln\left(\frac{3-x}{x+3}\right)$$

ដោយសារ $\ln\left(\frac{3-x}{x+3}\right) = \ln\left(\left(\frac{x+3}{3-x}\right)^{-1}\right) = -\ln\left(\frac{x+3}{3-x}\right) = -g(x)$

ព្រោះ $g(-x) = -g(x)$ ដូចនេះ $g$ ជាអនុគមន៍សេស ។

ⓑ គណនាលីមីត សិក្សាអថេរភាព និងសង់តារាងអថេរភាព ៖

○ លីមីត ៖

· $\lim\limits_{x\to -3^+} g(x) = \lim\limits_{x\to -3^+} \ln\left(\frac{x+3}{3-x}\right) = \ln(0^+) = -\infty$

$\Longrightarrow$ បន្ទាត់ $x = -3$ ជាអាស៊ីមតូតឈរនៃក្រាប $C$ ត្រង់ $-\infty$

· $\lim\limits_{x\to 3^-} g(x) = \lim\limits_{x\to 3^-} \ln\left(\frac{x+3}{3-x}\right) = \ln(+\infty) = +\infty$

$\Longrightarrow$ បន្ទាត់ $x = 3$ ជាអាស៊ីមតូតឈរនៃក្រាប $C$ ត្រង់ $+\infty$

○ ដេរីវេ និងទិសដៅអថេរភាព ៖

សរសេរ $g(x) = \ln(x+3) - \ln(3-x)$ ៖

$$g'(x) = \frac{1}{x+3} - \frac{-1}{3-x} = \frac{1}{x+3} + \frac{1}{3-x} = \frac{3-x+x+3}{(x+3)(3-x)} = \frac{6}{9-x^2}$$

ដោយសារគ្រប់ $x \in ]-3,3[$ នាំឱ្យ $x^2 < 9 \iff 9-x^2 > 0$ ដូច្នេះ $g'(x) > 0$ គ្រប់ $x \in D_g$ ។

នាំឱ្យ $g$ ជាអនុគមន៍កើនដាច់ខាតលើចន្លោះ $]-3,3[$ ។

○ តារាងអថេរភាព ៖

| $x$ | $-3$ | | $3$ |
|---|---|---|---|
| $g'(x)$ | ‖ | $+$ | ‖ |
| $g(x)$ | $-\infty$ ‖ | $-\infty \longrightarrow +\infty$ | ‖ $+\infty$ |

ⓒ សមីការបន្ទាត់ប៉ះ $T$, សង់ក្រាប $C$ និងសិក្សាសញ្ញានៃ $g(x)$ ៖

○ សមីការបន្ទាត់ប៉ះ $T$ ត្រង់ $x = 0$ ៖

· $g(0) = \ln\left(\frac{3}{3}\right) = \ln(1) = 0$

· $g'(0) = \frac{6}{9-0^2} = \frac{6}{9} = \frac{2}{3}$


សមីការបន្ទាត់ប៉ះ $T$ មានទម្រង់ $y = g'(0)(x-0)+g(0) \implies (T): y = \frac{2}{3}x$ ។

- សិក្សាសញ្ញានៃ $g(x)$ ទៅតាមតម្លៃ $x$ ៖

  ដោយសារ $g$ ជាអនុគមន៍កើនដាច់ខាតលើ $]-3,3[$ និង $g(0)=0$ ៖

  - ចំពោះ $x \in ]-3,0[$ ៖ $g(x)<0$
  - ចំពោះ $x=0$ ៖ $g(x)=0$
  - ចំពោះ $x \in ]0,3[$ ៖ $g(x)>0$

- សង់ក្រាប $C$ និងបន្ទាត់ប៉ះ $T$ ៖




(d) គណនាដេរីវេ $h'(x)$ និងផ្ទៃក្រឡា ៖

(i) គណនាដេរីវេនៃអនុគមន៍ $h(x)=xg(x)$ ៖

$$h'(x) = (x)'g(x)+xg'(x) = 1\cdot g(x)+x\cdot\frac{6}{9-x^2} = g(x)+\frac{6x}{9-x^2}$$

(ii) រកផ្ទៃក្រឡានៃផ្នែកប្លង់ ៖

ចំពោះ $x\in[0,1], g(x)\geq 0$ នាំឱ្យផ្ទៃក្រឡា $S$ កំណត់ដោយ ៖

$$S = \int_0^1 g(x)\,dx$$

តាមសំនួរ (i) យើងមាន $g(x) = h'(x) - \frac{6x}{9-x^2}$ ៖

$$\begin{aligned}\int g(x)\,dx &= h(x) - \int \frac{6x}{9-x^2}\,dx \\ &= xg(x)+3\ln(9-x^2) \quad \left(\text{ព្រោះ } \int \frac{-2x}{9-x^2}dx = \ln(9-x^2)\right)\end{aligned}$$

ដូច្នេះ ៖

$$\begin{aligned} S &= \left[xg(x) + 3\ln(9-x^2)\right]_0^1 \\ &= (1\cdot g(1) + 3\ln(8)) - (0\cdot g(0) + 3\ln(9)) \\ &= \ln\left(\frac{4}{2}\right) + 3\ln(2^3) - 3\ln(3^2) \\ &= \ln 2 + 9\ln 2 - 6\ln 3 \\ &= 10\ln 2 - 6\ln 3 \quad (\text{ឯកតាផ្ទៃ}) \end{aligned}$$

**3** (ឧបឆ្នាំ ២០២៤ ថ្នាក់វិទ្យាសាស្ត្រ)

គេមានអនុគមន៍ $f$ កំណត់លើ $(1,+\infty)$ ដោយ $f(x) = \ln(x+1) - \ln(x-1) - x + 2$ ។ តេតាង $(C)$ ក្រាបរបស់វានៅក្នុងប្លង់ប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

**a** បង្ហាញកន្សោម $f(x)$ និងគណនាលីមីត ៖

○ បង្ហាញថា $f(x) = 2 - x + \ln\left(\frac{x+1}{x-1}\right)$ ៖

គ្រប់ $x \in ]1,+\infty[$ យើងមាន $x+1>0$ និង $x-1>0$ ៖

$$\begin{aligned} f(x) &= \ln(x+1) - \ln(x-1) - x + 2 \\ &= \ln\left(\frac{x+1}{x-1}\right) - x + 2 \\ &= 2 - x + \ln\left(\frac{x+1}{x-1}\right) \quad (\text{ពិត}) \end{aligned}$$

○ គណនាលីមីត ៖

· $\lim\limits_{x\to 1^+} f(x) = \lim\limits_{x\to 1^+}\left[2 - x + \ln\left(\frac{x+1}{x-1}\right)\right] = 1 + \ln(+\infty) = +\infty$

$\Longrightarrow$ បន្ទាត់ $x=1$ ជាអាស៊ីមតូតឈរនៃក្រាប $(C)$

· $\lim\limits_{x\to+\infty} f(x) = \lim\limits_{x\to+\infty}\left[2 - x + \ln\left(\frac{x+1}{x-1}\right)\right] = -\infty + \ln(1) = -\infty$

$\left(\text{ព្រោះ } \lim\limits_{x\to+\infty}\frac{x+1}{x-1} = 1 \Longrightarrow \lim\limits_{x\to+\infty}\ln\left(\frac{x+1}{x-1}\right) = 0\right)$

**b** បង្ហាញដេរីវេ $f'(x)$, សិក្សាអថេរភាព និងសង់តារាងអថេរភាព ៖

- បង្ហាញដេរីវេ $f'(x)$ ៖

$$\begin{aligned} f'(x) &= [\ln(x+1)]' - [\ln(x-1)]' - [x]' + [2]' \\ &= \frac{1}{x+1} - \frac{1}{x-1} - 1 \\ &= \frac{(x-1)-(x+1)}{(x+1)(x-1)} - 1 = \frac{-2}{x^2-1} - 1 \\ &= \frac{-2-(x^2-1)}{x^2-1} = \frac{-(x^2+1)}{x^2-1} = \frac{-(x^2+1)}{(x+1)(x-1)} \quad \text{(ពិត)} \end{aligned}$$

- ទិសដៅអថេរភាព ៖

  គ្រប់ $x \in ]1,+\infty[$ យើងមាន $x^2+1>0$ និង $(x+1)(x-1)=x^2-1>0$ ៖

$$f'(x) = \frac{-(x^2+1)}{(x+1)(x-1)} < 0 \quad \forall x \in ]1,+\infty[$$

  នាំឱ្យអនុគមន៍ $f$ ជាអនុគមន៍ចុះដាច់ខាតលើចន្លោះ $]1,+\infty[$ ៕

- តារាងអថេរភាព ៖

| $x$ | $1$ | | $+\infty$ |
|---|---|---|---|
| $f'(x)$ | ‖ | $-$ | |
| $f(x)$ | $+\infty$ ‖ | $+\infty$ ↘ | $-\infty$ |

ⓒ បង្ហាញថាបន្ទាត់ $(d)$ ជាអាស៊ីមតូតទ្រេត ៖

$$\lim_{x\to+\infty}[f(x)-(-x+2)] = \lim_{x\to+\infty}\ln\left(\frac{x+1}{x-1}\right) = \ln(1) = 0$$

ដូចនេះ បន្ទាត់ $(d): y=-x+2$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ត្រង់ $+\infty$ ៕

ⓓ ប្រៀបធៀបទីតាំងធៀប និងសង់ក្រាប ៖

- ប្រៀបធៀបទីតាំងធៀបនៃ $(C)$ និង $(d)$ ៖

  ពិនិត្យផលដក $f(x)-y_{(d)}=\ln\left(\frac{x+1}{x-1}\right)$ ៖


  ចំពោះ $x>1 \implies x+1>x-1>0 \implies \frac{x+1}{x-1}>1$

  នាំឱ្យ $\ln\left(\frac{x+1}{x-1}\right)>0 \implies f(x)-y_{(d)}>0$ គ្រប់ $x\in]1,+\infty[$ ៕

  ដូចនេះ ក្រាប $(C)$ ស្ថិតនៅខាងលើបន្ទាត់ $(d)$ ជានិច្ចលើចន្លោះ $]1,+\infty[$ ៕

- សង់ក្រាប $(C)$ និងបន្ទាត់ $(d)$ ៖

  ចំណុចពិសេស ៖ ត្រង់ $x=2 \implies f(2)=2-2+\ln 3=\ln 3\approx 1.1$




**4** (ឌុបឆ្នាំ ២០២៣ ថ្នាក់វិទ្យាសាស្ត្រ)

គេមានអនុគមន៍ $f$ កំណត់លើ $\mathbb{R}$ ដោយ $f(x)=4-x-2e^{-x}$ ។ គេតាង $(C)$ ក្រាបរបស់ $f$ ។

(a) (i) ផ្ទៀងផ្ទាត់កន្សោម $f(x)$ និងគណនាលីមីត ៖

- ផ្ទៀងផ្ទាត់ ៖

  គ្រប់ចំនួនពិត $x$ យើងមាន ៖

$$\frac{4e^x-xe^x-2}{e^x}=\frac{4e^x}{e^x}-\frac{xe^x}{e^x}-\frac{2}{e^x}=4-x-2e^{-x}=f(x) \quad \text{(ពិត)}$$

- គណនាលីមីត ៖

  · $\lim\limits_{x\to+\infty} f(x)=\lim\limits_{x\to+\infty}(4-x-2e^{-x})=-\infty$

  $\left(\text{ព្រោះ } \lim\limits_{x\to+\infty}(-x)=-\infty \text{ និង } \lim\limits_{x\to+\infty}2e^{-x}=0\right)$

  · $\lim\limits_{x\to-\infty} f(x)=\lim\limits_{x\to-\infty}\dfrac{4e^x-xe^x-2}{e^x}=-\infty$

  $\left(\text{ព្រោះ } \lim\limits_{x\to-\infty}e^x=0^+ \text{ និង } \lim\limits_{x\to-\infty}xe^x=0 \implies \text{ភាគយក} \to -2\right)$

(ii) បង្ហាញថាបន្ទាត់ $(D)$ ជាអាស៊ីមតូតទ្រេត ៖

$$\lim_{x\to+\infty}[f(x)-(-x+4)]=\lim_{x\to+\infty}[(4-x-2e^{-x})-(-x+4)]=\lim_{x\to+\infty}(-2e^{-x})=0$$

ដូចនេះ បន្ទាត់ $(D): y=-x+4$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ត្រង់ $+\infty$ ៕

(iii) សិក្សាទីតាំងនៃ $(C)$ ធៀបនឹង $(D)$ ៖

ពិនិត្យផលដក $f(x)-y_{(D)}=-2e^{-x}$ ៖

ដោយសារ $e^{-x}>0$ គ្រប់ $x\in\mathbb{R} \implies -2e^{-x}<0$ គ្រប់ $x\in\mathbb{R}$ ៕

ដូចនេះ ក្រាប $(C)$ ស្ថិតនៅខាងក្រោមបន្ទាត់ $(D)$ ជានិច្ចលើ $\mathbb{R}$ ។

(b) (i) គណនា $f'(x)$, សិក្សាអថេរភាព និងរកតម្លៃអតិបរមា ៖

- គណនាដេរីវេ $f'(x)$ ៖

$$f'(x) = (4 - x - 2e^{-x})' = -1 - 2(-e^{-x}) = -1 + 2e^{-x} = \frac{2 - e^x}{e^x}$$

- ទិសដៅអថេរភាព ៖
  - ឱ្យ $f'(x) = 0 \iff -1 + 2e^{-x} = 0 \iff e^x = 2 \iff x = \ln 2$
  - ចំពោះ $x \in ]-\infty, \ln 2[$ ៖ $e^x < 2 \implies 2 - e^x > 0 \implies f'(x) > 0 \implies f$ ជាអនុគមន៍កើន
  - ចំពោះ $x \in ]\ln 2, +\infty[$ ៖ $e^x > 2 \implies 2 - e^x < 0 \implies f'(x) < 0 \implies f$ ជាអនុគមន៍ចុះ
- តម្លៃអតិបរមា ៖

  អនុគមន៍មានតម្លៃអតិបរមាធៀបត្រង់ $x = \ln 2$ គឺ ៖

$$f(\ln 2) = 4 - \ln 2 - 2e^{-\ln 2} = 4 - \ln 2 - 2\left(\frac{1}{2}\right) = 3 - \ln 2 \approx 2.31$$

- តារាងអថេរភាព ៖

| $x$ | $-\infty$ | | $\ln 2$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | |
| $f(x)$ | $-\infty$ | ↗ | $3 - \ln 2$ | ↘ | $-\infty$ |

(ii) រកសមីការបន្ទាត់ប៉ះ $(T)$ ត្រង់ចំណុច $A$ ៖

- ចំណុច $A$ មានអាប់ស៊ីស $x_0 = 0 \implies y_0 = f(0) = 4 - 0 - 2e^0 = 2 \implies A(0, 2)$
- មេគុណប្រាប់ទិស $f'(0) = -1 + 2e^0 = 1$


សមីការបន្ទាត់ប៉ះ $(T)$ មានទម្រង់ $y = f'(0)(x - 0) + f(0) \implies (T) : y = x + 2$ ។

(iii) បង្ហាញថាសមីការ $f(x) = 0$ មានចម្លើយតែមួយគត់ $\beta \in [-1, 0]$ ៖

- លើចន្លោះ $[-1, 0] \subset ]-\infty, \ln 2]$, អនុគមន៍ $f$ ជាប់ និងកើនដាច់ខាត
- $f(-1) = 4 - (-1) - 2e^1 = 5 - 2e \approx -0.44 < 0$
- $f(0) = 2 > 0$

ដោយសារ $f(-1)\cdot f(0)<0$, តាមទ្រឹស្តីបទតម្លៃកណ្តាល សមីការ $f(x)=0$ មានចម្លើយ យ៉ាងតិចមួយ $\beta\in]-1,0[$ ។ ហើយដោយសារ $f$ កើនដាច់ខាតលើ $[-1,0]$ នាំឱ្យចម្លើយ $\beta$ នេះមានតែមួយគត់ ៕

iv សង់បន្ទាត់ប៉ះ $(T)$, អាស៊ីមតូត $(D)$ និងក្រាប $(C)$ ៖




## 5 (ឧបឆ្នាំ ២០២២ ថ្នាក់វិទ្យាសាស្ត្រ)

a សិក្សាអនុគមន៍ $f(x)=x-\ln(1+x)$ ៖

i រកដែនកំណត់ $D$ និងគណនាលីមីត ៖

- ដែនកំណត់ ៖

  អនុគមន៍ $f$ មានន័យលុះត្រាតែ $1+x>0\iff x>-1$ ៖

  $$D=]-1,+\infty[$$

- គណនាលីមីត ៖

  · $\lim\limits_{x\to-1^+}f(x)=\lim\limits_{x\to-1^+}[x-\ln(1+x)]=-1-(-\infty)=+\infty$
  $\Longrightarrow$ បន្ទាត់ $x=-1$ ជាអាស៊ីមតូតឈរនៃក្រាប $(C)$ ត្រង់ $+\infty$

  · $\lim\limits_{x\to+\infty}f(x)=\lim\limits_{x\to+\infty}[x-\ln(1+x)]=\lim\limits_{x\to+\infty}x\left(1-\dfrac{\ln(1+x)}{x}\right)=+\infty\cdot(1-0)=+\infty$

ii សិក្សាអថេរភាព តារាងអថេរភាព និងសញ្ញានៃ $f(x)$ ៖

- ដេរីវេ និងទិសដៅអថេរភាព ៖

  $$f'(x)=1-\frac{1}{1+x}=\frac{1+x-1}{1+x}=\frac{x}{1+x}$$

  · ឱ្យ $f'(x)=0\iff x=0$

  · ចំពោះ $x\in]-1,0[$ ៖ $x<0$ និង $1+x>0\implies f'(x)<0\implies f$ ជា

អនុគមន៍ចុះ

· ចំពោះ $x \in ]0,+\infty[$ ៖ $x > 0$ និង $1+x > 0 \implies f'(x) > 0 \implies f$ ជាអនុគមន៍កើន

○ តម្លៃអប្បបរមា ៖

អនុគមន៍មានតម្លៃអប្បបរមាធៀប (និងជាថ់ខាត) ត្រង់ $x = 0$ គឺ $f(0) = 0 - \ln(1) = 0$ ។

○ តារាងអថេរភាព ៖

| $x$ | $-1$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | ‖ $+\infty$ | ↘ | $0$ | ↗ | $+\infty$ |

○ បញ្ជាក់សញ្ញានៃ $f(x)$ លើ $D$ ៖

ដោយសារ $f(0) = 0$ ជាតម្លៃអប្បបរមាដាច់ខាតនៃ $f$ លើ $D = ]-1,+\infty[$ ៖

$$f(x) \geq 0 \quad \forall x \in ]-1,+\infty[ \quad (\text{និង } f(x) = 0 \iff x = 0)$$ ។

ⓑ សិក្សាទីតាំងធៀបនៃក្រាប $(C)$ និងប៉ារ៉ាបូល $(P) : y = \frac{1}{2}x^2$ ៖

ⓘ សិក្សាអថេរភាពនៃ $g(x)$, រកសញ្ញា និងប្រៀបធៀបទីតាំង ៖

○ ដេរីវេនៃ $g(x) = f(x) - \frac{1}{2}x^2 = x - \ln(1+x) - \frac{1}{2}x^2$ ៖

$$g'(x) = 1 - \frac{1}{1+x} - x = \frac{x}{1+x} - x = \frac{x - x(1+x)}{1+x} = \frac{-x^2}{1+x}$$

○ ទិសដៅអថេរភាព និងសញ្ញានៃ $g(x)$ ៖

គ្រប់ $x \in ]-1,+\infty[$ យើងមាន $1+x > 0$ និង $-x^2 \leq 0$ នាំឱ្យ $g'(x) \leq 0$ គ្រប់ $x \in D$ (និង $g'(x) = 0 \iff x = 0$) ។

ដូចនេះ $g$ ជាអនុគមន៍ចុះដាច់ខាតលើចន្លោះ $]-1,+\infty[$ ។

ដោយសារ $g(0) = f(0) - \frac{1}{2}(0)^2 = 0 - 0 = 0$ ៖

· ចំពោះ $x \in ]-1,0[$ ៖ $x < 0 \implies g(x) > g(0) = 0$

· ចំពោះ $x = 0$ ៖ $g(0) = 0$

· ចំពោះ $x \in ]0,+\infty[$ ៖ $x > 0 \implies g(x) < g(0) = 0$

○ សន្និដ្ឋានទីតាំងធៀប ៖

· ចំពោះ $x \in ]-1,0[$ ៖ $g(x) > 0 \implies f(x) > \frac{1}{2}x^2$


$\Longrightarrow$ ក្រាប $(C)$ នៅខាងលើប៉ារ៉ាបូល $(P)$

· ចំពោះ $x=0$ ៖ $g(0)=0 \Longrightarrow$ ក្រាប $(C)$ និង $(P)$ ប្រសព្វគ្នានៅគល់តម្រុយ $O(0,0)$

· ចំពោះ $x\in]0,+\infty[$ ៖ $g(x)<0 \Longrightarrow f(x)<\dfrac{1}{2}x^2$

$\Longrightarrow$ ក្រាប $(C)$ នៅខាងក្រោមប៉ារ៉ាបូល $(P)$

ii សង់ក្រាប $(C)$ និងប៉ារ៉ាបូល $(P)$ ៖




**6** (ឧបឆ្នាំ ២០២១ ផ្នែកវិទ្យាសាស្ត្រ)

គេមានអនុគមន៍ $f$ ដែល $f(x)=x-2+\dfrac{2(x+1)}{e^x}$ ។ យើងតាង $(C)$ ក្រាបរបស់អនុគមន៍ $f$ នៅក្នុងប្លង់ប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

a រកដែនកំណត់ និងគណនាលីមីត ៖

○ ដែនកំណត់ ៖

ដោយសារ $e^x>0$ គ្រប់ $x\in\mathbb{R}$ នាំឱ្យភាគបែងខុសពី 0 ជានិច្ច ៖

$$D=\mathbb{R}=]-\infty,+\infty[$$

○ គណនាលីមីត ៖

· $\lim\limits_{x\to+\infty} f(x)=\lim\limits_{x\to+\infty}\left(x-2+\dfrac{2x}{e^x}+\dfrac{2}{e^x}\right)=+\infty-2+0+0=+\infty$

$\left(\text{ព្រោះ } \lim\limits_{x\to+\infty}\dfrac{x}{e^x}=0 \text{ និង } \lim\limits_{x\to+\infty}\dfrac{2}{e^x}=0\right)$

· $\lim\limits_{x\to-\infty} f(x)=\lim\limits_{x\to-\infty}\left(x-2+2(x+1)e^{-x}\right)=-\infty+(-\infty\cdot+\infty)=-\infty$

b បង្ហាញថាបន្ទាត់ $(D)$ ជាអាស៊ីមតូតទ្រេត និងសិក្សាទីតាំងធៀប ៖

○ អាស៊ីមតូតទ្រេត ៖

$$\lim_{x\to+\infty}[f(x)-(x-2)]=\lim_{x\to+\infty}\frac{2(x+1)}{e^x}=0$$

ដូចនេះ បន្ទាត់ $(D): y = x - 2$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ត្រង់ $+\infty$ ។

- ទីតាំងធៀបនៃ $(C)$ ធៀបនឹង $(D)$ ៖

  ពិនិត្យផលដក $f(x) - y_{(D)} = \dfrac{2(x+1)}{e^x}$ ៖

  ដោយសារ $e^x > 0$ គ្រប់ $x \in \mathbb{R}$ សញ្ញានៃផលដកអាស្រ័យលើសញ្ញានៃ $(x+1)$ ៖

  · ចំពោះ $x \in ]-\infty, -1[$ ៖ $x + 1 < 0 \implies f(x) - y_{(D)} < 0$

  $\implies$ ក្រាប $(C)$ នៅខាងក្រោមបន្ទាត់ $(D)$

  · ចំពោះ $x = -1$ ៖ $f(-1) = -3 = y_{(D)}$

  $\implies$ ក្រាប $(C)$ និងបន្ទាត់ $(D)$ ប្រសព្វគ្នានៅចំណុច $I(-1, -3)$

  · ចំពោះ $x \in ]-1, +\infty[$ ៖ $x + 1 > 0 \implies f(x) - y_{(D)} > 0$

  $\implies$ ក្រាប $(C)$ នៅខាងលើបន្ទាត់ $(D)$

ⓒ បង្ហាញដេរីវេ $f'(x)$ និងសិក្សាអថេរភាព ៖

- បង្ហាញដេរីវេ $f'(x)$ ៖

$$\begin{aligned} f'(x) &= (x-2)' + \left[\frac{2(x+1)}{e^x}\right]' \\ &= 1 + \frac{2(e^x) - 2(x+1)e^x}{(e^x)^2} \\ &= 1 + \frac{2e^x - 2xe^x - 2e^x}{e^{2x}} = 1 - \frac{2xe^x}{e^{2x}} = 1 - \frac{2x}{e^x} = \frac{e^x - 2x}{e^x} \quad \text{(ពិត)} \end{aligned}$$

- ទិសដៅអថេរភាព ៖

  គេមាន $e^x - 2x > 0$ និង $e^x > 0$ គ្រប់ $x \in \mathbb{R}$ នាំឱ្យ ៖

$$f'(x) = \frac{e^x - 2x}{e^x} > 0 \quad \forall x \in \mathbb{R}$$

ដូចនេះ អនុគមន៍ $f$ ជាអនុគមន៍កើនដាច់ខាតលើ $\mathbb{R}$ ។

- តារាងអថេរភាព ៖

| $x$ | $-\infty$ | | $+\infty$ |
|---|---|---|---|
| $f'(x)$ | | $+$ | |
| $f(x)$ | $-\infty$ | $\nearrow$ | $+\infty$ |

ⓓ បង្ហាញភាពស្របនៃបន្ទាត់ប៉ះ $(\Delta)$ និងសង់ក្រាប ៖

- បង្ហាញថាសមីការបន្ទាត់ប៉ះ $(\Delta)$ ស្របនឹង $(D)$ ៖

· អាប់ស៊ីសចំណុចប៉ះគឺ $x_0 = 0$

$\Longrightarrow y_0 = f(0) = 0 - 2 + \dfrac{2(0+1)}{e^0} = 0 \Longrightarrow O(0,0)$


· មេគុណប្រាប់ទិសនៃបន្ទាត់ប៉ះ $(\Delta)$ គឺ $f'(0) = \dfrac{e^0 - 2(0)}{e^0} = 1$

· មេគុណប្រាប់ទិសនៃបន្ទាត់ $(D) : y = x - 2$ គឺ $a = 1$

ដោយសារមេគុណប្រាប់ទិសស្មើគ្នា $(f'(0) = a = 1)$ នាំឱ្យបន្ទាត់ប៉ះ $(\Delta)$ ស្របទៅនឹងបន្ទាត់ $(D)$ ។

សមីការបន្ទាត់ប៉ះ $(\Delta)$ គឺ $y = 1(x-0) + 0 \Longrightarrow (\Delta) : y = x$ ។

○ សង់បន្ទាត់ $(D), (\Delta)$ និងក្រាប $(C)$ ៖




## 7 (បាក់ឌុបឆ្នាំ ២០១៩ ថ្នាក់វិទ្យាសាស្ត្រ)

អនុគមន៍ $f$ កំណត់លើ $(0,+\infty)$ ដោយ $f(x) = \dfrac{x^2-2}{x} - \ln x$ តាង $(C)$ ក្រាបរបស់អនុគមន៍ $f$ នៅក្នុងប្លង់ប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $(O, \vec{i}, \vec{j})$ ។

a i បង្ហាញកន្សោមនៃ $f(x)$ ទាំងពីរទម្រង់ ៖

គ្រប់ $x \in ]0,+\infty[$ យើងមាន ៖

○ $f(x) = \dfrac{x^2-2}{x} - \ln x = x - \dfrac{2}{x} - \ln x = x\left(1 - \dfrac{\ln x}{x} - \dfrac{2}{x^2}\right)$ (ពិត)

○ $f(x) = \dfrac{x^2-2}{x} - \ln x = \dfrac{x^2 - 2 - x\ln x}{x} = \dfrac{1}{x}(x^2 - x\ln x - 2)$ (ពិត)

ii គណនាលីមីតនៃ $f(x)$ ត្រង់ 0 និងត្រង់ $+\infty$ ៖

○ $\lim\limits_{x\to 0^+} f(x) = \lim\limits_{x\to 0^+}\left[\dfrac{1}{x}(x^2 - x\ln x - 2)\right] = (+\infty)(0-0-2) = -\infty$

$\left(\text{ព្រោះ } \lim\limits_{x\to 0^+}\dfrac{1}{x} = +\infty \text{ និង } \lim\limits_{x\to 0^+} x\ln x = 0\right)$

$\Longrightarrow$ បន្ទាត់ $x = 0$ (អ័ក្សអរដោនេ) ជាអាស៊ីមតូតឈរនៃក្រាប $(C)$

○ $\lim\limits_{x\to+\infty} f(x) = \lim\limits_{x\to+\infty}\left[x\left(1 - \dfrac{\ln x}{x} - \dfrac{2}{x^2}\right)\right] = (+\infty)(1-0-0) = +\infty$

$\left(\text{ព្រោះ } \lim\limits_{x\to+\infty}\dfrac{\ln x}{x} = 0 \text{ និង } \lim\limits_{x\to+\infty}\dfrac{2}{x^2} = 0\right)$

(b) (i) គណនាដេរីវេ $f'(x)$ និងបញ្ជាក់សញ្ញា ៖

- គណនាដេរីវេ ៖

$$f'(x)=\left(x-\frac{2}{x}-\ln x\right)'=1-\left(-\frac{2}{x^2}\right)-\frac{1}{x}=1+\frac{2}{x^2}-\frac{1}{x}=\frac{x^2-x+2}{x^2}$$

- បញ្ជាក់សញ្ញា ៖
  ដោយសារ $x^2>0$ គ្រប់ $x\in]0,+\infty[$ នាំឱ្យសញ្ញានៃ $f'(x)$ គឺដូចគ្នាទៅនឹងសញ្ញានៃភាគយក $(x^2-x+2)$ គ្រប់ $x\in]0,+\infty[$ ។

(ii) សិក្សាអថេរភាព និងសង់តារាងអថេរភាព ៖

- ពិនិត្យកន្សោម $x^2-x+2$ មាន $\Delta=(-1)^2-4(1)(2)=1-8=-7<0$
- ដោយសារ $\Delta<0$ និងមេគុណ $a=1>0$ នាំឱ្យ $x^2-x+2>0$ គ្រប់ $x\in\mathbb{R}$
- ដូចនេះ $f'(x)>0$ គ្រប់ $x\in]0,+\infty[$ នាំឱ្យអនុគមន៍ $f$ ជាអនុគមន៍កើនដាច់ខាតលើ $]0,+\infty[$ ។
- តារាងអថេរភាព ៖

| $x$ | $0$ | | $+\infty$ |
|---|---|---|---|
| $f'(x)$ | ‖ | $+$ | |
| $f(x)$ | ‖ | $-\infty$ ↗ | $+\infty$ |

(c) (i) រកសមីការបន្ទាត់ប៉ះត្រង់ចំណុច $A$ ដែលមានអាប់ស៊ីស $1$ ៖

- អាប់ស៊ីស $x_A=1\implies y_A=f(1)=\frac{1^2-2}{1}-\ln 1=-1\implies A(1,-1)$
- មេគុណប្រាប់ទិស $f'(1)=\frac{1^2-1+2}{1^2}=2$

សមីការបន្ទាត់ប៉ះ $(T_A)$ ត្រង់ $A$ គឺ ៖

$$y=f'(1)(x-1)+f(1)=2(x-1)-1\implies (T_A):y=2x-3$$ ។

(ii) រកកូអរដោនេចំណុច $B$ ដែលបន្ទាត់ប៉ះស្របនឹងបន្ទាត់ $y=x$ ៖

- បន្ទាត់ប៉ះត្រង់ $B$ ស្របនឹងបន្ទាត់ $y=x$ លុះត្រាតែមេគុណប្រាប់ទិសស្មើគ្នា ៖


$$f'(x)=1\iff\frac{x^2-x+2}{x^2}=1\iff x^2-x+2=x^2\iff -x+2=0\iff x=2$$

- អរដោនេនៃចំណុច $B$ គឺ ៖

$$y_B = f(2) = \frac{2^2-2}{2} - \ln 2 = 1 - \ln 2 \approx 1 - 0.7 = 0.3$$

ដូចនេះ កូអរដោនេចំណុច $B$ គឺ $B(2, 1-\ln 2)$ (ឬ $B(2, 0.3)$) ។
(សមីការបន្ទាត់ប៉ះ $(T_B)$ ត្រង់ $B$ គឺ $(T_B) : y = x - 1 - \ln 2$) ។

**d** សង់ក្រាប $(C)$ និងបន្ទាត់ប៉ះត្រង់ $A$ និងត្រង់ $B$ ៖




**8** (ឧបឆ្នាំ ២០១៨ ថ្នាក់វិទ្យាសាស្ត្រ)

គេមានអនុគមន៍ $f$ កំណត់លើ $(1, +\infty)$ ដោយ $f(x) = -x + 4 + \ln\left(\frac{x+1}{x-1}\right)$ ។ គេតាងដោយ $(C)$ ក្រាបរបស់វា នៅក្នុងប្លង់ប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $(O, \vec{i}, \vec{j})$ ។

**a** គណនាលីមីតនៃ $f$ ត្រង់ 1 និង $+\infty$ ៖

- $\lim\limits_{x\to 1^+} f(x) = \lim\limits_{x\to 1^+}\left[-x+4+\ln\left(\frac{x+1}{x-1}\right)\right] = 3 + \ln(+\infty) = +\infty$
  $\left(\text{ព្រោះ } \lim\limits_{x\to 1^+}\frac{x+1}{x-1} = \frac{2}{0^+} = +\infty \implies \lim\limits_{x\to 1^+}\ln\left(\frac{x+1}{x-1}\right) = +\infty\right)$
  $\implies$ បន្ទាត់ $x = 1$ ជាអាស៊ីមតូតឈរនៃក្រាប $(C)$ ត្រង់ $+\infty$
- $\lim\limits_{x\to+\infty} f(x) = \lim\limits_{x\to+\infty}\left[-x+4+\ln\left(\frac{x+1}{x-1}\right)\right] = -\infty + \ln(1) = -\infty$
  $\left(\text{ព្រោះ } \lim\limits_{x\to+\infty}\frac{x+1}{x-1} = 1 \implies \lim\limits_{x\to+\infty}\ln\left(\frac{x+1}{x-1}\right) = 0\right)$

**b** បង្ហាញដេរីវេ $f'(x)$, សិក្សាអថេរភាព និងសង់តារាងអថេរភាព ៖

- បង្ហាញដេរីវេ $f'(x)$ ៖

គ្រប់ $x \in ]1,+\infty[$ យើងមាន ៖

$$\begin{aligned} f'(x) &= (-x+4)' + [\ln(x+1) - \ln(x-1)]' \\ &= -1 + \frac{1}{x+1} - \frac{1}{x-1} \\ &= -1 + \frac{(x-1)-(x+1)}{(x+1)(x-1)} = -1 - \frac{2}{x^2-1} \\ &= \frac{-(x^2-1)-2}{x^2-1} = \frac{-x^2+1-2}{x^2-1} = \frac{-(x^2+1)}{(x+1)(x-1)} \quad \text{(ពិត)} \end{aligned}$$

- ទិសដៅអថេរភាព ៖

  គ្រប់ $x \in ]1,+\infty[$ យើងមាន $x^2+1>0$ និង $(x+1)(x-1) = x^2-1 > 0$ ៖

$$f'(x) = \frac{-(x^2+1)}{(x+1)(x-1)} < 0 \quad \forall x \in ]1,+\infty[$$

  នាំឱ្យអនុគមន៍ $f$ ជាអនុគមន៍ចុះដាច់ខាតលើចន្លោះ $]1,+\infty[$ ។

- តារាងអថេរភាព ៖

| $x$ | $1$ | | $+\infty$ |
|---|---|---|---|
| $f'(x)$ | ‖ | $-$ | |
| $f(x)$ | ‖ | $+\infty$ ↘ | $-\infty$ |

(c) (i) បង្ហាញថាបន្ទាត់ $d_1 : y = -x+4$ ជាអាស៊ីមតូតទ្រេត ៖

$$\lim_{x\to+\infty}[f(x)-(-x+4)] = \lim_{x\to+\infty} \ln\left(\frac{x+1}{x-1}\right) = \ln(1) = 0$$

ដូចនេះ បន្ទាត់ $d_1 : y = -x+4$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ត្រង់ $+\infty$ ។

(ii) បង្ហាញថា $\dfrac{x+1}{x-1} > 1$ និងប្រៀបធៀបទីតាំង ៖

- ចំពោះគ្រប់ $x>1 \implies x+1>x-1>0$ ៖

$$\frac{x+1}{x-1} = \frac{x-1+2}{x-1} = 1 + \frac{2}{x-1} > 1 \quad \text{(ពិត, ព្រោះ } \frac{2}{x-1} > 0\text{)}$$

- ពិនិត្យផលដក $f(x) - y_{d_1} = \ln\left(\dfrac{x+1}{x-1}\right)$ ៖

ដោយសារ $\dfrac{x+1}{x-1} > 1 \implies \ln\left(\dfrac{x+1}{x-1}\right) > 0 \implies f(x) - y_{d_1} > 0$ គ្រប់ $x \in ]1,+\infty[$ ។

ដូចនេះ ក្រាប $(C)$ ស្ថិតនៅខាងលើបន្ទាត់អាស៊ីមតូត $d_1$ ជានិច្ចលើចន្លោះ $]1,+\infty[$ ។

ⓓ កំណត់កូអរដោនេចំណុចប៉ះ និងសរសេរសមីការបន្ទាត់ប៉ះ $d_2$ ៖

- រកកូអរដោនេចំណុចប៉ះ ៖

  មេគុណប្រាប់ទិសនៃបន្ទាត់ប៉ះ $d_2$ គឺ $f'(x) = -\dfrac{5}{3}$ ៖

$$\begin{aligned}\frac{-(x^2+1)}{x^2-1} = -\frac{5}{3} &\iff 3(x^2+1) = 5(x^2-1)\\ &\iff 3x^2+3 = 5x^2-5\\ &\iff 2x^2 = 8 \iff x^2 = 4 \implies x = 2 \quad (\text{ព្រោះ } x>1)\end{aligned}$$

  អរដោនេនៃចំណុចប៉ះ ៖


$$y = f(2) = -2+4+\ln\left(\frac{2+1}{2-1}\right) = 2+\ln 3 \approx 2+1.1 = 3.1$$

  ដូចនេះ ចំណុចប៉ះមានកូអរដោនេ $M(2,2+\ln 3)$ (ឬ $M(2,3.1)$) ។

- សរសេរសមីការបន្ទាត់ប៉ះ $d_2$ ៖

$$\begin{aligned}y &= f'(2)(x-2)+f(2)\\ &= -\frac{5}{3}(x-2)+(2+\ln 3)\\ &= -\frac{5}{3}x+\frac{10}{3}+2+\ln 3\\ &= -\frac{5}{3}x+\frac{16}{3}+\ln 3 \quad \left(\text{ឬ } y \approx -\frac{5}{3}x+6.43\right)\end{aligned}$$ ។

ⓔ សង់ក្រាប $(C)$, អាស៊ីមតូត $d_1$ និងបន្ទាត់ប៉ះ $d_2$ ៖




**9** (ឧបត្ថម្ភ ២០១៧ ថ្នាក់វិទ្យាសាស្ត្រ)

គេមានអនុគមន៍ $f$ កំណត់លើ $\mathbb{R}$ ដោយ $f(x)=x+\dfrac{1-3e^x}{1+e^x}$ ។ គេតាងដោយ $(C)$ ក្រាបរបស់វា នៅក្នុងប្លង់ប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

ⓐ បង្ហាញកន្សោម $f(x)$, គណនាលីមីត, អាស៊ីមតូតទ្រេត $d_1$ និងទីតាំងធៀប ៖

- បង្ហាញថា $f(x)=x+1-\dfrac{4e^x}{1+e^x}$ ៖
  គ្រប់ចំនួនពិត $x$ យើងមាន ៖

$$x+1-\frac{4e^x}{1+e^x}=x+\frac{(1+e^x)-4e^x}{1+e^x}=x+\frac{1-3e^x}{1+e^x}=f(x)\quad\text{(ពិត)}$$

- គណនាលីមីតត្រង់ $-\infty$ ៖ $\lim\limits_{x\to-\infty}f(x)=\lim\limits_{x\to-\infty}\left(x+1-\dfrac{4e^x}{1+e^x}\right)=-\infty+1-0=-\infty$
  $\left(\text{ព្រោះ }\lim\limits_{x\to-\infty}e^x=0\right)$
- បង្ហាញថាបន្ទាត់ $d_1$ ជាអាស៊ីមតូតទ្រេត ៖

$$\lim_{x\to-\infty}[f(x)-(x+1)]=\lim_{x\to-\infty}\left(-\frac{4e^x}{1+e^x}\right)=0$$

ដូចនេះ បន្ទាត់ $d_1:y=x+1$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ត្រង់ $-\infty$ ៕

- ទីតាំងធៀបនៃ $(C)$ ធៀបនឹង $d_1$ ៖
  ពិនិត្យផលដក $f(x)-y_{d_1}=-\dfrac{4e^x}{1+e^x}$ ៖
  ដោយសារ $e^x>0$ គ្រប់ $x\in\mathbb{R}\implies 1+e^x>0\implies -\dfrac{4e^x}{1+e^x}<0$ គ្រប់ $x\in\mathbb{R}$ ៕
  ដូចនេះ ក្រាប $(C)$ ស្ថិតនៅខាងក្រោមបន្ទាត់ $d_1$ ជានិច្ចលើ $\mathbb{R}$ ៕

ⓑ គណនាលីមីតត្រង់ $+\infty$, អាស៊ីមតូតទ្រេត $d_2$ និងទីតាំងធៀប ៖

- គណនាលីមីតត្រង់ $+\infty$ ៖

$$\lim_{x\to+\infty} f(x) = \lim_{x\to+\infty}\left(x+\frac{1-3e^x}{1+e^x}\right) = \lim_{x\to+\infty}\left(x+\frac{e^x(e^{-x}-3)}{e^x(e^{-x}+1)}\right) = +\infty - 3 = +\infty$$

- បង្ហាញថាបន្ទាត់ $d_2$ ជាអាស៊ីមតូតទ្រេត ៖
  $\lim_{x\to+\infty}[f(x)-(x-3)] = \lim_{x\to+\infty}\left(\frac{1-3e^x}{1+e^x}+3\right) = \lim_{x\to+\infty}\frac{1-3e^x+3+3e^x}{1+e^x}$
  $= \lim_{x\to+\infty}\frac{4}{1+e^x} = 0$
  ដូចនេះ បន្ទាត់ $d_2 : y = x-3$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ត្រង់ $+\infty$ ៕
- ទីតាំងធៀបនៃ $(C)$ ធៀបនឹង $d_2$ ៖
  ពិនិត្យផលដក $f(x) - y_{d_2} = \frac{4}{1+e^x}$ ៖
  ដោយសារ $1+e^x > 0$ គ្រប់ $x \in \mathbb{R} \implies \frac{4}{1+e^x} > 0$ គ្រប់ $x \in \mathbb{R}$ ៕
  ដូចនេះ ក្រាប $(C)$ ស្ថិតនៅខាងលើបន្ទាត់ $d_2$ ជានិច្ចលើ $\mathbb{R}$ ៕

(c) (i) គណនាដេរីវេ $f'(x)$ និងបង្ហាញកន្សោម ៖


$$\begin{aligned}
f'(x) &= \left(x+1-\frac{4e^x}{1+e^x}\right)' \\
&= 1-4\cdot\frac{e^x(1+e^x)-e^x(e^x)}{(1+e^x)^2} \\
&= 1-\frac{4e^x}{(1+e^x)^2} \\
&= \frac{(1+e^x)^2-4e^x}{(1+e^x)^2} = \frac{1+2e^x+e^{2x}-4e^x}{(1+e^x)^2} \\
&= \frac{e^{2x}-2e^x+1}{(e^x+1)^2} = \frac{(e^x-1)^2}{(e^x+1)^2} = \left(\frac{e^x-1}{e^x+1}\right)^2 \quad \text{(ពិត)}
\end{aligned}$$

(ii) សិក្សាអថេរភាព តារាងអថេរភាព និងសង់ក្រាប ៖

- ទិសដៅអថេរភាព ៖
  គ្រប់ចំនួនពិត $x$ យើងមាន $\left(\frac{e^x-1}{e^x+1}\right)^2 \geq 0$ នាំឱ្យ $f'(x) \geq 0$ គ្រប់ $x \in \mathbb{R}$ ៕
  ចំណាំ ៖ $f'(x) = 0 \iff e^x - 1 = 0 \iff e^x = 1 \iff x = 0$ ។
  ដោយសារ $f'(x) > 0$ គ្រប់ $x \neq 0$ នាំឱ្យអនុគមន៍ $f$ ជាអនុគមន៍កើនដាច់ខាតលើ $\mathbb{R}$ ៕
  តម្លៃត្រង់ចំណុចពិសេស ៖ $f(0) = 0 + \frac{1-3(1)}{1+1} = -1$ (ក្រាប $(C)$ មានបន្ទាត់ប៉ះផ្តេកត្រង់ចំណុចរបត់ $I(0,-1)$) ៕
- តារាងអថេរភាព ៖

| $x$ | $-\infty$ | $0$ | $+\infty$ |
|---|---|---|---|
| $f'(x)$ | $+$ | $0$ | $+$ |
| $f(x)$ | $-\infty$ | $-1$ | $+\infty$ |

- សង់ក្រាប $(C)$ និងអាស៊ីមតូត $d_1$ និង $d_2$ ៖




**10** (ឧបឆ្នាំ ២០១៦ ថ្នាក់វិទ្យាសាស្ត្រ)

គេឲ្យអនុគមន៍ $f$ កំណត់លើ $\mathbb{R}$ ដោយ $f(x)=x+2-\dfrac{4e^x}{e^x+3}$ ។ គេតាង $(C)$ ក្រាបរបស់វានៅក្នុងប្លង់ប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

**a** i គណនាលីមីតនៃ $f$ ត្រង់ $-\infty$ និង $+\infty$ ៖

- $\lim\limits_{x\to-\infty} f(x)=\lim\limits_{x\to-\infty}\left(x+2-\dfrac{4e^x}{e^x+3}\right)=-\infty+2-0=-\infty$
  $\left(\text{ព្រោះ }\lim\limits_{x\to-\infty}e^x=0\implies\lim\limits_{x\to-\infty}\dfrac{4e^x}{e^x+3}=0\right)$
- $\lim\limits_{x\to+\infty} f(x)=\lim\limits_{x\to+\infty}\left(x+2-\dfrac{4e^x}{e^x+3}\right)=\lim\limits_{x\to+\infty}\left(x+2-\dfrac{4}{1+3e^{-x}}\right)=+\infty+2-4=+\infty$
  $\left(\text{ព្រោះ }\lim\limits_{x\to+\infty}e^{-x}=0\implies\lim\limits_{x\to+\infty}\dfrac{4e^x}{e^x+3}=4\right)$

ii សិក្សាទីតាំងនៃក្រាប $(C)$ ធៀបនឹងបន្ទាត់ $d_1: y=x+2$ ៖

ពិនិត្យផលដក $f(x)-y_{d_1}=-\dfrac{4e^x}{e^x+3}$ ៖

ដោយសារ $e^x>0$ និង $e^x+3>0$ គ្រប់ $x\in\mathbb{R}\implies-\dfrac{4e^x}{e^x+3}<0$ គ្រប់ $x\in\mathbb{R}$ ។

ដូចនេះ ក្រាប $(C)$ ស្ថិតនៅខាងក្រោមបន្ទាត់ $d_1$ ជានិច្ចលើ $\mathbb{R}$ ។

(ចំណាំ ៖ ដោយសារ $\lim\limits_{x\to-\infty}[f(x)-y_{d_1}]=0$ នាំឱ្យ $d_1$ ជាអាស៊ីមតូតទ្រេតនៃ $(C)$ ត្រង់ $-\infty$)

៕

(b) (i) ស្រាយបញ្ជាក់ថា $f'(x) = \left(\dfrac{e^x-3}{e^x+3}\right)^2$ ៖

គ្រប់ចំនួនពិត $x$ យើងមាន ៖

$$\begin{aligned} f'(x) &= (x+2)' - 4\cdot\left[\frac{e^x}{e^x+3}\right]' \\ &= 1 - 4\cdot\frac{e^x(e^x+3)-e^x(e^x)}{(e^x+3)^2} \\ &= 1 - \frac{12e^x}{(e^x+3)^2} = \frac{(e^x+3)^2-12e^x}{(e^x+3)^2} \\ &= \frac{e^{2x}+6e^x+9-12e^x}{(e^x+3)^2} = \frac{e^{2x}-6e^x+9}{(e^x+3)^2} \\ &= \frac{(e^x-3)^2}{(e^x+3)^2} = \left(\frac{e^x-3}{e^x+3}\right)^2 \quad \text{(ពិត)} \end{aligned}$$

(ii) សិក្សាអថេរភាព និងសង់តារាងអថេរភាព ៖

- ទិសដៅអថេរភាព ៖

  គ្រប់ចំនួនពិត $x$ យើងមាន $f'(x) = \left(\dfrac{e^x-3}{e^x+3}\right)^2 \geq 0$ គ្រប់ $x \in \mathbb{R}$ ៕

  ចំណាំ ៖ $f'(x) = 0 \iff e^x - 3 = 0 \iff e^x = 3 \iff x = \ln 3$ ៕

  ដោយសារ $f'(x) > 0$ គ្រប់ $x \neq \ln 3$ នាំឱ្យអនុគមន៍ $f$ ជាអនុគមន៍កើនដាច់ខាតលើ $\mathbb{R}$ ៕

- តម្លៃអរដោនេត្រង់ចំណុចពិសេស $x = \ln 3$ ៖

$$f(\ln 3) = \ln 3 + 2 - \frac{4(3)}{3+3} = \ln 3 + 2 - 2 = \ln 3 \approx 1.1$$

- តារាងអថេរភាព ៖

| $x$ | $-\infty$ | | $\ln 3$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | ↗ | $\ln 3$ | ↗ | $+\infty$ |

(c) (i) កំណត់លក្ខណៈនៃបន្ទាត់ប៉ះ $d_2$ ត្រង់ចំណុច $I(\ln 3)$ ៖

- អាប់ស៊ីសនៃចំណុច $I$ គឺ $x_I = \ln 3 \implies y_I = f(\ln 3) = \ln 3 \implies I(\ln 3, \ln 3)$
- មេគុណប្រាប់ទិសនៃបន្ទាត់ប៉ះ $d_2$ គឺ $f'(\ln 3) = 0$

ដូចនេះ បន្ទាត់ប៉ះ $d_2$ ជាបន្ទាត់ប៉ះផ្តេកត្រង់ចំណុច $I$ ហើយមានសមីការ $d_2 : y = \ln 3$ ។

ii សិក្សាទីតាំងនៃក្រាប $(C)$ ធៀបនឹងបន្ទាត់ $d_2$ ៖

ដោយសារ $f$ ជាអនុគមន៍កើនដាច់ខាតលើ $\mathbb{R}$ និង $f(\ln 3) = \ln 3$ ៖

- ចំពោះ $x \in ]-\infty, \ln 3[$ ៖ $f(x) < f(\ln 3) = \ln 3 \implies$ ក្រាប $(C)$ នៅខាងក្រោមបន្ទាត់ $d_2$
- ចំពោះ $x = \ln 3$ ៖ $f(\ln 3) = \ln 3 \implies$ ក្រាប $(C)$ និងបន្ទាត់ $d_2$ ប្រសព្វគ្នានៅចំណុច $I(\ln 3,$
- ចំពោះ $x \in ]\ln 3, +\infty[$ ៖ $f(x) > f(\ln 3) = \ln 3 \implies$ ក្រាប $(C)$ នៅខាងលើបន្ទាត់ $d_2$


d i បង្ហាញថាសមីការបន្ទាត់ប៉ះ $d_3$ ត្រង់ $x = 0$ គឺ $y = \dfrac{1}{4}x + 1$ ៖

- អាប់ស៊ីសចំណុចប៉ះ $x_0 = 0 \implies y_0 = f(0) = 0 + 2 - \dfrac{4(1)}{1+3} = 1$
- មេគុណប្រាប់ទិស $f'(0) = \left(\dfrac{1-3}{1+3}\right)^2 = \left(\dfrac{-2}{4}\right)^2 = \dfrac{1}{4}$

សមីការបន្ទាត់ប៉ះ $d_3$ គឺ ៖

$$y = f'(0)(x-0) + f(0) \implies d_3 : y = \frac{1}{4}x + 1 \text{ ។}$$

ii សង់ក្រាប $(C)$ និងបន្ទាត់ប៉ះ $d_1, d_2, d_3$ ៖




## 11 (ឧបឆ្នាំ ២០១៥ ថ្នាក់វិទ្យាសាស្ត្រ)

a សិក្សាអនុគមន៍ $g(x) = x^2 + \ln x$ លើ $(0, +\infty)$ ៖

i a បង្ហាញថា $g$ ជាអនុគមន៍កើនដាច់ខាត ៖

គ្រប់ $x \in ]0, +\infty[$ យើងមាន ៖

$$g'(x) = (x^2 + \ln x)' = 2x + \frac{1}{x}$$

ដោយសារ $x > 0 \implies 2x > 0$ និង $\dfrac{1}{x} > 0$ នាំឱ្យ $g'(x) > 0$ គ្រប់ $x \in ]0, +\infty[$ ។

ដូចនេះ $g$ ជាអនុគមន៍កើនដាច់ខាតលើចន្លោះ $]0, +\infty[$ ។

**b** គណនា $g(1)$ ៖

$$g(1) = 1^2 + \ln(1) = 1 + 0 = 1 \text{ ។}$$

**ii** **a** ទាញបញ្ជាក់លទ្ធផល ៖

ដោយសារ $g$ ជាអនុគមន៍កើនដាច់ខាតលើ $]0, +\infty[$ ៖

· បើ $x \geq 1 \implies g(x) \geq g(1) \implies x^2 + \ln x \geq 1$ ។

· បើ $0 < x \leq 1 \implies g(x) \leq g(1) \implies x^2 + \ln x \leq 1$ ។

**b** កំណត់សញ្ញានៃកន្សោម $x^2 + \ln x - 1$ ៖

· ចំពោះ $x \in ]0, 1[$ ៖ $g(x) < g(1) = 1 \implies x^2 + \ln x - 1 < 0$

· ចំពោះ $x = 1$ ៖ $g(1) = 1 \implies x^2 + \ln x - 1 = 0$

· ចំពោះ $x \in ]1, +\infty[$ ៖ $g(x) > g(1) = 1 \implies x^2 + \ln x - 1 > 0$

**b** សិក្សាអនុគមន៍ $f(x) = x + 1 - \dfrac{\ln x}{x}$ លើ $(0, +\infty)$ ៖

**i** សិក្សាលីមីតត្រង់ 0 និង $+\infty$ ៖

○ $\lim\limits_{x \to 0^+} f(x) = \lim\limits_{x \to 0^+} \left( x + 1 - \dfrac{\ln x}{x} \right) = 0 + 1 - \left( \dfrac{-\infty}{0^+} \right) = 1 - (-\infty) = +\infty$

$\implies$ បន្ទាត់ $x = 0$ (អ័ក្សអរដោនេ) ជាអាស៊ីមតូតឈរនៃក្រាប $C$

○ $\lim\limits_{x \to +\infty} f(x) = \lim\limits_{x \to +\infty} \left( x + 1 - \dfrac{\ln x}{x} \right) = +\infty + 1 - 0 = +\infty$

$\left( \text{ព្រោះ } \lim\limits_{x \to +\infty} \dfrac{\ln x}{x} = 0 \right)$

**ii** បង្ហាញថាដេរីវេ $f'(x) = \dfrac{x^2 + \ln x - 1}{x^2}$ ៖

គ្រប់ $x \in ]0, +\infty[$ យើងមាន ៖

$$\begin{aligned} f'(x) &= (x+1)' - \left( \frac{\ln x}{x} \right)' \\ &= 1 - \frac{(\ln x)' \cdot x - \ln x \cdot (x)'}{x^2} \\ &= 1 - \frac{\frac{1}{x} \cdot x - \ln x \cdot 1}{x^2} = 1 - \frac{1 - \ln x}{x^2} \\ &= \frac{x^2 - (1 - \ln x)}{x^2} = \frac{x^2 + \ln x - 1}{x^2} \quad \text{(ពិត)} \end{aligned}$$

**iii** សិក្សាសញ្ញានៃ $f'(x)$ និងសង់តារាងអថេរភាព ៖

○ សញ្ញានៃ $f'(x)$ ៖

ដោយសារ $x^2 > 0$ គ្រប់ $x \in ]0, +\infty[$ នាំឱ្យសញ្ញានៃ $f'(x)$ គឺដូចសញ្ញានៃកន្សោម $x^2 + \ln x - 1$ (តាមលទ្ធផលសំណួរ A.2-ab) ៖

· ចំពោះ $x \in ]0, 1[$ ៖ $f'(x) < 0 \implies f$ ជាអនុគមន៍ចុះ

· ចំពោះ $x=1$ ៖ $f'(1)=0$

· ចំពោះ $x\in]1,+\infty[$ ៖ $f'(x)>0 \Longrightarrow$ $f$ ជាអនុគមន៍កើន

○ តម្លៃអប្បបរមា ៖

អនុគមន៍មានតម្លៃអប្បបរមាធៀប (និងជាច់ខាត) ត្រង់ $x=1$ គឺ $f(1)=1+1-\dfrac{\ln 1}{1}=2$ ៕

○ តារាងអថេរភាព ៖

| $x$ | $0$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | ‖ $+\infty$ | ↘ | $2$ | ↗ | $+\infty$ |

iv a បង្ហាញថាបន្ទាត់ $\Delta: y=x+1$ ជាអាស៊ីមតូតទ្រេត ៖

$$\lim_{x\to+\infty}[f(x)-(x+1)]=\lim_{x\to+\infty}\left(-\frac{\ln x}{x}\right)=0$$

ដូចនេះ បន្ទាត់ $\Delta: y=x+1$ ជាអាស៊ីមតូតទ្រេតនៃក្រាប $C$ ត្រង់ $+\infty$ ៕

b សិក្សាទីតាំងធៀប, កំណត់ចំណុចប្រសព្វ $I$ និងសង់ក្រាប ៖

○ ទីតាំងធៀបនៃ $C$ និង $\Delta$ ៖

ពិនិត្យផលដក $f(x)-y_\Delta=-\dfrac{\ln x}{x}$ ៖

· ចំពោះ $x\in]0,1[$ ៖ $\ln x<0$

$\Longrightarrow -\dfrac{\ln x}{x}>0 \Longrightarrow$ ក្រាប $C$ នៅខាងលើបន្ទាត់ $\Delta$

· ចំពោះ $x=1$ ៖ $f(1)-y_\Delta(1)=0$


$\Longrightarrow$ ក្រាប $C$ ប្រសព្វបន្ទាត់ $\Delta$ ត្រង់ចំណុច $I(1,2)$

· ចំពោះ $x\in]1,+\infty[$ ៖ $\ln x>0 \Longrightarrow -\dfrac{\ln x}{x}<0$

$\Longrightarrow$ ក្រាប $C$ នៅខាងក្រោមបន្ទាត់ $\Delta$

○ កូអរដោនេចំណុចប្រសព្វ $I$ ៖ $I(1,2)$ (ត្រូវជាចំណុចអប្បបរមានៃក្រាប $C$ ផងដែរ) ៕

○ សង់បន្ទាត់ $\Delta$ និងក្រាប $C$ ៖




**12** (ឧបឆ្នាំ ២០១៤ ថ្នាក់វិទ្យាសាស្ត្រ លើកទី២)

គេមានអនុគមន៍ $f$ កំណត់លើ $I=]0,+\infty[$ ដោយ $f(x)=\dfrac{x+\ln x}{x^2}$ ។

ⓐ គណនា $h(1)$ និងសិក្សាអថេរភាពនៃ $h(x)=-x+1-2\ln x$ លើ $I=]0,+\infty[$ ៖

- គណនា $h(1)$ ៖

$$h(1)=-1+1-2\ln(1)=0-0=0 \text{ ॥}$$

- សិក្សាអថេរភាពនៃ $h(x)$ ៖

គ្រប់ $x\in]0,+\infty[$ យើងមាន ៖

$$h'(x)=(-x+1-2\ln x)'=-1-\frac{2}{x}=\frac{-x-2}{x}$$

ដោយសារ $x>0 \implies -x-2<0$ នាំឱ្យ $h'(x)<0$ គ្រប់ $x\in]0,+\infty[$ ॥

ដូចនេះ អនុគមន៍ $h$ ជាអនុគមន៍ចុះដាច់ខាតលើចន្លោះ $]0,+\infty[$ ॥

(ទាញយកសញ្ញានៃ $h(x)$ ៖ ព្រោះ $h$ ចុះដាច់ខាត និង $h(1)=0$ នាំឱ្យចំពោះ $x\in]0,1[, h(x)>0$ និងចំពោះ $x\in]1,+\infty[, h(x)<0$

ⓑ សិក្សាអនុគមន៍ $f(x)=\dfrac{x+\ln x}{x^2}$ លើ $I=]0,+\infty[$ ៖

ℹ គណនាលីមីតត្រង់ 0 និងត្រង់ $+\infty$ ៖

- $\lim\limits_{x\to 0^+} f(x)=\lim\limits_{x\to 0^+}\dfrac{x+\ln x}{x^2}=\dfrac{-\infty}{0^+}=-\infty$

$\left(\text{ព្រោះ } \lim\limits_{x\to 0^+}(x+\ln x)=-\infty \text{ និង } \lim\limits_{x\to 0^+} x^2=0^+\right)$

$\implies$ បន្ទាត់ $x=0$ (អ័ក្សអរដោនេ) ជាអាស៊ីមតូតឈរនៃក្រាប $C$

